- ពង្រឹងសមត្ថភាព និងការគ្រប់គ្រងរបស់ស្ថាប័ន បរិយាកាសអំណោយផល និងយន្តការហិរញ្ញប្បទាន ដើម្បីឆ្លងកាត់អន្តរកាលឈានទៅរកសេដ្ឋកិច្ចបៃតង និងផ្អែកលើចំណេះដឹងជាគោល សម្រាប់វិបុលភាព និងសមភាព។
- ពង្រឹងការយល់ដឹង និងការទទួលបានចំណេះដឹង បច្ចេកវិទ្យា និងការបង្កើតថ្មី។

ជំហានបន្ត

- រាជរដ្ឋាភិបាលបានចាត់វិធានការជាច្រើន ដើម្បីគ្រប់គ្រង និងកាត់បន្ថយការដាក់សម្ពាធ និងការខូចខាតដល់ធនធានធម្មជាតិ និងបរិស្ថាន។
- ក៏ប៉ុន្តែប្រសិទ្ធភាពនៅមានកម្រិតដោយសារបញ្ហាហិរញ្ញវត្ថុ និងបច្ចេកទេស កិច្ចសម្របសម្រួលកិច្ចសហការ និងការដាក់បញ្ចូលនិរន្តរភាពនៃធនធានធម្មជាតិ និងបរិស្ថានទៅក្នុងការរៀបចំផែនការ និងកម្មវិធីតាមវិស័យ ជាពិសេសទៅក្នុងការធ្វើផែនការ និងកម្មវិធីនៅថ្នាក់ក្រោមជាតិនៅមានកម្រិត ឬ មិនទាន់បានអនុវត្ត។

ជំហានបន្ត

- ការអនុវត្តការងារតាមទម្លាប់ មិនមែនជាជម្រើសសម្រាប់កម្ពុជា ដើម្បីអភិវឌ្ឍឆ្ពោះទៅរកសង្គមមួយដែលមានភាពបៃតង បញ្ចេញការបោនទាប ធន់នឹងអាកាសធាតុ មានសមធម៌ ចីរភាព និងផ្អែកលើចំណេះដឹងនោះទេ។ ដូច្នេះ ត្រូវធ្វើឱ្យប្រសើរឡើងថែមទៀតនូវការធ្វើទំនើបកម្ម នៃអភិបាលកិច្ច និងការគ្រប់គ្រងបរិស្ថាននិងធនធានធម្មជាតិ សម្រាប់កំណើន និងការអភិវឌ្ឍរយៈពេលវែង។
- យុទ្ធសាស្ត្រជាតិនេះ បានដាក់ចេញនូវចក្ខុវិស័យវែងឆ្ងាយ និងបានកំណត់បេសកកម្មរបស់ខ្លួន ក្នុងការផ្តល់នូវផែនទីបង្ហាញផ្លូវសម្រាប់កៀរគរធនធាន និងសកម្មភាពនានា។
- ការកៀរគរមូលនិធីគឺ ជាអាទិភាពខ្ពស់មួយ ក្នុងការអនុវត្តសកម្មភាពដែលមានអាទិភាពខ្ពស់ និងអាចអនុវត្តបានដើម្បីទទួលបានលទ្ធផលភ្លាមៗ។

ជំហានបន្ត

- ដូច្នេះ ដើម្បីឱ្យមានការបង្កើនចំណាយលើវិស័យបរិស្ថានបន្ថែម ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក្រសួងបរិស្ថាន និងស្ថាប័នពាក់ព័ន្ធ គួរលើកឡើងនូវហេតុផលសេដ្ឋកិច្ចថា ការវិនិយោគលើនិរន្តរភាពបរិស្ថាន គឺមានផលចំណេញ ដោយផ្តល់ភស្តុតាង ដូចជា ការបង្កើតការងារ ការបង្កើនភាពប្រកួតប្រជែងផ្នែកពាណិជ្ជកម្ម និងការឈានចូលទីផ្សារពិភពលោកប្រសើរជាងមុន។
- ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុគួរផ្តល់គោលការណ៍ណែនាំច្បាស់លាស់ដល់បណ្តាក្រសួង និងស្ថាប័នពាក់ព័ន្ធ ក្នុងការបញ្ជ្រាបការកែលម្អគុណភាព បរិស្ថាន និងនិរន្តរភាពធនធានធម្មជាតិទៅក្នុងយុទ្ធសាស្ត្រតាមវិស័យ ស្របជៀងនឹងការបញ្ជ្រាបយៃនឌ័រ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ដែលជាបញ្ហាអន្តរវិស័យ។

សូមអរគុណ!

សិក្ខាសាលាត្រួតពិនិត្យលទ្ធផលការងារអភិវឌ្ឍន៍ដោយចីរភាព
ឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០

គោលដៅអភិវឌ្ឍន៍ដោយចីរភាព សម្រាប់វិស័យបរិស្ថាន និងការអភិវឌ្ឍដោយចីរភាព

លោក ឡុង សូណា អនុប្រធាននាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ
អគ្គលេខាធិការដ្ឋាន ក.ជ.អ.ច.
ក្រសួងបរិស្ថាន ២១ តុលា ២០១៩

អាតិការបទបង្ហាញ

1. បញ្ហាប្រឈម
2. អំពី SDGs កម្ពុជា
3. ស្ថានភាពនៃការអនុវត្ត SDGs កម្ពុជា
4. ជំហានបន្ទាប់

ឆ្ពោះទៅកាន់ប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់
នៅឆ្នាំ២០៣០ និងប្រទេសចំណូលខ្ពស់ឆ្នាំ២០៥០

១. បញ្ហាប្រឈម: ធនធានធម្មជាតិ (១)

កំណើនសេដ្ឋកិច្ចកម្ពុជាទន្ទឹមនឹងការកើនឡើងសម្ពាធទៅលើធនធានធម្មជាតិ និងបរិស្ថាន

Cambodia's economic growth has been coupled with increasing pressure on natural resources and the environment





Source: ODC and FA

72% in 1973 (ODC)

About 50% in 2014 (FA)

១. បញ្ហាប្រឈម៖ ធនធានធម្មជាតិ (២)



Photos: WWF, Cambodia

ហានិភ័យបរិស្ថាន

ផលប៉ះពាល់លើប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះ និងប្រភេទផ្សេងៗដែលមានហានិភ័យ

ហានិភ័យសង្គម

- ប៉ះពាល់លើឱកាសបង្កើនជីវភាពសម្រាប់សហគមន៍មូលដ្ឋានដែលពឹងអាស្រ័យលើប្រព័ន្ធអេកូឡូស៊ី (ទាំងមុខទំនិញ និងសេវាកម្ម)
- ការកើនឡើងភាពងាយរងគ្រោះរបស់សហគមន៍មូលដ្ឋានដែលបណ្តាលមកពីទឹកជំនន់ និងគ្រោះរាំងស្ងួត

១. បញ្ហាប្រឈម៖ បរិស្ថានទីក្រុង (៣)

បញ្ហាប្រឈមបរិស្ថានសម្រាប់ទីក្រុង

ការបំពុលខ្យល់
សំឡេង
ការកកស្ទះ

សំរាម

សេចក្តីព្រាងយុទ្ធសាស្ត្រជាតិសម្រាប់ការគ្រប់គ្រងសំរាម បានបញ្ជាក់ថា

- *0.5 Kg ក្នុង១ថ្ងៃសម្រាប់១នាក់(1.5kg នៅភ្នំពេញ)*
- *30% នៃសំរាមត្រូវបានប្រមូល*
- *10% នៃទីក្រុងបានបែងចែកសំរាមនៅភ្នំពេញ*
- ការប្រមូលសម្រាមកើនឡើងជាលំដាប់ក្នុងរយៈពេល១០ឆ្នាំចុងក្រោយ ពី៥ ទៅ១៥% ក្នុង១ឆ្នាំ
- ពុំមានទីលានចាក់សម្រាមតាមបច្ចេកទេស

១. បញ្ហាប្រឈម៖ ការប្រែប្រួលអាកាសធាតុ (៤)

- រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថា ការប្រែប្រួលអាកាសធាតុគឺជាបញ្ហាប្រឈមដ៏ចំបងសម្រាប់ការអភិវឌ្ឍដោយចីរភាពរបស់កម្ពុជា



< 0.1%
ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់

ភ្នាពងាយរងគ្រោះខ្ពស់ទៅនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ

ទឹកជំនន់ធ្ងន់ធ្ងរ
ខ្សល់ព្យុះ
ការកើនឡើងកំដៅ
ការកើនឡើងកំពស់ទឹកសមុទ្រ
ការផ្លាស់ប្តូរបបទឹកភ្លៀង

ដោយសារសមត្ថភាពបន្សាំទាប និងភាពងាយរងគ្រោះខ្លាំងនៃសេដ្ឋកិច្ច

២. ការធ្វើមូលដ្ឋានបនីយកម្ម SDG កម្ពុជា

ស្ថាប័នដឹកនាំការងារនេះ:

- **ក្រសួងផែនការ**

សម្របសម្រួលការធ្វើមូលដ្ឋានបនីយកម្មគោលដៅអភិវឌ្ឍន៍ដោយចីរភាពនៅកម្ពុជា

(facilitates discussions with key line ministries/ agencies; discussions with SNEC)

-ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងក្រសួងបរិស្ថាន ដឹកនាំការធ្វើមូលដ្ឋានបនីកម្ម សូចនាករគោលដៅអភិវឌ្ឍន៍ដោយចីរភាពពាក់ព័ន្ធបរិស្ថាន និងការអភិវឌ្ឍដោយចីរភាព

CSDGs ជាភាសាខ្មែរ និងអង់គ្លេសត្រូវបានផ្សព្វផ្សាយនៅខែមីនា ២០១៩

2015
- ប្រកាសការរៀបចំ CSDG

2016
- ចាប់ផ្តើមពិភាក្សាពីការរៀបចំ CSDG (ក្រសួងផែនការជាអ្នកផ្តល់ការណែនាំដល់វិស័យ)

2017
- មូលដ្ឋានបន្ទីយតុម្មរបស់ក្រសួងស្ថាប័នសខាន សម្រាប់គោលដៅខុសៗគ្នា
- ក្រុមការងារបច្ចេកទេសផ្ទៀងផ្ទាត់សូចនាករ

2018
- កែសម្រួលសូចនាករ(MOP, OCM, CRDB/CDC, SNEC)
- ប្រែក្លាយគោលដៅអភិវឌ្ឍន៍ដោយចីរភាពទៅសូចនាករ NSDP 2019-23

2018
- អនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រី១៩ វិច្ឆិកា ១៨

បញ្ហាប្រឈម

បញ្ហាស្ថាប័ន និងបរិបទជាតិ
- គោលដៅSDG សាកលមាន:
  - *17 គោលដៅ*
  - *169 ចំណុចដៅ*
  - *232 សូចនាករ*
- បញ្ហាបន្ទីជាមួយផែនការជាតិ
- សម្របសម្រួលអន្តរវិស័យ
- ការវិភាគ ប្រមូល និងទិន្នន័យដែលមាន
- ធនធានសម្រាប់ការអនុវត្ត
- ការផ្តល់ធាតុចូលរបស់ថ្នាក់ក្រោមជាតិនៅមានកម្រិត

៣. អំពី SDGs កម្ពុជា

គោលដៅ ចំណុចដៅ សូចនាកររបស់CSDGs:

- ១៨ គោលដៅ៖ ១៧មកពីគោលដៅសាកល និង១ គោលដៅជាតិ (18 ការបញ្ចប់ផលប៉ះពាល់ជាអវិជ្ជមានរបស់មីន/សំណល់ជាតិផ្ទុះពីសង្គ្រាម និងជំរុញការសង្គ្រោះជនរងគ្រោះ)
- ៨៨ ចំណុចដៅ៖ ៨៤ ពីសាកលក្នុងចំណោម១៦៩ និងបន្ថែម៤ចំណុចដៅរបស់ជាតិ
- CSDGs ស្មើឡើង១៤៨ សូចនាកដែលរួមមាន:
  - ៥៣ សូចនាករពីសូចនាករសាកល
  - ២៣ សូចនាការដែលបែងចែកពីសូចនាកដើម
  - ៧៣ កែសម្រួល និងសូចនាកថ្មី

គោលដៅពាក់ព័ន្ធវិស័យបរិស្ថាន និងការអភិវឌ្ឍន៍ដោយចីរភាព (១)

គោលដៅពាក់ព័ន្ធវិស័យបរិស្ថាន និងការអភិវឌ្ឍន៍ដោយចីរភាព ឆ្នាំគោលដៅ ១៩ សូចនាករ

គោលដៅទី២៖ បញ្ចប់ភាពអត់ឃ្លាន សម្រេចឲ្យបានសន្តិសុខស្បៀង ធ្វើឲ្យប្រសើរឡើងស្ថានភាពអាហារូបត្ថម្ភ និង លើកកម្ពស់កសិកម្មប្រកបដោយចីរភាព

- ២.៥.២ អត្រាភាគរយនៃចំនួនគ្រួសារក្នុងសហគមន៍តំបន់ការពារធម្មជាតិ ដែលត្រូវបានលើកកម្ពស់កម្រិតជីវភាព តាមរយៈ ការទទួលបានផលប្រយោជន៍ពី ផល-អនុផលព្រៃឈើ ការបញ្ចូលវិស័យកសិកម្មនិងការបង្កើនជម្រើសមុខរបរពី ទេសចរណ៍ធម្មជាតិ និងការអភិរក្សតំបន់បេតិកភណ្ឌវប្បធ៌មធម្មជាតិ ទេសចរណ៍ធម្មជាតិ នៅក្នុងតំបន់ការពារធម្មជាតិ

គោលដៅទី៦៖ ធានាឲ្យមានទឹកនិងអនាម័យ និងការគ្រប់គ្រងទឹកនិងអនាម័យប្រកបដោយចីរភាព សម្រាប់ប្រជាជនគ្រប់រូប

- ៦.៣.១ សមាមាត្រនៃសំណល់រាវដែលបានសម្អាតប្រកបដោយសុវត្ថិភាព។

គោលដៅទី១១៖ ធ្វើឲ្យទីក្រុង និងកន្លែងតាំងទីលំនៅថ្មីសម្រាប់ប្រជាជន មានលក្ខណៈ បរិយាប័ន្ន សុវត្ថិភាព ធន់នឹងបម្រែបម្រួលអាកាសធាតុនិងចីរភាព

- ១១.៦.១ ភាគរយសំរាមសំណល់រឹងដែលប្រមូល នៅរាជធានី ក្រុង ស្រុក
- ១១.៦.២ ភាគរយនៃការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិច
- ១១.៦.៣ ភាគរយនៃសំណល់រឹងត្រូវបានគ្រប់គ្រងតាមគោលការណ៍បច្ចេកទេស
- ១១.៦.៤ គុណភាពទឹកសាធារណៈ ទឹកកខ្វក់ ផ្អែកលើប៉ារ៉ាម៉ែត្រ pH DO BOD COD TSS TN TP NH3 Oil and Grease Coliform នៅតាមគោលដៅក្នុងឆ្នាំ

គោលដៅពាក់ព័ន្ធវិស័យបរិស្ថាន និងការអភិវឌ្ឍន៍ដោយចីរភាព (២)

គោលដៅពាក់ព័ន្ធវិស័យបរិស្ថាន និងការអភិវឌ្ឍន៍ដោយចីរភាព ឆ្នាំគោលដៅ ១៩ សូចនាករ

គោលដៅទី១២៖ ធានាឲ្យមានចីរភាពក្នុងទម្រង់នៃការប្រើប្រាស់និងផលិតកម្ម

- ១២.៤.១ អត្រានៃការសាយភាយសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុសាយភាយ ចូលទៅក្នុងបរិស្ថាន
- ១២.៤.២ ភាគរយនៃការកាត់បន្ថយការសាយភាយសារធាតុបារតសាយភាយចូលទៅក្នុងបរិស្ថាន
- ១២.៤.៣ ភាគរយនៃការ គ្រប់គ្រងសំណល់គ្រោះថ្នាក់ សំណល់ជីវសាស្ត្រ និងវិទ្យុសកម្ម
- ១២.៥.១ អត្រានៃការកែច្នៃឡើងវិញនូវវត្ថុធាតុដើមដែលបានប្រើប្រាស់

គោលដៅទី១៣៖ ចាត់វិធានការជាបន្ទាន់ ដើម្បីប្រយុទ្ធប្រឆាំងនឹងបម្រែបម្រួលអាកាសធាតុ និងផលប៉ះពាល់របស់វា

- ១៣.១.១ ភាគរយនៃឃុំ សង្កាត់រងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុ
- ១៣.១.២ ភាគរយនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីសកម្មភាពកាត់បន្ថយនៅពេលប្រៀបធៀបចំហាក(សេណារីយ៉ូ)បញ្ចេញឧស្ម័នតាមទំលាប់
- ១៣.១.៣ភាគរយនៃកំណើនចំណាយសាធារណៈសម្រាប់ការប្រែប្រួលអាកាសធាតុ
- ១៣.៣.១កម្រិតស្ថាប័នដែលត្រៀមសម្រាប់ឆ្លើយតបការប្រែប្រួលអាកាសធាតុដោយបង្ហាញជាភាគរយនៃសមត្ថភាពស្ថាប័នដែលបានបញ្ជ្រាបផ្នែកទាំង៥នៃការប្រែប្រួលអាកាសធាតុ
- ១៣.៣.២.ភាគរយនៃកសិករដាំដុះ ចិញ្ចឹមសត្វ ចិញ្ចឹមត្រី អ្នកនេសាទនិងប្រជាសហគមន៍មូលដ្ឋានទទួលបានការផ្សព្វផ្សាយ និងបណ្តុះបណ្តាលពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ

គោលដៅពាក់ព័ន្ធវិស័យបរិស្ថាន និងការអភិវឌ្ឍន៍ដោយចីរភាព (៣)

គោលដៅពាក់ព័ន្ធវិស័យបរិស្ថាន និងការអភិវឌ្ឍន៍ដោយចីរភាព ពាក់ព័ន្ធជាមួយគោលដៅ ១៩ សូចនាករ

គោលដៅទី១៤៖ អភិរក្សនិងប្រើប្រាស់ប្រកបដោយចីរភាពនូវ មហាសមុទ្រ សមុទ្រ និង ធនធានសមុទ្រ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព

- ១៤.១.១ ភាគយនៃការកាត់បន្ថយការបំពុលសមុទ្រដោយសកម្មភាពអភិរក្ស
- ១៤.២.១ មុខងារនិងសេវា សំខាន់ៗរបស់ប្រព័ន្ធអេកូឡូស៊ីសមុទ្រនិងតំបន់ឆ្នេរត្រូវ បានថែរក្សានិងស្តារតាមការចាំបាច់

គោលដៅទី១៥៖ ការពារ ស្តារ និងជំរុញការប្រើប្រាស់ប្រកបដោយចីរភាពនូវប្រព័ន្ធអេកូឡូ ស៊ីនៅលើដែនគោក គ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព ប្រយុទ្ធប្រឆាំងនឹងវិនាភាពដី បញ្ឈប់និងបង្វែរទិសនៃការសឹករេចរឹលគុណភាពដី និងបញ្ឈប់កុំឲ្យបាត់បង់ជីវជាតិដីនិងដី វិចម្រុះ (ដោយសារការផ្លេរផ្ទៃដីអភិរក្ស មកក្រសួងបរិស្ថាន ការរៀបចំនេះមុនពេលផ្លេរមុខ ងារ ជាការទទួលខុសត្រូវ អាណត្តិ របស់ស្ថាប័នក្រសួងបរិស្ថាន)

- ១៥.២.១ ភាគយនៃផ្ទៃដីព្រៃឈើការពារ និងគ្រប់គ្រងដោយនិរន្តរភាព
- ១៥.៩.២ ចំនួនគោលនយោបាយ យុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្ត ស្តីពីសេវាកម្ម ប្រព័ន្ធអេកូឡូស៊ី ដែលត្រូវបានបង្កើត និងអនុវត្ត

ទម្លាប់គោលដៅ និងសូចនាករ

ផ្នែកទី ១: Metadata

ចំនុចដៅ	សូចនាករ	ភ្នាក់ងារទទួលខុសត្រូវ	ប្រភពទិន្នន័យ	វិធីទិន្នន័យ	និយមន័យ	វិធីសាស្ត្រគណនាតម្លៃសូចនាករ		សំគាល់
						ភាគយក	ភាគបែង	

Schedule 2: Goals, Targets, and Indicator core data

			ចំនួនគោល	គោលដៅប្រចាំឆ្នាំ														គោលដៅបញ្ចប់
ចំណុចដៅ	សូចនាករ	ឯកតា	2015	2016	2017	2018	2019	2020	2021	2022	2023	2024	2025	2026	2027	2028	2029	2030

វិធីសាស្ត្រក្នុងការបញ្ចូលCSDGs នៅកម្ពុជា

- សង្គតិភាព និងភាពជាប់ពាក់ព័ន្ធ គ្នារវាង CSDGs ផែនការ និង សកម្មភាព
- ចាត់អាទិភាព និងរៀបចំជម្រើសគោលនយោបាយ ដោយរាប់បញ្ចូលគោលដៅ CSDGs
  - គោលការណ៍ *ពុំមានទុក្ខអ្នកណាម្នាក់ចុះចាល* និងការមិនទាន់បញ្ចប់នៃ CMDGS
  - ភាពត្រូវគ្នារវាងសូចនាករ CSDGs ជាមួយគោលបំណងអ្វីដែលមានស្រាប និងថ្មីរបស់ជាតិគឺជាមូលដ្ឋាននៃវិធីចាត់អាទិភាពរបស់កម្ពុជា
  - កាតាលីករសកម្មភាពគោលនយោបាយ



CSDG Framework's points of intersection with planning and budgeting processes

ការបញ្ចូលCSDGs នៅក្នុងប្រព័ន្ធផែនការ

- បញ្ចូលទៅក្នុងការកសាងផែនការយុទ្ធសាស្ត្រតាមវិស័យ
- ត្រួតពិនិត្យផែនការអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ
- ដៃគូអភិវឌ្ឍន៍ អាចប្រើក្របខណ្ឌCSDG ជាផែនទីបង្ហាញផ្លូវសម្រាប់ជំនួយនិងសកម្មភាពរបស់គេ
- អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកអាចបញ្ចូលCSDGsទៅក្នុងផែនការសកម្មភាពសម្រាប់អនុវត្ត

៤. ស្ថានភាពការអនុវត្ត CSDGs

វឌ្ឍនភាពនៃការអនុវត្តនៅត្រឹមចុងឆ្នាំ២០១៨។ នៅធាប់ពេកសម្រាប់វាស់វែងនូវភាពរីកចម្រើន គោលដៅទាំងអស់ (6 focused and 12 other Goals) បានទទួលជោគជ័យច្រើន គឺប្រហែល៤៩% សម្រេចបាន ឬលើសពីការរំពឹងទុក ប្រហែល៨%ទទួលលទ្ធផលតិចជាងការរំពឹងទុក ហើយប្រហែល៤៣% នៃគោលដៅខ្វះទិន្នន័យ



៥. ផែនការបន្តសម្រាប់ CSDG

- ការអនុវត្តCSDGsនៅបន្ត និងតម្រូវឱ្យមានការចូលរួមពីគ្រប់ភាគីនៅក្នុងសង្គម ដោយរួមទាំងទាំងវិស័យឯកជន អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋ
- បញ្ចូប CSDGs ទៅក្នុងប្រព័ន្ធគោលនយោបាយ និងផែនការនៅគ្រប់កម្រិតជាពិសេសថ្នាក់ក្រោមជាតិ តាមរយៈការចូលរួមពីគ្រប់ដៃគូនៅថ្នាក់មូលដ្ឋាន
- កម្ពុជាតិត្រូវការធនធានច្រើនបន្ថែមលើថវិកាជាតិ ជាពិសេសពីវិស័យឯកជន ដើម្បីសម្រេចគោលដៅ CSDGs
- រាជរដ្ឋាភិបាលកម្ពុជាមានឆន្ទៈខ្ពស់ក្នុងការសម្រេចរបៀបវារៈ២០៣០
- រាជរដ្ឋាភិបាលកម្ពុជាមានឆន្ទៈប្រកាន់ខ្ជាប់នូវគោលការណ៍រួម *ពុំមានទុកអ្នកណាម្នាក់ចោល* ដែលដឹកនាំដោយសហប្រជាជាតិ

Thank You

https://ncsd.moe.gov.kh
General Secretariat of
National Council for Sustainable Development

Annual Meeting of the National Council for Sustainable Development

Cambodia's SDGs Related to Environment and Sustainable Development

Mr. Sona LONG
Deputy Director, Department of Administration, Planning and Finance
General Secretariat, National Council for Sustainable Development

Ministry of Environment, 21 October 2019

Contents of Presentation

1. Emerging Challenges
2. SDGs Development Process
3. About Cambodia's SDGs
4. Implementation Status of Cambodia's SDGs
5. Way forward

Moving toward becoming an upper middle-income country by 2030 and a high income country by 2050

1. Emerging Challenges: NRM (1)

Cambodia's economic growth has been coupled with increasing pressure on natural resources and the environment



Source: ODC and FA

72% in 1973 (ODC)



About 50% in 2014 (FA)

1. Emerging Challenges: NRM (2)

Photos: WWF, Cambodia

Environmental risks

- Impact on ecosystems, and biodiversity and species at risk

Social risks

- Impact on livelihood opportunities for local communities who depend on ecosystem goods and services
- Increasing vulnerability of local communities to floods and droughts

1. Emerging Challenges: Urban Environment (3)

New environmental challenges to cities

Air pollution
Noise
Congestion

Waste

Draft National Waste Management Strategy indicate:

- *0.5 Kg/capita/day nationally (1.5 in PP)*
- *30% solid waste collection coverage*
- *10% of the cities have waste segregation*

In PP:

- collection of waste has been rising in the last 10yrs (5 to 15% annually)
- No sanitary landfills

5

1. Emerging Challenges: Climate Change (4)

- RGC recognizes Climate Change as a major challenge to Cambodia's efforts to develop sustainably

< 0.1% global GHG emissions

Highly vulnerable to CC impacts

Severe floods
Storms
Droughts
Increasing temperatures
Sea level rise
Changing rainfall regimes

due to its low adaptive capacity and high vulnerability of its economy

6

2. Developing Cambodia's SDGs

Leading Agencies:

- **Ministry of Planning**
  Coordinates the localization of SDGs in Cambodia (facilitates discussions with key line ministries/ agencies; discussions with SNEC)
- **National Council for Sustainable Development and MoE**
  Leads the localization of cross cutting SDGs related to environment and CC/SD

2015
- CSDG launching

2016
- Kick-off of localization discussions (MoP guidance to sectors)

2017
- Localization work lead by key ministries for different sets of SDG targets
- TWGs validation of the proposed set indicators

2018
- Revised list of indicators (MOP, OCM, CRDB/CDC, SNEC)
- Translating SDGs indicators to NSDP 2019-23 indicators

2018 ...
- Approved by Council of Ministers in full Cabinet meeting on **19 November 2018**

The CSDGs (Kh and Eng version) were circulated in Mar. 2019

Challenges:

- Fit national context and institutional issues
- Global SDGs data set:
  17 goals,
  169 targets
  232 indicators
- Hardwired with national planning
- Cross-sectoral coordination
- Data availability, collection and analysis
- Resource for implementation
- Limited inputs from sub-national level

7

3. About Cambodia's SDGs

Goals, Targets, and Indicators of CSDGs:

- 18 Goals: 17 from global goals and 1 National goal (18th End the negative impact of Mine/ERW and promote victim assistance)
- 88 Targets: 84 from global among the 169; and add 4 national targets.
- CSDGs Proposed 148 Indicators including:
  - 52 indicators from global indicators;
  - 23 indicators disaggregated from original indicators;
  - 73 revised and new indicators (proxy indicators)

8

Goals Related to Environment & SD in CSDGs (1)



Goals Related to Environment & SD in CSDGs (2)



Goals Related to Environment & SD in CSDGs (3)

SDG related to Envt. & SD
7 Goals , 19 Indicators

Goal 14: Conserve and sustainably use the oceans, seas and marine resources for sustainable development

- 14.1.1 Percentage of the reduction of the sea pollution by the conservation activities
- 14.2.1 Key ecosystem function and service of marine and coast area maintained and restore as necessary

Goal 15: Protect, restore and promote sustainable use of terrestrial ecosystems, sustainably manage forests, combat desertification, and halt and reverse land degradation and halt biodiversity loss

- 15.2.1 Percentage of sustainable forest protection and management
- 15.9.2 Number of policies, strategies and regulations on ecosystem services is established and implemented

Target and Indicator Data Schedules

Schedule 1: Metadata

Targets	Indicators	Responsible agencies	Source of data	Cycle of data	Definition	Method of calculation		Remarks
						Nominator	Denominator	

Schedule 2: Goals, Targets, and Indicator core data

Targets	Indicators	Unit	Based line	Targets Values												End Targets
			2015	2016	2017	2018	2019	2020	2021	2022	2023	2024	2025	2026	2027	2028	2029	2030

Approaches to Integrate CSDGs in Cambodia

- Consistency and coherence between the CSDGs and plans and actions;
- Prioritize and make policy choices, including between CSDG targets
  - The principle of ***no one left behind***; and *unfinished business* under the CMDGs
  - Fit between the CSDG targets and existing and new national objectives must form the basis of Cambodia's general prioritization approach
  - Catalytic policy actions



CSDG Framework's points of intersection with planning and budgeting processes

Integrate CSDG into Planning System

- Also integrate into Sectoral Strategic Development Plans (SSDPs);
- Sub-national Development Plans Review;
- DPs can use CSDG Framework as roadmap to guide their assistance and activities in Cambodia;
- CSOs organizations can integrate CSDGs into their action plans for implement

4. Implementation Status of Cambodia's SDGs

Snapshot of progress at the end of 2018; **remains early days** to measure progress.

All goals, both focused 6 goals and other 12 goals, have **made strong progresses** as about 49% is achieved on or above track and only around 8% is below the targets; about 43% is of CSDG Targets **lack sufficient data**.



5. Way Forward of CSDG

- CSDG Implementation still continues and requires participation from all actors in the society particularly private sector, CSOs, and citizen;
- Integration CSDG into policy and plan systems in all levels, especially at sub-national level to call for participation of all partners in local level;
- Cambodia needs more financial mobilization in addition to national budget, especially from private sector for achievement of CSDG;
- RGC has strong commitment to achievement of Agenda 2030;
- RGC is committed to adhere to common principle of "No one left behind", spearheaded by United Nations.

Thank You

https://ncsd.moe.gov.kh
General Secretariat of
National Council for Sustainable Development

សេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ នៃព្រះរាជាណាចក្រកម្ពុជា

ឯកឧត្តម សុត យា អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន

គន្លឹះទី១: បទបញ្ញត្តិទូទៅ

គន្លឹះនេះ មានបញ្ជាក់យ៉ាងច្បាស់ពីវិសាលភាពនៃក្រមនេះ និងបានបង្ហាញពីគ្រប់គោលការណ៍ទូទៅនៃច្បាប់បរិស្ថាន ដែលចាំបាច់ ដើម្បីធានាឱ្យមានការបកស្រាយ និងពង្រឹកការអនុវត្តក្រមនេះឱ្យបានត្រឹមត្រូវ ដោយមានភ្ជាប់នូវយន្តការគាំទ្រជាច្រើន ដោយប្រើប្រាស់ទស្សនទាន "បរិស្ថានសម្រាប់ទាំងអស់គ្នា ទាំងអស់គ្នាសម្រាប់បរិស្ថាន"។

I. គោលដៅ គោលបំណងរំពឹងទុក និងវិសាលភាព

❖គោលបំណង៖ ក្រមនេះ ត្រូវបានតាក់តែងឡើង ដើម្បីពង្រឹង និងបង្កើនប្រសិទ្ធភាពនៃកិច្ចគាំពារបរិស្ថាន ការអភិរក្ស ការគ្រប់គ្រង និងការស្តារឡើងវិញនូវធនធានធម្មជាតិ ជីវៈចម្រុះ បេតិកភណ្ឌវប្បធម៌ និងការរស់នៅដោយចីរភាព។

គន្លឹះទី១: បទបញ្ញត្តិទូទៅ

❖គោលដៅ៖ ក្រមនេះ មានគោលដៅដូចខាងក្រោម៖

- អភិរក្ស ការពារ គ្រប់គ្រង និងស្តារឡើងវិញ នូវធនធានធម្មជាតិ ជីវៈចម្រុះ និងសេវាប្រព័ន្ធអេកូឡូស៊ី
- លើកកម្ពស់ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ប្រសិទ្ធភាពថាមពល ការអភិវឌ្ឍបៃតង និងការប្រើប្រាស់ធនធាន និងការប្រើប្រាស់ថាមដោយចីរភាព
- ថែរក្សា ការពារ អភិរក្ស ស្តារឡើងវិញ និងលើកកម្ពស់បេតិកភណ្ឌវប្បធម៌ជាតិគ្រប់ប្រភេទទាំងអស់ ទាំងរូបី និងអរូបី ទាំងបេតិកភណ្ឌធម្មជាតិ និងបេតិកភណ្ឌវប្បធម៌
- លើកកម្ពស់សុខុមាលភាពសង្គម
- លើកកម្ពស់ និងការពារសិទ្ធិបុគ្គលគ្រប់រូប និងសិទ្ធិសមូហភាពរបស់ជនជាតិដើមភាគតិច
- បញ្ចូលការយកចិត្តទុកដាក់អំពីបរិស្ថាន និងធនធានធម្មជាតិ ទៅក្នុងការរៀបចំផែនការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ទាក់ទិននឹងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម
- និងពង្រឹងការអនុវត្តលិខិតុបករណ៍អន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាជាភាគី។

គន្លឹះទី១: បទបញ្ញត្តិទូទៅ

❖វិសាលភាព៖

ក្រមនេះ ត្រូវអនុវត្តចំពោះរាជរដ្ឋាភិបាលកម្ពុជា អាជ្ញាធរមូលដ្ឋាន មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ប្រជាពលរដ្ឋកម្ពុជា ជនបរទេសដែលរស់នៅក្នុងប្រទេសកម្ពុជា ក្រុមហ៊ុនឯកជន សមាគម និងអង្គការសង្គមស៊ីវិលគ្រប់ប្រភេទ និងនីតិបុគ្គលនានា ទាំងក្រុមហ៊ុនរដ្ឋ និងក្រុមហ៊ុនឯកជន ដែលការធ្វើសកម្មភាព ការពុំធ្វើសកម្មភាព គោលនយោបាយ និង/ឬ ផែនការសកម្មភាព អាចបង្កផលប៉ះពាល់ដល់បរិស្ថាន ធនធានធម្មជាតិ និងបេតិកភណ្ឌ ដែលឋិតក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

ក្រមនេះ អនុវត្តចំពោះសកម្មភាព និង/ឬ ការមិនធ្វើសកម្មភាពណាមួយដែលអាចបង្កផលប៉ះពាល់ដល់បរិស្ថាន ធនធានធម្មជាតិ និងបេតិកភណ្ឌរបស់ប្រទេសកម្ពុជា បើទោះបីជាផលប៉ះពាល់ទាំងនេះ កើតចេញពីប្រភពផ្សេងទៀត ដែលឋិតនៅខាងក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជាយ៉ាងណាក៏ដោយ។

គន្លឹះទី១: បទបញ្ញត្តិទូទៅ

II. ការចូលរួមជាសាធារណៈ

ការចូលរួមជាសាធារណៈ គឺជាលក្ខខណ្ឌតម្រូវមួយ ដើម្បីធានាយ៉ាងណាឱ្យអភិបាលកិច្ចធនធានធម្មជាតិ និងបរិស្ថានរបស់យើងអាចប្រព្រឹត្តទៅប្រកបដោយស័ក្តិសិទ្ធ និងប្រសិទ្ធភាព។ ការចូលរួមជាសាធារណៈ អាចធ្វើឡើងក្នុងរូបភាពដូចខាងក្រោម៖

- ការរាយការណ៍ទៅកាន់អាជ្ញាធរមានសមត្ថកិច្ច និង/ឬការផ្សព្វផ្សាយព័ត៌មាន និង/ឬការសម្រេចចិត្តនានា ដែលអាចមានផលប៉ះពាល់លើបរិស្ថាន និងធនធានធម្មជាតិ
- ការលើកជាសំណួរ ការសុំឱ្យមានការបញ្ជាក់ ការបដិសេធ ក៏ដូចជាការចូលរួមក្នុងកិច្ចប្រជុំនានា ដើម្បីធ្វើការពិភាក្សា និង/ឬចេញសេចក្តីសម្រេចចិត្ត ដែលអាចប៉ះពាល់លើបរិស្ថាន និងធនធានធម្មជាតិ
- ការដាក់ពាក្យបណ្តឹង ឬការជំទាស់ទៅនឹងសកម្មភាព ឬការសម្រេចចិត្តនានា ដោយប្រើប្រាស់យន្តការសម្រាប់ដោះស្រាយជម្លោះ ដែលពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ

គន្លឹះទី១: បទបញ្ញត្តិទូទៅ

III. សិទ្ធិទទួលបានព័ត៌មាន

ជនណាក៏ដោយ សុទ្ធតែមានសិទ្ធិទទួលបានព័ត៌មាន ឬស្នើសុំព័ត៌មានពីរដ្ឋាភិបាល ឬម្ចាស់គម្រោង ពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ ដោយក្រមនេះបានដាក់ចេញយ៉ាងជាក់ច្បាស់នូវប្បញ្ញត្តិជាច្រើន ដែលចាំបាច់ ដើម្បីធានាឱ្យបាននូវ "សិទ្ធិទទួលបានព័ត៌មាន"។

ព័ត៌មាននេះរួមមាន៖

- ស្ថានភាពនៃសមាសភាគនានានៃបរិស្ថាន ដូចជា ខ្យល់ និងបរិយាកាស ទឹក និងដីជាដើម
- កត្តានានា ដែលអាចប៉ះពាល់ដល់ធាតុផ្សំទាំងឡាយនៃបរិស្ថាន ដូចជាសារធាតុ ថាមពល សម្លេង សំណល់ និងការបំភាយឧស្ម័នជាដើម
- វិធានការដែលប៉ះពាល់ដល់ស្ថានភាពបរិស្ថាន ដូចជា គោលនយោបាយ ច្បាប់ ផែនការ កម្មវិធី និងសកម្មភាពនានា
- ពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ
- ទំនាក់ទំនងជាលក្ខណៈបុគ្គល និងធុរកិច្ចរបស់ម្ចាស់គម្រោង ជាមួយសហគ្រាសពាណិជ្ជកម្ម ឬស្ថាប័នផ្តល់កម្ចីជាតិ ឬអន្តរជាតិដទៃទៀត ដែលគាំទ្រដល់គម្រោង តាមរយៈកម្ចីឥណទាន ឬជំនួយផ្នែកបច្ចេកទេស
- ព័ត៌មានទាំងឡាយ អំពីហានិភ័យបរិស្ថាន និងអាកាសធាតុ ដែលប៉ះពាល់ដល់បរិស្ថាននៃសុខភាព និងសុវត្ថិភាពរបស់មនុស្ស ទីតាំងបេតិកភណ្ឌវប្បធម៌ និងសំណង់នានា។

គន្លឹះទី២: ការវាយតម្លៃបរិស្ថាន

ដើម្បីគ្រប់គ្រងធនធានធម្មជាតិរបស់ជាតិឱ្យកាន់តែប្រសើរប្រកបដោយចីរភាព និងសម្រេចបាននូវសុភានុពលនានា ដែលអាចផ្តល់ដោយ និង/ឬបង្កើតចេញពីធនធានធម្មជាតិរបស់យើង ដូចជា ប្រព័ន្ធបរិស្ថាន ជីវៈចម្រុះ ស្ថានភាពភូមិសាស្ត្រ និងអាកាសធាតុ ធនធានទឹក និងធនធានរ៉ែ ដែលក្រមនេះបានដាក់ចេញនូវឧបករណ៍វិទ្យាសាស្ត្រជាច្រើន សម្រាប់គាំទ្រឱ្យមានការរៀបចំគោលនយោបាយ ផែនការសកម្មភាពអភិវឌ្ឍន៍ និងការសម្រេចចិត្តផ្សេងទៀត ផ្អែកតាមព័ត៌មានត្រឹមត្រូវ។

I. ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាយុទ្ធសាស្ត្រ

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាយុទ្ធសាស្ត្រ ត្រូវបានអនុវត្តចំពោះគោលនយោបាយ ផែនការ និងផែនការសកម្មភាពអភិវឌ្ឍន៍ក្នុងវិស័យអាទិភាព ដែលត្រូវបានកំណត់ដោយរាជរដ្ឋាភិបាល ដូចជា ឧស្សាហកម្ម រ៉ែ ថាមពល កសិកម្ម ទេសចរណ៍ ហេដ្ឋារចនាសម្ព័ន្ធ និងទូរគមនាគមន៍ ព្រមទាំងវិស័យផ្សេងទៀត ទៅតាមការចាំបាច់។ ការវាយតម្លៃនេះជួយឱ្យអ្នកតាក់តែងគោលនយោបាយ និង/ឬ ប្បញ្ញត្តិករ និងតួអង្គពាក់ព័ន្ធ អាចប្រមើលមើលដឹងពីការខាតបង់ អត្ថប្រយោជន៍ ការគំរាមកំហែង ឱកាស និងបញ្ហាដទៃទៀត ដែលអាចកើតចេញពីគោលនយោបាយ និង/ឬផែនការសកម្មភាពជាក់លាក់ដែលរាជរដ្ឋាភិបាល និង/ឬក្រសួងចង់រៀបចំ និង/ឬអភិវឌ្ឍ។

គន្លឹះទី២: ការវាយតម្លៃបរិស្ថាន

II. ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (និងសង្គម)

គោលដៅចម្បង គឺដើម្បីវាយតម្លៃលើហេតុប៉ះពាល់វិជ្ជមាន និង/ឬអវិជ្ជមានដែលអាចត្រូវបានកើតចេញពី និង/ឬកើតចេញពីគម្រោងជាក់លាក់ ដែលផ្តួចផ្តើម និង/ឬអភិវឌ្ឍដោយរាជរដ្ឋាភិបាលកម្ពុជា ឬអាជ្ញាធរមូលដ្ឋាន វិនិយោគិន និង/ឬបុគ្គលផ្សេងទៀត ដូចដែលតម្រូវដោយច្បាប់ ដោយប្រើប្រាស់លើការវិភាគលើការខាតបង់ និងអត្ថប្រយោជន៍ ដើម្បីធានាថាសកម្មភាពទាំងឡាយ ដែលបង្កផលប៉ះពាល់ដល់បរិស្ថាន ត្រូវធ្វើឡើងប្រកបដោយការទទួលខុសត្រូវ ស្របតាមច្បាប់បរិស្ថាន និងសេចក្តីណែនាំនានារបស់ព្រះរាជាណាចក្រកម្ពុជា ពាក់ព័ន្ធនឹងផែនការកាត់បន្ថយផលប៉ះពាល់បរិស្ថាន។

គន្លឹះទី២: ការវាយតម្លៃបរិស្ថាន

III. ឧបករណ៍បន្ថែម

ក្រមនេះ បានដាក់ចេញនូវឧបករណ៍គាំទ្រដល់ការសម្រេចចិត្តបន្ថែមទៀត ដូចជា ការវាយតម្លៃហេតុប៉ះពាល់លើសុខភាព ការវាយតម្លៃហានិភ័យ ការវាយតម្លៃហេតុប៉ះពាលបរិស្ថានជាបណ្តុំ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដោយបញ្ចូលការប្រែប្រួលអាកាសធាតុ រួមនឹងការតម្រូវយ៉ាងជាក់ច្បាស់ឱ្យមានការចូលរួមជាសាធារណៈ និងការដាក់ចេញនូវនីតិវិធី ដើម្បីផ្តល់លទ្ធភាពឱ្យសាធារណៈជនដែលងាយរងគ្រោះ ដូចជា កុមារ ស្ត្រី និងជនដែលរងផលប៉ះពាល់អាចចូលរួមយ៉ាងមានប្រសិទ្ធភាព និងដោយបានទទួលព័ត៌មានត្រឹមត្រូវ ក្នុងការរៀបចំ និង/ឬ លើកស្នើនូវជម្រើសផ្សេងៗ សម្រាប់កាត់បន្ថយផលប៉ះពាល់នានា ដែលកើតឡើងដោយសារគម្រោង។

គន្លឹះទី៣:ការគ្រប់គ្រងបរិស្ថាន និងយន្តការចីរភាព

I. គោលបំណង និងគោលដៅ

ក្រមនេះបានទទួលស្គាល់នូវគោលនយោបាយ និងក្របខ័ណ្ឌគាំទ្រជាច្រើន ដែលរួមគ្នាបង្កើតបានជា "យន្តការចីរភាព" ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ។

យន្តការចីរភាពនេះ មានជាអាទិ៍៖

- ក្របខ័ណ្ឌគ្រប់គ្រងគ្រោះមហន្តរាយ និងហានិភ័យ
- ការរៀបចំនូវគោលនយោបាយចីរភាព និងផែនការសកម្មភាពជាយុទ្ធសាស្ត្រសម្រាប់គាំទ្រដែលអាចឆ្លើយតប ផ្តោតការយកចិត្តទុកដាក់លើការអភិរក្សជីវៈចម្រុះនៅខាងក្នុង និងខាងក្រៅតំបន់ការពារ ការបំពុលបរិស្ថាន និងក្របខ័ណ្ឌគ្រប់គ្រងជីវៈចម្រុះ។
- គោលនយោបាយ និងផែនការសកម្មភាពស្តីពីភាពធន និងការបន្សាំទៅនឹងអាកាសធាតុ រួមជាមួយនឹងក្របខ័ណ្ឌហិរញ្ញប្បទានបរិស្ថានគ្រប់ជ្រុងជ្រោយ ដែលមានបញ្ចូលសមាសភាគខាងក្រោម៖ មូលនិធិអាកាសធាតុបៃតបៃពណ៌ ការវិនិយោគលើការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ការវិនិយោគបៃបអាកាសធាតុមេត្រី ដែលអនុវត្តដោយវិស័យឯកជន ការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ និងទីផ្សារសន្និធិស្តុកកាបូន។
- និងគំនិតផ្តួចផ្តើម និងគោលនយោបាយ ផលិតកម្ម និងការប្រើប្រាស់ប្រកបដោយចីរភាព ដូចជាលទ្ធកម្មបៃតង ការដាក់ស្លាកសម្គាល់ផលិតផលដែលមិនបង្កផលប៉ះពាល់ដល់បរិស្ថាន ការវាយតម្លៃលើប្រសិទ្ធិភាពធនធាន អភិក្រមផ្តែកតាមការទទួលខុសត្រូវរបស់អ្នកផលិត ទេសចរណ៍ប្រកបដោយចីរភាព ថាមពលប្រកបដោយចីរភាព ប្រសិទ្ធភាពថាមពល និងឧស្សាហកម្មនិស្សារណកម្ម ដែលប្រកបដោយការទទួលខុសត្រូវ។
- ក៏ដូចជា ការរៀបចំផែនការប្រើប្រាស់ដីធ្លីបៃបបរិស្ថានមេត្រី និងទីក្រុងប្រកបដោយចីរភាព។

គន្លឹះទី៣:ការគ្រប់គ្រងបរិស្ថាន និងយន្តការចីរភាព

II. ចីរភាព និងការប្រែប្រួលអាកាសធាតុ

តើរដ្ឋាភិបាលកំពុងធ្វើអ្វីខ្លះ ដើម្បីឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ?

- ការបង្កើតក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- ការបញ្ចូលការពិចារណាពីការប្រែប្រួលអាកាសធាតុ ទៅក្នុងផែនការ និងយុទ្ធសាស្ត្រជាតិ
- ការបញ្ចូល និងការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ ទៅក្នុងថវិកាជាតិ តាមរយៈក្របខ័ណ្ឌហិរញ្ញប្បទាន និងផែនការសកម្មភាព ដែលអនុវត្តដោយក្រសួង និងស្ថាប័ននានា របស់រដ្ឋាភិបាល
- ការវាយតម្លៃលើភាពងាយរងគ្រោះនៃប្រព័ន្ធជីវសាស្ត្រ សង្គម និងសេដ្ឋកិច្ច ដោយសារការប្រែប្រួលអាកាសធាតុ
- ការរៀបចំហេដ្ឋរចនាសម្ព័ន្ធ សម្រាប់វិស័យកសិកម្ម ជលផល ដឹកជញ្ជូន និងថាមពល ដែលបំភាយជាតិកាបូនទាប និងធន់ នឹងអាកាសធាតុ
- ការកែលម្អប្រព័ន្ធប្រកាសអាសន្នជាមុន
- ការលើកកម្ពស់ការអនុវត្តមុខរបរចិញ្ចឹមជីវិតប្រកបចីរភាព
- ការបង្កើនលទ្ធភាពទទួលបានថាមពល ទឹក ប្រព័ន្ធគមនាគមន៍ និងសេវាអនាម័យក្នុងតម្លៃសមរម្យ
- ការអភិវឌ្ឍមធ្យោបាយដឹកជញ្ជូនសាធារណៈ និងមធ្យោបាយដឹកជញ្ជូនដោយបំភាយកាបូនទាប
- ការជំរុញឱ្យមានការស្រាវជ្រាវ និងនវានុវត្តន៍ និងការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ និងបច្ចេកវិទ្យាដែលពាក់ព័ន្ធ។

គន្លឹះទី៣:ការគ្រប់គ្រងបរិស្ថាន និងយន្តការចីរភាព

III. ការគ្រប់គ្រងគ្រោះមហន្តរាយ

ស្ថាប័នជាតិគ្រប់គ្រងគ្រោះមហន្តរាយ នឹងរៀបចំផែនការកាត់បន្ថយគ្រោះមហន្តរាយ និងផែនការត្រៀមបម្រុង ដើម្បីកាត់បន្ថយផលប៉ះពាល់ដែលបង្កឡើងដោយសារគ្រោះមហន្តរាយធម្មជាតិ និងមនុស្ស។ នឹងមានការយកចិត្តទុកដាក់សហការជាមួយនឹងអាជ្ញាធរមូលដ្ឋាន និងតួអង្គពាក់ព័ន្ធដទៃទៀត ដើម្បីកសាងភាពធន់ទៅនឹងគ្រោះមហន្តរាយ ដូចជា ការបន្សាំទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុជាដើម។

គន្លឹះទី៣:ការគ្រប់គ្រងបរិស្ថាន និងយន្តការចីរភាព

IV. ទេសចរណ៍ប្រកបដោយចីរភាព

ក្រមនេះគូសបញ្ជាក់យ៉ាងច្បាស់ថា ការអភិវឌ្ឍវិស័យទេសចរណ៍ អាចចាត់ទុកថា មាន "ចីរភាព" បានតែក្នុងករណីដែលការអភិវឌ្ឍនេះ អាចបំពេញតាមលក្ខណៈវិនិច្ឆ័យ ដូចតទៅតែប៉ុណ្ណោះ៖

- ការគ្រប់គ្រង ត្រូវគោរពឱ្យបានពេញលេញទៅតាមលក្ខខណ្ឌ ដែលត្រូវបានដាក់ចេញក្នុងលិខិតបទដ្ឋានគតិយុត្ត ដែលចេញដោយក្រុមប្រឹក្សាជាតិអភិវឌ្ឍដោយចីរភាព និងក្រសួងស្ថាប័នពាក់ព័ន្ធ
- ការប្រើប្រាស់ធនធាន ត្រូវមានប្រសិទ្ធភាព ទៅតាមស្តង់ដារ ដែលកំណត់ដោយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- ការគ្រប់គ្រង និងប្រតិបត្តិការសកម្មភាពទេសចរណ៍ ត្រូវធ្វើឡើងស្របតាមប្បញ្ញត្តិដែលចែងក្នុងក្រមនេះ (គន្លឹទី ៤ មាតិកាទី ៣) ដើម្បីធានាយ៉ាងណាឱ្យសកម្មភាពដែលធ្វើឡើងក្នុងតំបន់ការពារ ឬច្រករបៀងជីវចម្រុះ និងបង្កើនបរិមាណធនធានធម្មជាតិ ដើម្បីប្រយោជន៍ជាតិ សង្គម និងសេដ្ឋកិច្ច និងជួយដល់ការអភិរក្ស និងការស្តារឡើងវិញនូវជីវចម្រុះ ប្រព័ន្ធអេកូឡូស៊ី ក៏ដូចជាការលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍ និងការអភិវឌ្ឍប្រកបដោយចីរភាពរយៈពេលវែង។
- ការបង្កើតចំណូល និងការប្រើប្រាស់ចំណូល ត្រូវគ្រប់គ្រងស្របតាមវិធាន និងគោលនយោបាយ ដែលដាក់ចេញដោយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។

គន្លឹះទី៣:ការគ្រប់គ្រងបរិស្ថាន និងយន្តការចីរភាព

V. ការរៀបចំផែនការប្រើប្រាស់ដីធ្លី និងទីក្រុងប្រកបដោយចីរភាព

ផែនការមេស្តីពីការប្រើប្រាស់ដីធ្លីបែបមេត្រីបរិស្ថាន ត្រូវបំពេញរាល់លក្ខខណ្ឌទាំងអស់ដែលត្រូវបានដាក់ចេញក្នុងក្រមនេះ។ ដូច្នេះ ផែនការនេះត្រូវ៖

- កើតចេញពីការពិគ្រោះយោបល់ជាសាធារណៈជាមួយគ្រប់តួអង្គពាក់ព័ន្ធទាំងអស់ អំពីផែនការមេស្តីពីការប្រើប្រាស់ដីធ្លីដែលស្នើឡើង
- ប្រើប្រាស់ព័ត៌មានវិទ្យាសាស្ត្រលម្អិតល្អបំផុត ដែលអាចរកបាន និងទិន្នន័យទីតាំងពាក់ព័ន្ធនឹងធនធានដីធ្លី ការប្រើប្រាស់ដីធ្លីនាពេលបច្ចុប្បន្ន ហេដ្ឋរចនាសម្ព័ន្ធរូបវន្ត ប្រជាជនដែលរស់នៅជុំវិញ វប្បធម៌ និងសិទ្ធិប្រើប្រាស់ដីធ្លីជាដើម
- ប្រើប្រាស់បច្ចេកវិទ្យាល្អបំផុតដែលអាចរកបាន ដើម្បីរៀបចំផែនទីទីតាំងភូមិសាស្ត្ររួម សម្រាប់គ្រប់តំបន់ទេសភាពទាំងអស់
- ឆ្លើយតបទៅនឹងសំណួរថាតើផែនការមេស្តីពីការប្រើប្រាស់ដីធ្លីដែលស្នើឡើងនេះ អាចបង្កផលប៉ះពាល់ដល់ការបំភាយឧស្ម័នផ្ទះកញ្ចក់ និងអាងកាបូនដោយរបៀបណា
- ឆ្លើយតបចំពោះផលប៉ះពាល់ដែលការប្រែប្រួលអាកាសធាតុ អាចបង្កឡើងលើការអនុវត្តផែនការមេស្តីពីការប្រើប្រាស់ដីធ្លី ដូចជាការទប់ស្កាត់ទឹកជំនន់ជាដើម
- ឆ្លើយតបចំពោះផលប៉ះពាល់ដែលអាចកើតមានលើបរិស្ថាន
- ផ្តោតការយកចិត្តទុកដាក់លើវិធានការការពារបេតិកភណ្ឌវប្បធម៌ ឬធនធានធម្មជាតិ ដែលបិតនៅក្នុង ឬនៅជិតទីកន្លែងប្រើប្រាស់ដីធ្លីដែលស្នើឡើង
- កំណត់ភាគរយផ្ទៃដីសម្រាប់ទុកជាលំហបៃតង

គន្លឹះទី៣:ការគ្រប់គ្រងបរិស្ថាន និងយន្តការចីរភាព

VI. ថាមពលបៃតង

ដើម្បីជំរុញលើកកម្ពស់ទីក្រុងបៃបបរិស្ថានមេត្រី និងសង្គមដែលបំភាយកាបូនទាប ហើយក្នុងពេលជាមួយគ្នា នៅតែអាចលើកកម្ពស់សន្តិសុខថាមពលរបស់ជាតិ ក្រមនេះក៏បានដាក់ចេញនូវក្របខ័ណ្ឌគតិយុត្ត និងក្របខ័ណ្ឌស្ថាប័នជាច្រើន (ក្នុងគន្លឹះទី ៣ មាតិកាទី ៧) ដើម្បីគាំទ្រដល់ការអភិវឌ្ឍថាមពលបៃតង។

គន្លឹះទី៣:ការគ្រប់គ្រងបរិស្ថាន និងយន្តការចីរភាព

VII. ឧស្សាហកម្មនិស្សារណកម្មដែលប្រកបដោយការទទួលខុសត្រូវ

ពាក់ព័ន្ធនឹងឧស្សាហម្មនិស្សារណកម្ម ដូចជា ការរុករកប្រេង ឧស្ម័ន រ៉ែ លោហធាតុ វត្ថុធាតុភូគព្ភវិទ្យា និងធនធានដទៃទៀតក្នុងព្រះរាជាណាចក្រកម្ពុជា ក្រសួងទទួលបន្ទុករ៉ែ ត្រូវធ្វើការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ សម្រាប់សកម្មភាពក្នុងវិស័យនេះ។

ការវាយតម្លៃទាំងនេះ នឹងផ្តល់នូវក្របខ័ណ្ឌនូវម្ចាស់គម្រោងដាក់បញ្ចូលទៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃការរៀបចំគម្រោង នូវវិធានការបញ្ចៀស និងកាត់បន្ថយការគំរាមកំហែង ចំពោះតំបន់ ដែលមានតម្លៃអភិរក្សខ្ពស់។

គន្លឹះទី៣:ការគ្រប់គ្រងបរិស្ថាន និងយន្តការចីរភាព

VIII. ផលិតកម្ម និងការប្រើប្រាស់ដោយចីរភាព

ក្រុមប្រឹក្សាជាតិអភិវឌ្ឍប្រកបដោយចីរភាព សហការជាមួយនឹងក្រសួងបរិស្ថាន ក៏នឹងរៀបចំកម្មវិធីផ្តោតលើផលិតកម្ម និងប្រើប្រាស់ដោយចីរភាព ដូចមានចែងក្នុងគន្លឹះទី ៣ មាតិកាទី ៤ ផងដែរ ដើម្បី៖

- បង្កើនតម្រូវការ និងការផ្គត់ផ្គង់ផលិតផលដែលកាន់តែមានមេត្រីភាពចំពោះបរិស្ថាន
- កែលម្អបរិស្ថាននៅកន្លែងផលិតផលិតផល
- គាំទ្រដល់ការអនុវត្តល្អសម្រាប់ផលិតកម្មបរិស្ថានមេត្រី
- ជំរុញឱ្យអ្នកផលិតទទួលខុសត្រូវលើសំណល់ដែលបង្កើតដោយប្រើប្រាស់ប
- លើកទឹកចិត្តឱ្យមានការដាក់ស្លាកសម្គាល់ដោយស្ម័គ្រចិត្តលើផលិតផល និងសេវាកម្មនានា ដោយបង្ហាញព័ត៌មានអំពីបន្ទុកបរិស្ថាន ដូចជា សារធាតុនៅក្នុងផលិតផល ឬរបៀបផលិតផល និងសំណល់ជាដើម
- ដាក់ចេញនូវឧបសគ្គ និងផ្តល់ការគាំទ្រឱ្យអ្នកផ្គត់ផ្គង់ប្រើប្រាស់ផលិតផលមេត្រីបរិស្ថាន។

គន្លឹះទី៣:ការគ្រប់គ្រងបរិស្ថាន និងយន្តការចីរភាព

IX. ការបំភាយឧស្ម័នផ្ទះកញ្ចក់ និងគុណភាពខ្យល់

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព នឹងសហការយ៉ាងជិតស្និទ្ធជាមួយនឹងក្រសួងបរិស្ថាន និងក្រសួងពាក់ព័ន្ធ ដើម្បីរៀបចំក្របខ័ណ្ឌមូលនិធិអាកាសធាតុ ជំរុញឱ្យមានការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ រក្សា និងធ្វើបច្ចុប្បន្នភាពទិន្នន័យទាំងអស់ ពាក់ព័ន្ធនឹងការធ្វើតេស្តគុណភាពខ្យល់ ដើម្បីវាយគុណភាពខ្យល់។

គន្លឹះទី៤:ការគ្រប់គ្រងធនធានធម្មជាតិ ដោយចីរភាព

I. ប្រព័ន្ធតំបន់ការពារធម្មជាតិ

រៀបចំតួនាទីការកិច្ចរបស់តួអង្គពាក់ព័ន្ធនីមួយៗ ជាអាទិ៍ក្រសួងបរិស្ថាន អាជ្ញាធរមូលដ្ឋាន និងសហគមន៍មូលដ្ឋាន។ ក្រមនេះ បានធ្វើការកំណត់ពីក្របខ័ណ្ឌស្ថាប័ន និងក្របខ័ណ្ឌច្បាប់ ដើម្បីកែលម្អការគ្រប់គ្រងធនធានធម្មជាតិ ហើយស្របពេលជាមួយគ្នា លើកកម្ពស់សេវាប្រព័ន្ធអេកូឡូស៊ី ដោយអនុញ្ញាតឱ្យក្រសួបរិស្ថាន និង/ឬ អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដូចជាអាជ្ញាធរមូលដ្ឋានជាដើម រៀបចំបង្កើតតំបន់ការពារប្រភេទផ្សេងៗ បែងចែកតំបន់ និង/ឬបង្កើតតំបន់ការពារពិសេស ដូចជា តំបន់ការពារតាមតំបន់ តំបន់បេតិកភណ្ឌជាដើម។

II. សត្វព្រៃ

ក្រសួងបរិស្ថាន ទទួលខុសត្រូវការពារ អភិរក្ស និងគ្រប់គ្រងសត្វព្រៃ និងត្រូវសហការជាមួយនឹងក្រសួង និងស្ថាប័នពាក់ព័ន្ធដទៃទៀត ដើម្បីទប់ស្កាត់បទល្មើស និងការបំផ្លិចបំផ្លាញជម្រក ព្រមទាំងរុក្ខជាតិ និងសត្វក្នុងព្រះរាជាណាចក្រកម្ពុជា។

គន្លឹះទី៤:ការគ្រប់គ្រងធនធានធម្មជាតិ ដោយចីរភាព

III. ព្រៃឈើ និងតំបន់វាលទំនាប

ព្រៃឈើ និងតំបន់វាលទំនាប ផ្តល់នូវដែនជម្រក សម្រាប់រុក្ខជាតិ និងសត្វព្រៃកម្រ ក៏ដូចជាតំបន់ដែលមានសារៈសំខាន់ផ្នែកវប្បធម៌ចំពោះជនជាតិដើមភាគតិច។ ផ្ទៃដីជាង XX ភាគរយនៃប្រទេសកម្ពុជា គ្របដណ្តប់ដោយព្រៃ ដែលមានចាប់ពីព្រៃក្រាស់ឃ្មឹក រហូតដល់ប្រព័ន្ធអេកូឡូស៊ីដែលមានលក្ខណៈពិសេសនៅតាមមាត់បឹង។ ក្រសួង X នឹងរៀបចំបញ្ជីសារពើភណ្ឌបង្ហាញពីស្ថានភាពព្រៃឈើនៅក្នុងប្រទេសនេះ។

IV. តំបន់ឆ្នេរ

ឆ្នេររបស់ប្រទេសកម្ពុជា លាតសន្ធឹងចម្ងាយ X គីឡូម៉ែត្រ។ ការការពារ និងការអភិរក្សាតំបន់ឆ្នេរ មានសារៈសំខាន់យ៉ាងខ្លាំងចំពោះសុខុមាលភាពសត្វព្រៃ និងប្រជាពលរដ្ឋក្នុងមូលដ្ឋាន ជាពិសេសឧស្សាហកម្មទេសចរណ៍។

គណៈកម្មាធិការជាតិអភិវឌ្ឍន៍ និងគ្រប់គ្រងតំបន់ឆ្នេរ ទទួលខុសត្រូវលើសកម្មភាព និងការអភិវឌ្ឍនានា ដែលបង្កផលប៉ះពាល់ដល់តំបន់ឆ្នេរ។

គន្លឹះទី៤:ការគ្រប់គ្រងធនធានធម្មជាតិ ដោយចីរភាព

V. មច្ឆាទឹកសមុទ្រ

គោលនយោបាយជាតិស្តីពីវិស័យជលផល ផ្តោតការយកចិត្តទុកដាក់លើការធានាចីរភាពផលចាប់ នៃការធ្វើនេសាទទឹកសាប ក្នុងគោលបំណងគ្រប់គ្រង និងអភិរក្សធនធានវារីជាតិ ដើម្បីផ្គត់ផ្គង់អាហារឱ្យបានគ្រប់គ្រងដល់ប្រជាពលរដ្ឋគ្រប់រូប។ នេះ គឺជាទំនួលខុសត្រូវរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយការងារមួយក្នុងចំណោមការងារសំខាន់ៗ គឺការបង្កើតសហគមន៍នេសាទ ដើម្បីផ្តល់អំណាចឱ្យប្រជាពលរដ្ឋមូលដ្ឋាន ធ្វើការគ្រប់គ្រង និងអភិរក្សធនធានជលផលរបស់ពួកគេ។

VI. ធនធានទឹក

ក្រសួង X នឹងរៀបចំផែនការបែងចែក និងគ្រប់គ្រងទឹកប្រកបដោយចីរភាព ដើម្បីបំពេញតម្រូវការទឹកនាពេលអនាគត របស់ព្រះរាជាណាចក្រកម្ពុជា តាមរយៈការដាក់ចេញនូវផែនការជាតិយុទ្ធសាស្ត្រធនធានទឹក និងផែនការគ្រប់គ្រងធនធានទឹកងតំបន់អាងទន្លេ។

គន្លឹះទី៥:ការអភិរក្ស និងការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ និងធម្មជាតិបេតិកភណ្ឌវប្បធម៌

I. បេតិកភណ្ឌវប្បធម៌

ប្រទេសកម្ពុជា ជាប្រទេសដែលសម្បូរដែលបេតិកភណ្ឌវប្បធម៌ ដូចជា ប្រាង្គប្រាសាទបុរាណ សិលាចារឹកប្រវត្តិសាស្ត្រ និងបច្ចេកទេសកសិកម្មបែបប្រពៃណី។ ដើម្បីការពារ និងអភិរក្សបេតិកភណ្ឌនេះ ក្រសួង X នឹងរៀបចំផែនការជាតិគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ និងបង្កើតតំបន់ការពារបេតិកភណ្ឌប្បធម៌។

II. បេតិកភណ្ឌធម្មជាតិ

បេតិកភណ្ឌធម្មជាតិសំដៅលើដែនគោក និងដែនទឹក ដែលបង្កបង្កើតឡើង ដោយសារកត្តារូបសាស្ត្រ, ភូគព្ភសាស្ត្រ ជីវសាស្ត្រ ឬដោយមនុស្ស ដែលឆ្លុះបញ្ចាំងពីដំណាក់កាលវិវត្តន៍នៃធម្មជាតិ ឬអរិយធម៌ នៅមានតម្លៃប្រវត្តិសាស្ត្រ សិល្បៈ, វិទ្យាសាស្ត្រ ឬសោភ័ណភាព។ ក្រមបរិស្ថាន និងច្បាប់ នៃព្រះរាជាណាចក្រកម្ពុជានឹងធ្វើការការពារបេតិកភណ្ឌធម្មជាតិរបស់ប្រទេសនេះ។

គន្លឹះទី៦:ការគ្រប់គ្រងសំណល់ និងការត្រួតពិនិត្យការបំពុលបរិស្ថាន

គន្លឹះនេះ ត្រូវបានរៀបចំឡើង ដើម្បីសម្អាត និងរក្សាផ្ទៃះសម្បែងសហគមន៍ ភូមិដ្ឋាន ទីក្រុង និងប្រទេសរបស់យើងឲ្យនៅស្អាតស្រស់បំព្រង និងមានសុវត្ថិភាព សម្រាប់រស់នៅ ស្នាក់នៅ និងធ្វើការ និងពុំមានការបំពុលបរិស្ថាន។ គន្លឹះនេះត្រូវបានរៀបចំឡើង ដើម្បីសម្អាត និងរក្សាផ្ទៃះសម្បែងសហគមន៍ ភូមិដ្ឋាន ទីក្រុង និងប្រទេសរបស់យើងឲ្យនៅស្អាតស្រស់បំព្រង និងមានសុវត្ថិភាព សម្រាប់រស់នៅ ស្នាក់នៅ និងធ្វើការ និងពុំមានការបំពុលបរិស្ថាន។

ដើម្បីសម្រេចគោលបំណងនេះ និងដើម្បីការពារ និងលើកម្ពស់គុណភាពបរិស្ថានរបស់យើងប្រកបដោយប្រសិទ្ធភាព ដើម្បីឲ្យដីបន្តមានជីជាតិ បរិយាកាស ខ្យល់ និងទឹកស្អាត និងមានសុវត្ថភាព (ដូចជាទន្លេ បឹង ទឹកលើដីដទៃទៀត ទឹកក្រោមដី និងសមុទ្រជាដើម...) សម្រាប់គ្រប់គ្នា (មនុស្ស ជីវចម្រុះ រុក្ខជាតិ និងសត្វ) ក្រមនេះប្រើប្រាស់គោលការណ៍វិភាគឬសគល់ និងអភិក្រមគ្រប់ជ្រុងជ្រោយ ដើម្បីគ្រប់គ្រងរាល់សំណល់គ្រប់ប្រភេទ (រឹង និងរាវ) និងធ្វើការត្រួតពិនិត្យការបំពុលបរិស្ថានពីគ្រប់ប្រភពទាំងអស់។

គន្លឹះទី៦:ការគ្រប់គ្រងសំណល់ និងការត្រួតពិនិត្យការបំពុលបរិស្ថាន

I. ការគ្រប់គ្រងសំណល់

1. ការដាក់ចំណាត់ថ្នាក់សំណល់៖ ជាបុរេលក្ខខណ្ឌសម្រាប់សម្អាត និងរក្សាបរិស្ថាននៅកន្លែងរស់នៅ និងកន្លែងធ្វើការរបស់យើងឲ្យនៅស្អាត និងស្រស់បំព្រងប្រកបដោយប្រសិទ្ធភាព
2. ការកិច្ចរួមសម្រាប់ទាំងអស់គ្នា (ប្រជាពលរដ្ឋ និវាសនជន ភ្ញៀវ និងបុគ្គលដទៃទៀត)
3. ភារកិច្ច និងការទទួលខុសត្រូវសំខាន់ៗរបស់បញ្ញតិករ និងមន្ត្រីអនុវត្តន៍ច្បាប់

II. ការត្រួតពិនិត្យការបំពុលបរិស្ថាន និងការការពារស្រទាប់អូហ្សូន

ការបំពុលបរិស្ថាន មានទម្រង់ដូចតទៅ៖ ១)ការបំពុលទឹក, ២)ការបំពុលដី, ៣)ការបំពុលខ្យល់, ៤)ការបំពុលដោយសំឡេងរំខាន និងរំញ័រ (ឬការរំខាន) និង ៥)ការបំពុលដោយរូបភាព។ ការបំពុលអាចកើតចេញពីការគ្រប់គ្រងសំណល់ពុំបានសមស្រប ឬពីការធ្វើសកម្មភាព ឬការពុំធ្វើសកម្មភាពណាមួយ។

គន្លឹះទី៦:ការគ្រប់គ្រងសំណល់ និងការត្រួតពិនិត្យការបំពុលបរិស្ថាន

II. ការត្រួតពិនិត្យការបំពុលបរិស្ថាន និងការការពារស្រទាប់អូហ្សូន (ត)

1. យន្តការរួមជាច្រើន ដែលអាចយកមកអនុវត្តចំពោះការគ្រប់គ្រងសំណល់ ការផ្លាស់ទីផលិតផល និងការប្រើប្រាស់សារធាតុគីមី និងការត្រួតពិនិត្យការបំពុលបរិស្ថានជាទូទៅ
2. របបជាប់លាប់ និងយន្តការគាំទ្រជាច្រើន ត្រូវបានបង្កើតឡើង ដើម្បីឆ្លើយតបចំពោះលក្ខណៈពិសេសនៃការបំពុលបរិស្ថានទៅតាមប្រភេទនីមួយៗ
3. ពាក់ព័ន្ធនឹងការត្រួតពិនិត្យកាបំពុលខ្យល់ និងការការពារស្រទាប់អូហ្សូន ក្រមនេះបានបង្កើតនូវរបបសម្រាប់ការបំពុលពីប្រភពពីប្រភពចល័ត (ដូចជាយានយន្ត ទោចក្រយានយន្ត យន្តហោះ...) និងប្រភពអចល័ត (ដូចជារោងចក្រកោជនីយដ្ឋាន តំបន់សេដ្ឋកិច្ចពិសេស)។
4. ការត្រួតពិនិត្យសំឡេងរំខាន និងរំញ័រ។

គន្លឹះទី៧:ការអប់រំ ស្រាវជ្រាវ និងយល់ដឹងពីបរិស្ថាន

ក្រមនេះ ជឿជាក់យ៉ាងមុតមុតមាំថា យើងទាំងអស់គ្នាដែលជាប្រជាពលរដ្ឋកម្ពុជា អាចការពារធនធានធម្មជាតិរបស់យើង(ដូចជាព្រៃឈើ សត្វព្រៃ ដីវាលស្រែ ធនធានដលផល សត្វសមុទ្រ តំបន់ទេសភាព បេតិកភណ្ឌ និងបេតិកភណ្ឌអេកូឡូស៊ីគាំទ្រដទៃទៀត) យ៉ាងល្អប្រសើរប្រកបដោយប្រសិទ្ធភាព និងបង្កើនគុណភាពបរិស្ថានរបស់យើង ដើម្បីជោគជ័យរយៈពេលវែងការរស់នៅ និងការអភិវឌ្ឍប្រកបដោយចីរភាព ប្រសិនបើ និងតែប្រសិនបើយើងទាំងអស់គ្នាអាចអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋរបស់យើងបានល្អប្រសើរតែប៉ុណ្ណោះ។ ការស្វែងយល់ដោយខ្លួនឯង និងការអភិវឌ្ឍខ្លួនឯង រួមនឹងការបន្តស្រាវជ្រាវនិងរិះរកគំនិតច្នៃប្រឌិតថ្មីនឹងជួយធានាជោគជ័យរយៈពេលវែងរបស់យើង ដោយអស់ចំណាយតិចនិងកាន់តែមានប្រសិទ្ធភាព។

គន្លឹះទី៧:ការអប់រំ ស្រាវជ្រាវ និងយល់ដឹងពីបរិស្ថាន

ដើម្បីសម្រេចគោលដៅនេះ យន្តការគាំទ្រសំខាន់ៗចំនួយ៩ត្រូវបានបង្កើតឡើង ក្រោមក្របខណ្ឌនៃច្បាប់នេះ៖

១. នេះជាលើកទី១ ក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ដែលក្រមនេះផ្តល់ការទទួលស្គាល់ជាផ្លូវការដល់តួនាទី និងការទទួលខុសត្រូវរបស់គ្រប់តួអង្គពាក់ព័ន្ធទាំងអស់ ចាប់ពីអាជ្ញាធរថ្នាក់ជាតិ និងអាជ្ញាធរ មូលដ្ឋានរហូតដល់សង្គមស៊ីវិលទូទៅ ដូចជាក្រុមហ៊ុនឯកជន អង្គការក្រៅរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍អន្តរជាតិ ដែលកំពុងបំពេញសកម្មភាពអប់រំបរិស្ថាន និងជំរុញផ្សព្វផ្សាយសកម្មភាពដែលមិនបង្កផលប៉ះពាល់ដល់បរិស្ថាន។

២. គោលនយោបាយស្តីពីការអប់រំបរិស្ថានដែលនឹងត្រូវរៀបចំឡើងដោយក្រសួងបរិស្ថានឹងត្រូវបញ្ចូលទៅក្នុងអប់រំផ្លូវការនៅគ្រប់កំរិតថ្នាក់ទាំងអស់ ចាប់ពីការអប់រំកុមារតូច(មត្តេយ្យសិក្សា)រហូតដល់ឧត្តមសិក្សា។

៣. ការអប់រំក្រៅប្រព័ន្ធ ដូចជាយុទ្ធនាការការពារបរិស្ថាន និងការជំរុញផ្សព្វផ្សាយមេត្រីភាពបរិស្ថាន នឹងត្រូវបានលើកទឹកចិត្តឲ្យមានសម្រាប់ទាំងអស់គ្នា សម្រាប់អ្នកជំនាញ និងសារធារណៈជនទូទៅ

គន្លឹះទី៧:ការអប់រំ ស្រាវជ្រាវ និងយល់ដឹងពីបរិស្ថាន

ដើម្បីសម្រេចគោលដៅនេះ យន្តការគាំទ្រសំខាន់ៗចំនួយ៩ត្រូវបានបង្កើតឡើង ក្រោមក្របខណ្ឌនៃច្បាប់នេះ៖ (ត)

៤. នឹងមានការផ្សព្វផ្សាយពីចំណេះដឹង និងជំនាញគ្រប់គ្រងបរិស្ថានដល់មន្ត្រីរាជការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងមានការដាក់ចេញនូវក្របខ័ណ្ឌគាំទ្រ សម្រាប់បង្កើត និងរៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូបង្គោលផ្សេងៗ

៥. គោលនយោបាយផ្តល់រង្វាន់ដល់ពលរដ្ឋឆ្នើម និងក្របខ័ណ្ឌគាំទ្រនានា ត្រូវបានដាក់ឱ្យអនុវត្ត ក្រោមវេទិកាផ្សេងៗ ចាប់ពីសាលាមេត្រីបរិស្ថាន រហូតដល់អាជីវកម្ម និងសហគមន៍មេត្រីបរិស្ថាន រួមនឹងការប្រកួតប្រជែង និងការផ្តល់រង្វាន់ជាច្រើនប្រភេទ

៦. អាជ្ញាធររដ្ឋាភិបាលនៅថ្នាក់ជាតិ និងអាជ្ញាធរមូលដ្ឋានមកពីតាមក្រសួង និងម្ចាស់សហគ្រាសឯកជន ត្រូវធ្វើរបាយការណ៍បរិស្ថានប្រចាំឆ្នាំ ដែលជាផ្នែកមួយនៃការបំពេញភារកិច្ចស្ម័យភាយការណ៍ និងគោរពតាមច្បាប់ដោយខ្លួនឯងរបស់ពួកគេ

គន្លឹះទី៧:ការអប់រំ ស្រាវជ្រាវ និងយល់ដឹងពីបរិស្ថាន

ដើម្បីសម្រេចគោលដៅនេះ យន្តការគាំទ្រសំខាន់ៗចំនួយ៩ត្រូវាបានបង្កើតឡើង ក្រោមក្របខណ្ឌនៃច្បាប់នេះ៖ (ត)

៧. នឹងមានការជំរុញឱ្យមានការស្រាវជ្រាវ និងនវានុវត្តន៍បន្ថែមទៀត ទាំងក្នុងវិស័យឯកជន និងតាមគ្រឹះស្ថានសិក្សាស្រាវជ្រាវ

៨. រចនាសម្ព័ន្ធផ្តល់មូលនិធិ ដូចជាមូលនិធិបរិធនបាលកិច្ចបរិស្ថាន និងទម្រង់មូលនិធិផ្សេងទៀត ដែលត្រូវបានអនុញ្ញាតឱ្យបង្កើតឡើង ដើម្បីជំរុញឱ្យមានការអនុវត្តសកម្មភាពគ្រប់បែបយ៉ាង ដែលរួមចំណែកដល់ការអប់រំ និងបង្កើនការយល់ដឹងអំពីបរិស្ថាន។

៩. នឹងមានបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវ អំពីធនធាន និងបរិស្ថាន ដើម្បីគាំទ្រដល់នវានុវត្តន៍ និងភាពច្នៃប្រឌិតថ្មី ក្នុងវិស័យបច្ចេកវិទ្យាបរិស្ថាន វិទ្យាសាស្ត្រ និងគោលនយោបាយអភិបាលកិច្ចដែលពាក់ព័ន្ធ។

គន្លឹះទី៨:វិធានការសេដ្ឋកិច្ច គណនេយ្យ ប្រាក់កម្រៃ និងមូលនិធិបរិស្ថាន

ក្រោមគន្លឹះនេះ ក្រមបរិស្ថានមិនត្រឹមតែដាក់ចេញនូវវិធានការសេដ្ឋកិច្ច ដើម្បីលើកទឹកចិត្តឱ្យបុគ្គល ម្ចាស់អាជីវកម្ម និងម្ចាស់ឧស្សាហកម្ម ក៏ដូចជាសាជីវកម្មគ្រប់ប្រភេទ និងនីតិបុគ្គលផ្សេងទៀត ដូចជាអង្គការក្រៅរដ្ឋាភិបាល និងសហគមន៍មូលដ្ឋានស្ម័គ្រចិត្តកែប្រែខ្លួនឯង និង/ឬ គោរពច្បាស់ដោយខ្លួនឯង (I) ថែមទាំងបង្កើតនូវកម្មវិធីផ្តល់ហិរញ្ញប្បទានជាច្រើនដែលចាំបាច់ ដើម្បីគាំទ្រដល់សកម្មភាពការពារ និងគាំពារបរិស្ថានបក្របដោយចីរភាព ដូចដែលតម្រូវដោយច្បាប់នេះ (II) ។

គន្លឹះទី៨:វិធានការសេដ្ឋកិច្ច គណនេយ្យ ប្រាក់កម្រៃ និងមូលនិធិបរិស្ថាន

I. វិធានការសេដ្ឋកិច្ច ជាមធ្យោបាយបន្ថែមសម្រាប់ជំរុញឱ្យមានស្ម័យលើកទឹកចិត្ត និងការគោរពច្បាប់ដោយខ្លួនឯង

ដើម្បីផ្តល់ការលើកទឹកចិត្តប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល យន្តការសំខាន់ៗចំនួន៣ដូចខាងក្រោមត្រូវបានបង្កើតឡើង ដើម្បីលើកទឹកចិត្តប្រជាពលរដ្ឋ ទាំងរូបវន្តបុគ្គល ទាំងនីតិបុគ្គលគ្រប់ប្រភេទ ដែលត្រូវបានបង្កើតឡើងក្រោមច្បាប់នៃប្រទេសកម្ពុជា ជាអាទិ៍សហគមន៍មូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលឱ្យប្រកាន់យកឥរិយាបទបរិស្ថានមេត្រី៖

១) រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវដឹកនាំ និងបន្តពិនិត្យលទ្ធភាពផ្តល់ការលើកទឹកចិត្តដល់ការវិនិយោគ និង/ឬ សកម្មភាពអាជីវកម្មទាំងឡាយដែលជួយលើកកម្ពស់ការគាំពារបរិស្ថាន និង/ឬការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ស្របតាមសំណើ និង/ឬតាមគំនិតផ្តួចផ្តើមរបស់ក្រសួងបរិស្ថាន។ ការលើកទឹកចិត្តទាំងនេះ អាចធ្វើឡើងក្នុងរូបភាពជាការលើកទឹកចិត្តផ្នែកពន្ធការផ្តល់វិញ្ញាបនបត្របៃតង ការដាក់ស្លាកសម្គាល់មេត្រីបរិស្ថាន ការផ្តល់លិខិតសរសើរ និង/ឬឥណទានឧបត្ថម្ភក្នុងរូបភាពណាមួយ។

២) ការលើកទឹកចិត្តដែលបង្ហាញខាងលើនឹងត្រូវផ្តល់ជូន ដើម្បីជំរុញឱ្យមានការវិនិយោគមេត្រីបរិស្ថាន និង/ការបង្កើតអាជីវកម្មបៃតង (ដូចជាធ្យូងឬ ដែលមាននិរន្តរភាព អគារដែលមាននិរន្តរភាព ក្រុមហ៊ុនដែលទទួលខុសត្រូវចំពោះសង្គម "SCR" ថាមពលប្រកបដោយនិរន្តរភាព និង/ឬកើតឡើងវិញ និងអាជីវកម្មផ្សេងទៀត ដើម្បីប្រយោជន៍ដល់ការស្តារព្រៃឈើ និងឬ ការស្តារបរិស្ថានឡើងវិញ)

៣) នឹងមានការរៀបចំគោលនយោបាយជាតិ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីផ្តល់ការលើកទឹកចិត្តក្របកដោយប្រសិទ្ធភាព និងប្រសិទ្ធផលនិអាចធានាបាននូវភាពត្រឹមត្រូវយុត្តិធម៌និងសមធម៌សម្រាប់ទាំងអស់គ្នា។

គន្លឹះទី៨:វិធានការសេដ្ឋកិច្ច គណនេយ្យ ប្រាក់កម្រៃ និងមូលនិធិបរិស្ថាន

II. យន្តការផ្តល់ហិរញ្ញប្បទាន ដើម្បីគាំទ្រដល់ការបង្កើនប្រសិទ្ធភាពនិងប្រសិទ្ធផលនៃការអភិបាលកិច្ចបរិស្ថាន

យើងទាំងអស់គ្នាយល់ស្របដូចៗគ្នាថា ការការពារ ការគាំពារអភិបាលកិច្ចល្អក្នុងវិស័យបរិស្ថានជាទូទៅមិនអាចសម្រេចដោយពុំមានការចំណាយនោះឡើយ។ ដោយមូលហេតុនេះហើយ ដើម្បីរ៉ាប់រងចំណាយទាំងនេះប្រកបដោយចីរភាព ក្រមនេះបានបង្កើតនូវយន្តការផ្តល់ហិរញ្ញប្បទានធំៗចំនួន ៣៖

1) ក្រមនេះបង្កើតនូវប្រភពចំណូលជាច្រើន

2) ក្រមនេះផ្តល់លទ្ធភពឱ្យអ្នកដែលមានមូលនិធិ និង/ឬធនធានគ្រប់ប្រភេទទាំងអស់ អាចបង្កើតរចនាសម្ព័ន្ធគ្រប់គ្រងមូលនិធិដោយខ្លួនឯង ដោយត្រូវសហការ ឬពុំចាមបាច់មានការសហការជាមួយ និង/ឬការគាំទ្រពីដៃគូសាធារណៈនានា ដូចជាអាជ្ញាធររដ្ឋាភិបាលនៅថ្នាក់ជាតិ និង/ឬក្រោមជាតិជាដើម។ រចនាសម្ព័ន្ធគ្រប់គ្រងមូលនិធិដែលចុះបញ្ជីជាមួយនឹងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្រោមឈ្មោះមូលនិធិ «អាណត្តិព្យាបាល»។ ការគ្រប់គ្រង និងកិបាលកិច្ចត្រូវស្របតាមច្បាប់ស្តីពីអាណត្តិព្យាបាលភាព (trust law) ដែលកំពុងចូលជាធរមាន។

គន្លឹះទី៨:វិធានការសេដ្ឋកិច្ច គណនេយ្យ ប្រាក់កម្រៃ និងមូលនិធិបរិស្ថាន

II. យន្តការផ្តល់ហិរញ្ញប្បទាន ដើម្បីគាំទ្រដល់ការបង្កើនប្រសិទ្ធភាពនិងប្រសិទ្ធផលនៃការអភិបាលកិច្ចបរិស្ថាន (ត)

3) ចុងក្រោយ ដើម្បីលើកកម្ពស់កិច្ចគាំពារបរិស្ថានប្រកបដោយប្រសិទ្ធភាព និងដើម្បីលើកកម្ពស់ផលជាវិជ្ជមានចំពោះសហគមន៍ដែលឋិតនៅជុំវិញទីតាំងដែលមានការវិនិយោគ និង/ឬមានការធ្វើសកម្មភាពអាជីវកម្ម ក្រមនេះក៏បង្កើតកាតព្វកិច្ចតម្រូវឱ្យម្ចាស់វិនិយោគ និង/ឬអាជីវកម្មបង្កើតដោយឡែកនូវមូលនិធិពិសេស ក្រោមការគ្រប់គ្រងដោយខ្លួនឯង «សម្រាប់ប្រើប្រាស់ជាមូលនិធិបម្រុង ដើម្បីកាត់បន្ថយផលប៉ះពាល់បរិស្ថាន និងសង្គម ដែលកើតមានជាយថាហេតុ ចេញពីសកម្មភាពអាជីវកម្ម និង/ឬប្រតិបត្តិការវិនិយោគ ឬផលិតកម្មរបស់ពួកគេ»។ គេហៅមូលនិធិបែបនេះថា «មូលនិធិគ្រប់គ្រងបរិស្ថាន (EMP)»។ មូលនិធិនេះ នឹងត្រូវប្រើប្រាស់ដើម្បីអនុវត្តកម្មវិធីត្រួតពិនិត្យនិងតាមដានការបំពុលបរិស្ថាន ការសម្អាតសំណល់ និង/ឬការកែច្នៃសំណល់ឡើងវិញ ការបំពាក់ប្រព័ន្ធការពារមិនឱ្យមានសំឡេងរំខាន និងរំញ័រ ការបង្កើតផ្ទៃបៃតង និង/ឬអនុវត្តសកម្មភាពផ្សេងទៀត ដែលតម្រូវដោយច្បាប់ និង/ឬអាជ្ញាធររដ្ឋាភិបាលដែលមានសមត្ថកិច្ច។

គន្លឹះទី៩:ការទទួលខុសត្រូវលើការខូចខាតបរិស្ថាន

ក្រមនេះ បានដាក់ចេញនូវមូលដ្ឋានគ្រឹះស្តីពីការទទួលខុសត្រូវផ្នែកបរិស្ថាន ដោយធ្វើការឆ្លើងឆ្លែងពីអំណាចក្នុងការធានាឱ្យមានយុត្តិធម៌សង្គម និងការប្រតិបត្តិដោយការស្មើភាពគ្នា និងប្រកបដោយសមធម៌សម្រាប់ទាំងអស់គ្នា។ ដើម្បីសម្រេចគោលដៅនេះ មានការដាក់ចេញនូវគោលការណ៍ណែនាំជាច្រើន ដូចជា៖

១. ពាក់ព័ន្ធនឹងការខាតបង់ចំពោះបរិស្ថាន និងការបង់សំណង

២. ពាក់ព័ន្ធនឹងនីតិវិធី និងបែបបទវិញមានការដាក់ចេញនូវគោលការណ៍ជាមូលដ្ឋានដើម្បីបង្កើនប្រសិទ្ធភាព។

គន្លឹះទី១០:នីតិវិធីដោះស្រាយបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ

ដោយធ្វើការពិចារណាពីលក្ខណៈពិសេស និងភាពស្មុគស្មាញនៃជម្លោះបរិស្ថាន (ដោយសារតែបញ្ហាកស្តុតាង ភាពស្មុគស្មាញនៃការវាយតម្លៃផលប៉ះពាល់ ការរៀបចំផ្តល់សំណង និងតម្លៃនានា ...) វិធានពិសេសចំនួន ៥ ត្រូវបានដាក់ឱ្យអនុវត្តក្រោមក្របខ័ណ្ឌនេះ ដើម្បីលើកម្ពស់យុត្តិធម៌ក្នុងវិស័យបរិស្ថាន បន្ថែមពីលើនីតិវិធីតុលាការដែលត្រូវបានចែងក្នុងច្បាប់ព្រហ្មទណ្ឌ និងក្រមនីតិវិធីរដ្ឋប្បវេណី ដែលកំពុងចូលជាធរមាននាពេលបច្ចុប្បន្ននេះក្នុងប្រទេសកម្ពុជា៖

១. ការដាក់ពាក្យបណ្តឹង

២. វិធានគ្រប់ដណ្តប់លើការធ្វើសេចក្តីសម្រេចចិត្ត

៣. វិធានការកស្តុតាង៖ បើតាមក្រមនេះ ជនណាក៏ដោយ ដែលចាប់អារម្មណ៍មានសេរីភាពក្នុងការផ្តល់កស្តុតាង ដែលខ្លួនគិតថា មានប្រយោជន៍

៤. ហាន:ពិសេសរបស់មន្ត្រីក្រសួងបរិស្ថាន

៥. បទល្មើសបរិស្ថាន

គន្លឹះទី១១:ទោសប្បញ្ញត្តិ

ការខកខានមិនអនុវត្តតាមក្រមនេះនិងលិខិតបទដ្ឋានគតិយុត្តសម្រាប់អនុវត្តផ្សេងទៀត ដូចជា គោល ការណ៍ណែនាំនិងច្បាប់ពាក់ព័ន្ធផ្សេងទៀត ដែលគ្រប់ដណ្តប់លើកិច្ចការពាក់ព័ន្ធនឹងធនធានធម្មជាតិ និងបរិស្ថាន អាចនាំឱ្យមានទោសដូចខាងក្រោម៖

- ការព្រមានជាលយលក្ខណ៍អក្សរ

-ការដកហូត ឬការព្យួរការងារការឯកភាព ឬលិខិតអនុញ្ញាតិ (ដូចជាការឯកភាពលើការវាយតម្លៃហេតុផល ប៉ះពាល់បរិស្ថាន លិខិតអនុញ្ញាតិអោយបញ្ចេញសំណល់...) ការពិន័យ ការសងសំណងជាដើម

-ទោសជាប់ពន្ធនាគារដោយមាន ឬគ្មានទោសបន្ថែម ដូចជាការរំលាយក្រុមហ៊ុន ការដកមុខតំណែង នាយកក្រុមហ៊ុន ការបិទសកម្មភាពផលិតកម្មជាបណ្តោះអាសន្ន ការផ្អាកកិច្ចព្រមព្រៀងសម្បទាន ការដកហូតទ្រព្យ សម្បត្តិរបស់ក្រុមហ៊ុន ការដាក់កំហិតលើសកម្មភាពអាជីវកម្មជាដើម និងទោសផ្សេងទៀតដែលចែងក្នុងក្រម ព្រហ្មទណ្ឌនៃ ព្រះរាជាណាចក្រកម្ពុជា

គន្លឹះទី១១:ទោសប្បញ្ញត្តិ

បទល្មើសទាំង ៥ថ្នាក់ ត្រូវបានកំណត់ដូចខាងក្រោម៖

១. បទល្មើសថ្នាក់ទី១ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ទៅ៣០ឆ្នាំ និងពិន័យជាប្រាបក់ពី ៤០០.០០០.០០០ (បួនរយលាន) រៀល ទៅ ៨០០.០០០.០០០ (ប្រាំបីរយលាន)រៀល។

២. បទល្មើសថ្នាក់ទី២ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០៥ឆ្នាំ ទៅ ១០ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី ២០០.០០០.០០០ (ពីររយលាន) រៀលទៅ ៤០០.០០០.០០០ (បួនរយលាន) រៀល។

៣. បទល្មើសថ្នាក់ទី៣ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០១ឆ្នាំ ទៅ ០៥ឆ្នាំ និងត្រូវពិន័យជាប្រាប់ពី ២០.០០០.០០០ (ម្ភៃលាន) រៀលទៅ ២០០.០០០.០០០ (ពីររយលាន) រៀល។

៤. បទល្មើសថ្នាក់ទី៤ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០៧ថ្ងៃ ទៅ០១ឆ្នាំ និង/ឬត្រូវពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀលទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល។

៥. បទល្មើសថ្នាក់ទី៥ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី០១ ទៅ ០៦ថ្ងៃ និង/ឬត្រូវពិន័យជាប្រាក់ពី ២០.០០០ (ពីរម៉ឺន) រៀលទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល។

សូមអរគុណ!

សិក្ខាសាលាត្រួតពិនិត្យលទ្ធផលការងារអភិវឌ្ឍន៍ដោយចីរភាពឆ្នាំ២០១៩
និងទិសដៅការងារឆ្នាំ២០២០

ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩ សាលប្រជុំម៉ុក ម៉ារ៉េត ទីស្តីការក្រសួងបរិស្ថាន

កិច្ចផ្ដួចផ្ដើមការសិក្សា និងការរៀបចំគោលនយោបាយ ជាមពលពន្លឺព្រះអាទិត្យនៅកម្ពុជា

ជន គង្គា
នាយកដ្ឋានសេដ្ឋកិច្ចបៃតង

មាតិកា

- សេចក្តីផ្តើម
- សមិទ្ធផល
- បញ្ហាប្រឈម និងអនុសាសន៍
- ទិសដៅ២០២០

សេចក្តីផ្តើម



ការគ្រប់គ្រងថាមពល និងថាមពលកកើតឡើងវិញប្រកបដោយប្រសិទ្ធភាព

ការគ្រប់គ្រងថាមពលសម្រាប់ការអភិវឌ្ឍបៃតងគឺត្រូវ**សន្សំសំចៃថាមពល និងផ្តត់ផ្តង់ថាមពលចម្រុះបន្ថែម**ដើម្បីកសាងសង្គមកម្ពុជាដែលមានការបញ្ចេញកាបូនទាប កាត់បន្ថយការបំពុលបរិស្ថាន និងបញ្ចៀសវិបត្តិហិរញ្ញវត្ថុសម្រាប់អ្នកប្រើប្រាស់ ជាពិសេសប្រជាជននៅជនបទ

សេចក្តីផ្តើម

ការប្តេជ្ញារបស់កម្ពុជា

- កម្ពុជាស្នើការរួមចំណែកកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់សម្រាប់២០២០-២០៣០ ក្រោមលក្ខខណ្ឌនៃការគាំទ្រផ្សេងៗពីសហគមន៍អន្តរជាតិ
- របាយការណ៍ “ការចូលរួមចំណែករបស់កម្ពុជាក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ NDC” បញ្ជាក់ពីយុទ្ធសាស្ត្រ រយៈពេលវែង ដែលមានបំណងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់តាមរយៈការធ្វើផែនការតាមវិស័យ និងថ្នាក់ជាតិដែលអនុលោមតាមអាទិភាពនៃការអភិវឌ្ឍ។

វិស័យសំខាន់ៗសម្រាប់កាត់បន្ថយឧស្ម័នផ្ទះកញ្ចក់

- **ឧស្សាហកម្មថាមពល ឧស្សាហកម្មកម្មន្តសាល ការដឹកជញ្ជូន និងវិស័យផ្សេងៗទៀត ៖** កាត់បន្ថយជាអតិបរិមា 3,100 Gg CO_2eq ប្រៀបធៀបជាមួយការបញ្ចេញជាមូលដ្ឋាន 11,600 Gg CO_2eq (27%) ត្រឹមឆ្នាំ 2030
- **ការប្រើប្រាស់ដីធ្លី ការប្រែប្រួលការប្រើប្រាស់ដីធ្លី និងព្រៃឈើ (LULUCF) ៖** បង្កើនគម្របព្រៃឈើទៅ 60% នៃផ្ទៃដីត្រឹមឆ្នាំ 2030. កាត់បន្ថយត្រឹម 7,897 $GgCO_2$ នៅ 2030 ប្រៀបធៀបការស្រូបដែលប៉ាន់ប្រមាណ 18,492 $GgCO_2$ នៅ

សេចក្តីផ្តើម

តើយើងអាចឈានឆ្ពោះទៅអនាគតដែលកាន់តែមានថាមពលនិរន្តរភាពយ៉ាងដូចម្តេច ?

ទស្សនទាន៖ យើងអាចឈានឆ្ពោះទៅអនាគតដែលកាន់តែមានថាមពលនិរន្តរភាព ដោយពង្រឹងប្រសិទ្ធភាពថាមពល ប្រើប្រាស់ថាមពលចម្រុះនៃធនធានថាមពលកកើតឡើងវិញ និងបញ្ចូលតម្លៃសុខភាព និងបរិស្ថាននៃធនធានថាមពលទៅក្នុងតម្លៃទីផ្សារ។

សេចក្តីផ្តើម

ការជ្រើសរើសមាស៊ាំនានាឆ្ពោះទៅថាមពលនិរន្តភាព

បើគិតពីអនាគតថាមពលដែលអាចមាន មានសេចក្តីសន្និដ្ឋានទូទៅចំនួន៣ ដោយផ្តែកលើជម្រើសថាមពលនានា

- *ទី១ ក្នុងសតវត្សនេះ អាចមានការឈានចេញពីការពឹងផ្តែកលើឥន្ធនៈហ្វូស៊ីល ទៅថាមពលកកើតឡើងវិញចម្រុះ ដូចជាថាមពលព្រះអាទិត្យ ថាមពលខ្យល់ ថាមពលវារីអគ្គិសនី និងថាមពលកម្តៅក្នុងដី*

- *ទី២ ការបញ្ចូលគ្នានៃវិធានការប្រសិទ្ធភាពថាមពល និងការប្រើប្រាស់នៃឧស្ម័នធម្មជាតិ ដែលត្រូវបានត្រួតពិនិត្យដោយប្រុងប្រយ័ត្ន អាចជាវិធីមួយដ៏ល្អក្នុងការឈានទៅការប្រើប្រាស់ធនធានថាមពលកកើតឡើងវិញកាន់តែច្រើន*

- *ទី៣ ដោយសារតែឥន្ធនៈហ្វូស៊ីលនៅមានច្រើន និងមានតម្លៃថោក យើងនឹងនៅបន្តប្រើប្រាស់ឥន្ធនៈទាំងនេះក្នុងបរិមាណច្រើន*

សមិទ្ធិផល

1. **ការសិក្សាស្រាវជ្រាវជាមួយដៃគូអតិថិជន៍ស្តីពីសក្តានុពលថាមពលព្រះអាទិត្យនៅកម្ពុជា**

   - វិថីឆ្ពោះទៅសន្តិសុខថាមពលនិរន្តរភាពនៅកម្ពុជា (២០១៦)
   - របាយការណ៍ស្តីពីការកាត់បន្ថយហានិភ័យវិនិយោគថាមពលពន្លឺព្រះអាទិត្យនៅកម្ពុជា (២០១៩)

2. **ការបង្កើតក្រុមការងារបច្ចេកទេសដាយតម្លៃសក្តានុពលថាមពលពន្លឺព្រះអាទិត្យ**

សមិទ្ធិផល

ធាតុចូលខាងក្រោមត្រូវបានរៀបចំឡើងសម្រាប់ការពិចារណា ដោយក្រុមការងារបច្ចេកទេសដាយតម្លៃសក្តានុពលថាមពលពន្លឺព្រះអាទិត្យ

1. *ឯកសារគោលនយោបាយ៖ ការឆ្លើយតបទៅនឹង ការកង្វះខាតថាមពល នៅកម្ពុជា, អត្ថបទស្រាវជ្រាវ និងអនុសាសន៍សម្រាប់បង្កើតគោលនយោបាយ*
2. *ការវិភាគ និងតែតម្រូវដែលស្នើឡើងសម្រាប់បទប្បញ្ញត្តិស្តីពីថាមពលពន្លឺព្រះអាទិត្យ*
3. *ការវាយតម្លៃ ការផ្គត់ផ្គង់ថាមពលលើសតម្រូវការដែលអាចមានពីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យនៅលើដំបូលនៅកម្ពុជា*
4. *វិធីសាស្ត្រស្នើឡើងសម្រាប់វាយតម្លៃឆាប់រហ័សនៃការខាតបង់សេដ្ឋកិច្ចដែលកើតឡើងដោយការរអាក់រអួលនៃការផ្គត់ផ្គង់អគ្គិសនីនៅកម្ពុជា*
5. *របាយការណ៍ស្តីពីការកាត់បន្ថយហានិភ័យវិនិយោគថាមពលពន្លឺព្រះអាទិត្យនៅកម្ពុជា៖ ការរកឃើញសំខាន់ៗ*

សមិទ្ធិផល

គោលលក្ខណៈនៃការសិក្សាស្តីពីការកាត់បន្ថយហានិភ័យវិនិយោគថាមពលពន្លឺព្រះអាទិត្យនៅកម្ពុជា

- **កំណត់វិធានការកាត់បន្ថយហានិភ័យដែលមានប្រសិទ្ធភាពចំណាយ៖** ការសិក្សានេះមានគោលបំណងធ្វើការវិភាគលើវិធានការសាធារណៈដែលមានប្រសិទ្ធភាពចំណាយបំផុត ដើម្បីគាំទ្រការវិនិយោគរបស់វិស័យឯកជន លើផ្នែកថាមពលពន្លឺព្រះអាទិត្យនៅកម្ពុជា
- **ការវិភាគលើអនុវិស័យទាំងបួន៖** ដោយប្រើវិធីសាស្ត្របែបទូលំទូលាយ ការសិក្សានេះផ្តោតលើអនុវិស័យថាមពលពន្លឺព្រះអាទិត្យបួនផ្សេងគ្នា៖
  - **ប្រព័ន្ធតភ្ជាប់នឹងបណ្តាញអគ្គិសនីរដ្ឋ (on-grid)** ដែលរួមមាន៖ ១.ថាមពលពន្លឺព្រះអាទិត្យខ្នាតធំសម្រាប់ផលិតកម្មអគ្គិសនី (utility-scale photovoltaics) និង ២. ថាមពលពន្លឺព្រះអាទិត្យដាក់លើដំបូលអគារ(roof-top photovoltaics)
  - **ប្រព័ន្ធមិនតភ្ជាប់នឹងបណ្តាញអគ្គិសនីរដ្ឋ (off-grid)** ដែលរួមមាន៖ ៣. បណ្តាញអគ្គិសនីខ្នាតតូចដែលប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យនិងអាគុយ (solar-battery mini-grids) និង ៤. ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ(solar home system)



- **ចំណុចដៅវិនិយោគដោយផ្នែកឯកជន៖** ចំពោះអនុវិស័យនិមួយៗខាងលើ សិក្សានេះបានកំណត់ចំណុចដៅសន្មតសម្រាប់ការវិនិយោគដោយផ្នែកឯកជនដូចខាងក្រោម៖
  - **ប្រព័ន្ធតភ្ជាប់នឹងបណ្តាញអគ្គិសនីរដ្ឋ (on-grid) ៖** ចំពោះថាមពលពន្លឺព្រះអាទិត្យខ្នាតធំសម្រាប់ផលិតកម្មអគ្គិសនី៣៥០មេហ្គាវ៉ាត់(MW) និង៣៥០MW ទៀតសម្រាប់ថាមពលពន្លឺព្រះអាទិត្យដាក់លើដំបូលអគារ សរុប៧០០ MW ។ចំនួននេះស្មើនឹង២០%នៃសមត្ថភាពផលិតថាមពលអគ្គិសនីសរុបរបស់កម្ពុជានៅឆ្នាំ ២០៣០។
➢ ជំរុញឱ្យមានការផ្សព្វផ្សាយ និងគ្រប់គ្រងព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុឱ្យមានលក្ខណៈទូលំទូលាយ ជាពិសេសក្នុងតំបន់ដែលងាយទទួលរងគ្រោះ

➢ កសាងសមត្ថភាពបន្សាំនឹងការប្រែប្រួលអាសធាតុ សំដៅកាត់បន្ថយការខាតបង់នៃប្រាក់ចំណូល។

សូមអរគុណ!

https://ncsd.moe.gov.kh/dcc

សិក្ខាសាលាត្រួតពិនិត្យលទ្ធផលការងារអភិវឌ្ឍន៍ដោយចីរភាពឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០

ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩

វឌ្ឍនភាពនៃការតាក់តែងគោលនយោបាយស្តីពីការទូទាត់សេវាកម្មប្រព័ន្ធអេកូឡូស៊ីនៅកម្ពុជា (PES)

ដោយ លោកម៉ែង មុនីរក្ស
ប្រធាននាយកដ្ឋានជីវៈចម្រុះ
អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព/ ក្រសួងបរិស្ថាន

មាតិកា

1. សាវតានៃការរៀបចំគម្រោងសាកល្បង PES នៅកម្ពុជា
2. គម្រោងសាកល្បង PES នៅភ្នំគូលែន និងក្បាលឆាយ
3. លទ្ធផលនៃការសិក្សាសមិទ្ធិលទ្ធភាពរបស់គម្រោងសាកល្បង PES
4. ជម្រើសសម្រាប់ការបង់ថ្លៃសេវាកម្ម
5. អនុសាសន៍ និងសេចក្តីសម្រេចសម្រាប់អនុវត្តគម្រោងសាកល្បង PES បន្ត

1. សាថតានៃការរៀបចំគម្រោងសាកល្បង PES នៅកម្ពុជា

- សេចក្តីសម្រេចរបស់កិច្ចប្រជុំប្រទេសជាមាជិកនៃអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ
- យន្តការ (Official establishment of PES)
- តួនាទី និងភារកិច្ចរបស់ គ.ជ.អ.ច. ក្នុងការអនុវត្តអនុសញ្ញា UN-CBD និងកៀរគរហិរញ្ញវត្ថុក្នុងការអនុវត្តកម្មវិធីគ្រប់គ្រងធនធានធម្មជាតិ និងជីវៈចម្រុះ
- ដំណើរទស្សនកិច្ចសិក្សារបស់ថ្នាក់ដឹកនាំកម្ពុជានៅប្រទេសកូស្តារីការ
- សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ស្តីពីការអនុញ្ញាតឱ្យរៀបចំសាល្បង PES

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ...

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ភ្នំពេញ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០១៦

ឯកឧត្តម រដ្ឋមន្ត្រីក្រសួងបរិស្ថាន

• តំបន់ប្រើប្រាស់ច្រើនយ៉ាងក្បាលធាយក្នុងខេត្តព្រះសីហនុ ជាប្រភពផ្គត់ផ្គង់ទឹកស្អាតដ៏សំខាន់បំផុតសម្រាប់ក្រុងព្រះសីហនុ ដែលចប្បុប្បន្នមានក្រុមហ៊ុនឯកជនបាន និងកំពុងទាញយកទឹកពីតំបន់ក្បាលធាយ មកផលិតជាទឹកស្អាតសម្រាប់ឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់របស់ប្រជាជន ភ្ញៀវទេសចរណ៍ និងអាជីវកម្មផ្សេងៗ។

• ឧទ្យានជាតិព្រះជ័យវ៉ែនរកត្តម "កំគុលេន" ក្នុងខេត្តសៀមរាប គឺជាទីជម្រាល ដែលមានសក្តានុពលខ្ពស់សម្រាប់ជាប្រភពទឹកផ្គត់ផ្គង់តម្រូវការប្រើប្រាស់ទឹកស្អាតរបស់ប្រជាជន ភ្ញៀវទេសចរណ៍ និងអាជីវកម្មផ្សេងៗទៀត នៅក្នុងក្រុងសៀមរាប។

• ពិនិត្យសិក្សា និងរៀបចំអនុវត្តន៍សាកល្បង ការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី ពីសំណាក់ក្រុមហ៊ុនវារីអគ្គិសនីមួយចំនួន ដោយហេតុថាដំណើរការផលិតថាមពលពីវារីអគ្គិសនី ទាមទារឱ្យមានការ

សេចក្តីសម្រេចចិត្តរបស់រាជរដ្ឋាភិបាល សាកល្បងលើ២ទីតាំង

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រី សូមជម្រាបជូនឯកឧត្តមជ្រាបថា រាជរដ្ឋាភិបាលបានឃើញ និងឯកភាពដូចខាងក្រោម៖

- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពី "ការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី" ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ និងមានគ្មិនសំខាន់ៗមកពីប្រទេសកូស្តារីកា ដើម្បីចែករំលែកបទពិសោធន៍ជាក់ស្តែង ដោយសហការជាមួយអង្គការ CI និងក្រសួង ស្ថាប័នពាក់ព័ន្ធ។

- ក្រសួងបរិស្ថានត្រូវសហការជាមួយក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធក្នុងការរៀបចំសេចក្តីព្រាងសំណើគោលនយោបាយស្តីពី "ការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី" ដើម្បីជាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច។

- ឱ្យក្រសួងបរិស្ថាន សហការជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធក្នុងការសិក្សារៀបចំអនុវត្ត "គោលការណ៍បង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី" ជាលក្ខណៈសាកល្បងនៅតាមតំបន់ ដែលមានសក្តានុពលមួយចំនួន ដូចខាងក្រោម៖

ស.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
ប្លង់លេខាធិការ

ចម្លងជូន:
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ក្រសួងកសិកម្ម ព្រៃឈើ និងនេសាទ
-ក្រសួងធនធានទឹកនិងឧតុនិយម
-ក្រសួងឧស្សាហកម្មនិងសិប្បកម្ម
-ក្រសួងរ៉ែនិងថាមពល
-ក្រសួងទេសចរណ៍
-អគ្គលេខាធិការដ្ឋាភិបាល
-ឧទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ឧទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន
-ឯកសារ-កាលប្បវត្តិ

2. គម្រោងសាកល្បង PES នៅភ្នំគូលែន និងក្បាលឆាយ

ភ្នំគូលែន

- ជាប្រភពទឹកធម្មជាតិដ៏សំខាន់មួយ
- តម្រូវការទឹកក្នុងខេត្តមានការកើនឡើងជាខ្លាំង
- គម្របព្រៃឈើនៅឧទ្យានជាតិមានការធ្លាក់ចុះយ៉ាងខ្លាំង
- សកម្មភាពកសិកម្ម (កាប់ព្រៃធម្មជាតិយកដី) មានការកើនឡើងយ៉ាងគំហុក (ដំណាំចន្ទី)

ក្បាលឆាយ

- ជាប្រភពទឹកធម្មជាតិដ៏សំខាន់បំផុតនិងតែ១គត់
- ទឹកក្រោមដីមិនអាចទាញយកមកប្រើប្រាស់ឱ្យបានគ្រប់គ្រាន់
- បឹងព្រែកទប់ ដែលជាប្រភពសំខាន់ទី២ ប្រឈមនឹងបាត់បង់មុខងារនាពេលខាងមុខ
- តម្រូវការទឹកមានការកើនឡើងជាខ្លាំង (១ទ្វេជា២ ឬ៣ដង ចាប់ពីពេលនេះតទៅ)

3. លទ្ធផលនៃការសិក្សាសមិទ្ធិលទ្ធភាពសម្រាប់ក្រុងសៀមរាប (1)





3. លទ្ធផលនៃការសិក្សាសមិទ្ធិលទ្ធភាពសម្រាប់ភ្នំគូលែន (2)

3. លទ្ធផលនៃការសិក្សាសមិទ្ធិលទ្ធភាពសម្រាប់ក្រុងព្រះសីហនុ (3)



3. លទ្ធផលនៃការសិក្សាសមិទ្ធិលទ្ធភាពសម្រាប់ក្បាលឆាយ (4)

4. ជម្រើសសម្រាប់ការបង់ថ្លៃ PES

ភ្នំគូលែន

1. ការរួមវិភាគទានដោយស្ម័គ្រចិត្តពីអ្នកប្រើប្រាស់ទឹកច្រើន
2. ការគិតពន្ធលើថ្លៃប្រើប្រាស់ទឹកលក្ខណៈពាណិជ្ជកម្ម
3. ថ្លៃសេវាប្រព័ន្ធបរិស្ថានសម្រាប់ភ្ញៀវដែលមកដល់អាកាសយានដ្ឋាន
4. បញ្ចូលក្នុងថ្លៃសំបុត្រចូលទស្សនាប្រាសាទអង្គរវត្ត
5. ការយកថ្លៃបរិស្ថានសម្រាប់ផ្លូវថ្មីលើភ្នំគូលេន

ក្បាលឆាយ

1. ការរួមវិភាគទានដោយស្ម័គ្រចិត្តពីអ្នកប្រើប្រាស់ទឹកច្រើន
2. ការបង់ពន្ធលើការប្រើប្រាស់ទឹកជាលក្ខណពាណិជ្ជកម្ម
3. ថ្លៃសេវាប្រព័ន្ធបរិស្ថានសម្រាប់ភ្ញៀវដែលមកដល់អាកាសយានដ្ឋាន
4. ទីផ្សារឥណទានកាបូន
5. ប្រភពផ្សេងៗ

ការប៉ាន់ប្រមាណនៃថវិកាសរុបបានពីការឧបត្ថម្ភ

ប្រសិនអនុវត្តជម្រើសអាទិភាព៣ខាងលើជាគោលការណ៍ ពេលនោះPES តំណាងហិរញ្ញវត្ថុពីការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី នឹងអាចប្រមូលបានក្នុងមួយឆ្នាំគឺ៖

- ក្បាលឆាយ៖ ចំនួនពី 0.9 US$ ទៅ 1.1 លាន US$
- ភ្នំគូលែន៖ ចំនួនពី 2.9 US$ ទៅ 3.9 លាន US$

5. អនុសាសន៍ និងសេចក្តីសម្រេចសម្រាប់អនុវត្តបន្ត (1)

1. ធ្វើបច្ចុប្បន្នភាពព័ត៌មានស្តីពីស្ថានភាពដើម
2. ធ្វើការសិក្សាបន្ថែមលើផ្នែកតម្រូវការទឹក ដូចជា ការប្រើប្រាស់បច្ចេកវិទ្យាសន្សំសំចៃទឹកនិងការបាត់បង់ទឹក ការកំណត់ថ្លៃទឹក និងការអប់រំផ្សព្វផ្សាយ
3. រៀបចំធ្វើផែនការគ្រប់គ្រងទីជម្រាល រួមទាំងផែនការថវិកា
4. ធ្វើការវិភាគស្វែងរកជម្រើសបន្ទាប់ ឬជម្រើសផ្សេងទៀតដែលមានលក្ខណៈពិពណ៌នា
5. រៀបចំឯកសារគតិយុត្ត ឬគោលការណ៍ណែនាំពាក់ព័ន្ធនឹង PES
6. **គួរចាប់ផ្តើមអនុវត្តអនុវត្តគោលការណ៍ស្មគ្រចិត្តក្នុងការបង់ថ្លៃសេវាកម្មការប្រើប្រាស់ទឹកពីភាគីអ្នកប្រើប្រាស់ទឹកជាលក្ខណៈអាជីវកម្ម លក្ខណៈដំហានបឋម**

5. អនុសាសន៍ និងសេចក្តីសម្រេចសម្រាប់អនុវត្តបន្ត (2)

7. គួរពិចារណាដាក់ចេញវិធានការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី ក្នុងកញ្ចប់មូលនិធិបរិស្ថាន និងសង្គម
8. ពិនិត្យមើលទ្រព្យសកម្មអាងស្តុកទឹកនៅក្នុងតំបន់ ឬទំនប់ទឹកបម្រុង ពិសេសសម្រាប់ការប្រើប្រាស់ទឹកនៅរដូវប្រាំង
9. ត្រូវរៀបចំគោលការណ៍ឱ្យបានច្បាស់លាស់ក្នុងការអនុវត្ត PES ដោយតម្រូវឱ្យមានការពិភាក្សាស៊ីជម្រៅដើម្បីរៀបចំឯកសារគតិយុត្តឱ្យមានលក្ខណៈងាយស្រួល និងអាចអនុវត្តបាន
10. ពិនិត្យសិក្សាលទ្ធភាពលើសេវាកម្មនានាក្រៅពីទឹក ជាពិសេសលើមុខងាររបស់ប្រភេទនានា
11. គួរតែមានការកៀរគរថវិកាពីប្រភពធនធាន និងបន្ថែមកម្លាំងការពារនៅទីតាំងគោលដៅផ្ទាល់។

ការពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពី "ការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ីនៅកម្ពុជា"



ផែនទីបង្ហាញផ្លូវ

រយៈពេលខ្លី (៦ ទៅ ១២ខែ)

- បង្កើតសេចក្តីប្រកាសរួមរវាងក្រសួងពាក់ព័ន្ធស្តីពីយន្តការនៃការគ្រប់គ្រង PES តាមរយៈមូលនិធិបរិស្ថាន និងសង្គម ឬបង្កើតកញ្ចប់មូលនិធិដាច់ដោយឡែក
- រៀបចំយន្តការនៃការបែកចែកផលប្រយោជន៍បានពី PES
- ផ្សព្វផ្សាយ PES ទៅស្ថានប័នពាក់ព័ន្ធ
- ជំរុញ និងគាំទ្រឱ្យមានការរៀបចំផែនការគ្រប់គ្រង និងកំណត់តំបន់ នៅតំបន់សាកល្បងទាំងពីរ
- ជំរុញការអនុវត្តPES បន្ទាន់ជាមួយសហគមន៍ដែលរស់នៅខ្សែទឹកខាងលើ

ផែនទីបង្ហាញផ្លូវ

រយៈពេលវែង (២ ទៅ ៣ឆ្នាំ)

- ជំរុញយន្តការ PES ទៅអនុវត្តនៅថ្នាក់តំបន់
- សិក្សាវាយតម្លៃ កំណត់សក្តានុពលសេវាកម្មប្រព័ន្ធអេកូឡូស៊ីនៅតំបន់ទេសភាពផ្សេងៗ
- ប្រើប្រាស់ថវិកាមួយចំនួនបានពី PES ដើម្បីសិក្សាពីទំនាក់ទំនងប្រភពទឹក និងផ្លូវទឹក និងបរិមាណទឹកដែលអាចផ្គត់ផ្គង់បាន

សូមអរគុណ !

អាស័យដ្ឋានទាក់ទង ៖
Email: mmonyrak@gmail.com
Tel.: 078 800 816

Annual Workshop to Review NCSD 2019 Progress and 2020 PLANS

Managing Sustainable Development

21 October 2019

Development of Policy on Payment for Ecosystem Service (PES)

By Mr. Meng Monyrak
Director of Department of Biodiversity
General Secretariat of National Council for Sustainable Development/MoE

OUTLINE

1. Background of PES Project in Cambodia
2. Pilot PES Projects in Phnom Kulen Mountain and Kbal Chay
3. Findings of feasibility study on Pilot PES Projects
4. Options of PES schemes
5. Recommendations and Decision-making on implementation of PES

Background of Pilot PES Project in Cambodia

- Decision made in UNCBD COP
- Official Establishment of PES
- Roles and Duties of NCSD in implementation of UN-CBD and resource mobilization for implantation of NR and biodiversity-related programmes
- Visits of Cambodia leaders to Costa Rica
- Decision made by RGC on Implementation of pilot PES projects



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ភ្នំពេញ ថ្ងៃទី ២០ ខែតុលា ឆ្នាំ២០១៦

ទៅ៖ ឯកឧត្តម រដ្ឋមន្ត្រីក្រសួងបរិស្ថាន

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រី សូមជម្រាបជូន ឯកឧត្តមជ្រាបថា ពជរដ្ឋាភិបាលបានឃើញ និងឯកភាពដូចខាងក្រោម៖

- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពី "ការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី" ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ និងមានគ្និនសំខាន់ៗមកពីប្រទេសកូស្តារីកា ដើម្បីចែករំលែកបទពិសោធន៍ជាក់ស្តែង ដោយសហការជាមួយអង្គការ CI និងក្រសួង ស្ថាប័នពាក់ព័ន្ធ។

- ក្រសួងបរិស្ថានត្រូវសហការជាមួយក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធក្នុងការរៀបចំសេចក្តីព្រាងសំណើរគោលនយោបាយស្តីពី "ការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី" ដើម្បីជាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច។

- ឱ្យក្រសួងបរិស្ថាន សហការជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធក្នុងការសិក្សារៀបចំអនុវត្ត "គោលការណ៍បង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី" ជាលក្ខណៈសាកល្បងនៅតាមតំបន់ ដែលមានសក្តានុពលមួយចំនួន ដូចខាងក្រោម៖

• តំបន់ប្រើប្រាស់ច្រើនយ៉ាងក្បាលធាយក្នុងខេត្តព្រះសីហនុ ជាប្រភពផ្គត់ផ្គង់ទឹកស្អាតដ៏សំខាន់បំផុតសម្រាប់ក្រុងព្រះសីហនុ ដែលចម្ងុបុ្បន្នមានក្រុមហ៊ុនឯកជនបាន និងកំពុងទាញយកទឹកពីតំបន់ក្បាលធាយ មកផលិតជាទឹកស្អាតសម្រាប់ឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់របស់ប្រជាជន ភ្ញៀវទេសចរណ៍ និងអាជីវកម្មផ្សេងៗ។

• ឧទ្យានជាតិព្រះជ័យវ៉ែននពេត្តម "ក្នុគូលេន" ក្នុងខេត្តសៀមរាប គឺជាទីជម្រាល ដែលមានសក្តានុពលខ្ពស់សម្រាប់ជាប្រភពទឹកផ្គត់ផ្គង់តម្រូវការប្រើប្រាស់ទឹកស្អាតរបស់ប្រជាជន ភ្ញៀវទេសចរណ៍ និងអាជីវកម្មផ្សេងៗទៀត នៅក្នុងក្រុងសៀមរាប។

• ពិនិត្យសិក្សា និងរៀបចំអនុវត្តន៍សាកល្បង ការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី ពីសំណាក់ក្រុមហ៊ុនវារីអគ្គិសនីមួយចំនួន ដោយហេតុថាដំណើរការផលិតថាមពលពីវារីអគ្គិសនី ទាមទារឱ្យមានការថែរក្សាការពារទីជម្រាល និងផ្ទៃរងទឹកគៀងឱ្យបានល្អត់ត្រង់ ដើម្បីបានរយៈពេលទឹក។

Decision of RGC on Implementation of two pilot PES Projects

ចម្លងជូន:
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ក្រសួងកសិកម្ម ព្រៃឈើ និងនេសាទ
-ក្រសួងធនធានទឹកនិងឧតុនិយម
-ក្រសួងឧស្សាហកម្មនិងសិប្បកម្ម
-ក្រសួងរ៉ែនិងថាមពល
-ក្រសួងទេសចរណ៍
-អគ្គលេខាធិការដ្ឋាភិបាល
-ឧទ្ធកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ឧទ្ធកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន
-ឯកសារ-កាលប្បវត្តិ

PES Projects in Phnom Kulen Mountain and Kbal Chay

Phnom Kulen

- Main source of water supply in the province
- High water demands in the province
- Decrease of forest cover in the park
- Sharp increase of agriculture activities (Land encroachment, Cashew plantation)

Kbal Chay

- Main source of water supply in the province
- Underground water cannot be extracted for consumption
- Boeng Praktup, the second source of water supply, might lose its functions in the future
- Water demands in the province are doubled

Findings of feasibility study on pilot PES project in SR province





Findings of feasibility study on pilot PES project in Phnom Kulen

Findings of feasibility study on pilot PES project in PSV





Findings of feasibility study on pilot PES project in Kbal Cha

Options of PES Schemes

Phnom Kulen	ក្បាលធាយ
• **Voluntary contribution from the users who consume lots of water**	• **Voluntary contribution from the users who consume lots of water**
• **Taxes on commercial water users**	• **Taxes on commercial water users**
• Integration of costs into Angkor Wat entry fees	• **Environmental fees collected from visitors arriving at the international airports**
• **Environmental fees collected from visitors arriving at the international airports**	• Carbon credit markets
• Environmental fees for walking trails in Phnom Kulen	• Other sources

Total estimated budgets from the Project Implementations

For the implementation of three above options, the annual estimated fees from PES will be:

- Kbal Chay: 0.9 US$-1.1 million US$
- Phnom Kulen: from 2.9 US$ to 3.9 million US$

Recommendations and Decisions

1. Update of the baseline status
2. Conduction of further studies on various demands such as efficient water consumption technology and loss of water, water costs, and education/outreach
3. Development of watershed management, including budget planning
4. Conduction of analysis on supplementary options or other descriptive options
5. Development of PES-related legal framework or policies
6. **Voluntary schemes on water consumptions from commercial water users should be immediately implemented**

Recommendations and Decisions (Cont.)

7. PES should be integrated into environmental and social funds
8. The water storage capacity of the water bodies or the alternatives should be examined, especially for the consumptions in the dry season
9. Comprehensive policies on implementation of PES should be developed by means of detailed discussions to develop legal framework
10. Other services rather than water supplies, especially functions of species should be studied
11. In order to protect the sources, resources should be mobilized from other sources and more labor forces are used to directly protect the sites ។

National Dialogue on "PES in Cambodia"



Work Road Map

Short-term (6 to 12 months)

- Development of a joint declaration of concerned ministries on PES management mechanism through environmental and social funds or formation of a separate funds
- Development of policy on benefits sharing of PE
- PES promotion in the relevant sectors
- Encouragement and support of development zoning and management plans in the two pilot sites
- Promotion of PES implementation as soon as possible with the upstream communities

Work Road Map

Long terms (2 to 3 years)

- PES schemes will be implemented at the regional level
- Conduction of assessment studies, identification of PES potentials in the landscapes
- Use of PES funds to study the correlation between water sources and water bodies as well as water volumes

Thanks!

For further information:
Email: mmonyrak@gmail.com
Tel.: 078 800 816

សិក្ខាសាលាត្រួតពិនិត្យលទ្ធផលការងារអភិវឌ្ឍន៍ដោយចីរភាពឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០

ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩

វឌ្ឍនភាពនៃការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិរក្សកេសរកូល សុខ អាន ភ្នំគូលែន

លោក ឈិន សុភា
អនុប្រធានការិយាល័យនៃនាយកដ្ឋានជីវៈចម្រុះ
អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព/ ក្រសួងបរិស្ថាន

មាតិកា

- សាវតារ
- គោលបំណង
- ទីតាំង
- បច្ចុប្បន្នភាព
- បញ្ហាប្រឈម និងអនុសាសន៍
- ទិសដៅការងារឆ្នាំ ២០២០

សាថតារ

- **តួនាទី និងការកិច្ច**
  - ប្រកាសលេខ ៤២៦ ប្រ.ក ប.ស្ដ ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងប្រព្រឹត្ត ទៅរបស់នាយកដ្ឋានជីវៈចម្រុះ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិ អភិវឌ្ឍន៍ដោយចីរ ភាព (មាត្រាទី៧ ស្ដីពីការងារអភិរក្សក្រៅតំបន់)
- **បញ្ហា**
  - ការជ្លួញដូរដើមកេសរកូលព្រៃទៅកាន់ប្រទេសជិតខាង
  - ទិន្នន័យ និងការសិក្សាស្រាវជ្រាវលក្ខណៈវិទ្យាសាស្ត្រលើពពួកកេសរកូលនៅមានកម្រិត
- **ឱកាស**
  - កម្ពុជាជាប្រទេសសំបូរដោយកេសរកូលព្រៃ
  - សក្តានុពលសម្រាប់ការអភិវឌ្ឍតំបន់អេកូទេសចរណ៍ ដែលជួយដល់ការបង្កើនចំណូល បន្ថែមដល់ប្រជាជន
  - ជំរុញការសិក្សាស្រាវជ្រាវ ការកសាងសមត្ថភាព និងផ្សព្វផ្សាយដល់សាធារណៈជន



គោលបំណង

- ការសិក្សាស្រាវជ្រាវៈ ដើម្បីកំណត់ឈ្មោះ តួនាទីនៃប្រភេទនីមួយៗ
- ការអភិរក្សៈ ធ្វើការស្តារប្រភេទរងគ្រោះ និងកម្រ
- ការអប់រំៈ ផ្តល់ជាព័ត៌មាន និងចំណេះដឹងបែបវិទ្យាសាស្ត្រពីកេសរកូលព្រៃនៅកម្ពុជា
- ទេសចរណ៍ៈ បង្កើតបន្ថែមនូវទីតាំងទេសចរណ៍សម្រាប់ភ្ញៀវជាតិ និងអន្តរជាតិ

ទីតាំង

❖ **ទីតាំង:** មជ្ឈមណ្ឌលស្រាវជ្រាវ និងអភិរក្សកេសរកូល សុខ អាន ភ្នំគូលែន ចាប់ផ្តើមសាងសង់ក្នុងខែកញ្ញា ឆ្នាំ២០១៨ ដែលមានទីតាំងក្នុងភូមិស្រះខ្ចៅ ឃុំត្បែង ស្រុកបន្ទាយស្រី ខេត្តសៀមរាប ត្រង់ច្រកផ្លូវឡើងឧទ្យានជាតិជ័យវរ្ម័ន-នរោត្តម ភ្នំគូលែន

❖ **ផែនការ:**

- សួនកេសរកូលព្រៃ ទំហំ ២៥ ម x ៣៥ ម = ៨៧៥ម៉ែតការ៉េ
- ថ្នាលបណ្តុះកូនកេសរកូល ទំហំ ១៤ម x ១៤ ម = ១៩៦ម៉ែតការ៉េ

❖ **ផែនការអនាគត:** ទំហំសរុប ១៥០០ហិកតា

ផែនការមេ

❖ **ដំណាក់កាលទី១:**

- សួនកេសរកូលព្រៃ
- ថ្នាលបណ្តុះ

❖ **ដំណាក់កាលទី២:**

- ហាងកាហ្វេ
- ហាងលក់វត្ថុអនុស្សាវរីយ៍
- ធនាគារគ្រាប់ពូជ

❖ **ដំណាក់កាលទី៣:**

- ទីតាំងទស្សនា និងកំសាន្ត

បច្ចុប្បន្នភាព នៃមជ្ឈមណ្ឌល

- បានគូសផែនទីសិក្សាពីការប្រើប្រាស់ដីក្នុងមជ្ឈមណ្ឌល
- ការរៀបចំ និងរចនាផ្នែកខាងក្នុងសួន
- ការរៀបចំថ្នាល ប្រព័ន្ធទឹក ឃ្លាំងជាក់សម្ភារ
- ធ្វើការប្រមូលសំណាករុក្ខជាតិ បាន ១៣០ប្រភេទ (១,៥០០ដើម)
- រៀបចំស្លាកលេខ និងឈ្មោះ (label) ៦០%
- បានបង្កើតសម្ភារៈអប់រំ (leaflet, poster)
- ការគ្រប់គ្រងទិន្នន័យ
- កិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ
- រៀបចំស្លាកព័ត៌មានសម្រាប់មជ្ឈមណ្ឌល
- ការកសាងសមត្ថភាព

ផែនទីនៃការប្រើប្រាស់ដីក្នុងមជ្ឈមណ្ឌល







សួនកេសរក្លែងព្រៃ

ការរៀបចំថ្នាល និងឃ្លាំងជាក់សម្ភារ

ប្រព័ន្ធទឹក



ការសិក្សាស្រាវជ្រាវ និងប្រមូល







ការសិក្សាស្រាវជ្រាវ និងប្រមូល

ការដាក់ឈ្មោះ និងការគ្រប់គ្រងទិន្នន័យ



ផ្ទាំងព័ត៌មានស្តីពីកេសរកូល

ខិតប័ណ្ណព័ត៌មាន



ទស្សនកិច្ចរបស់ថ្នាក់ដឹកនាំក្រសួងបរិស្ថាន

ទស្សនកិច្ចសិក្សារបស់ក្រុមជំនាញមកពី ១១ប្រទេស ក្នុងតំបន់អាស៊ីអាស៊ីហ្វិក ២២ តុលា ២០១៨

ទស្សនកិច្ចសិក្សារបស់ក្រុមការងារ ICC-Angkor



កិច្ចសហប្រតិបត្តិការជាមួយ ICC-Angkor



méthodologiques et de vérifier certains résultats avant la publication du diagnostic, lors du prochain CIC.

c) Encourage cette équipe à proposer dans le cadre de la finalisation du document, une vision territoriale et collaborative, indispensable au développement touristique de Siem Reap /Angkor

7. LES ANTENNES :

Le groupe d'experts :

a) Félicite l'Autorité Nationale APSARA d'avoir entrepris des sondages d'archéologie préventive dans les 12 localités choisies pour l'installation des antennes planifiés.

b) Accepte la proposition technique finale basée sur un système de déploiement rapide (RDS) qui limite les impacts sur le site.

c) Encourage l'autorité nationale APSARA d'explorer des sources d'énergie alternatives comme le solaire, afin d'éviter l'utilisation de groupes électrogènes ou du réseau électrique ;

8. CENTRE SOK AN DE RECHERCHE ET DE CONSERVATION DE L'ORCHIDÉE AU PHNOM KULEN :

Le groupe d'experts :

a) Accueille favorablement l'initiative d'établir un centre de recherche et de conservation des orchidées dans le Parc National des Kulen et en particulier un centre de recherche sur les orchidées ainsi que sur la biodiversité botanique au Cambodge.

b) Apprécie l'extension de ce projet à l'établissement d'une banque de semences pour des espèces arborées remarquables du Cambodge.

9. PARC NATIONAL DES PHNOM KULEN :

Le groupe d'experts :

a) Apprécie la présence et le soutien actif du Ministère de l'Envi[illegible] dans la réalisation d'un inventaire des pl[illegible]es remarquables dans le parc et demande davantage d'informations sur son contenu et son usage futur ;

to verify certain results before the publication of the diagnoses for the next ICC.

c) Encourages the team to propose within the framework of the document, a territorial and collaborative vision, indispensable for tourism development in Siem Reap/Angkor.

7. The ANTENNAS:

The ad hoc group of experts:

a)Congratulates the National Authority APSARA to have undertaken a preventive archaeology survey in the 12 locations chosen for the implementation of the forthcoming antennas;

b) Accepts the final technical proposal based on a Rapid Deployment System (RDS) which limits the impact on the site ;

c)Encourages APSARA National Authority to explore some alternative energy sources such as solar to avoid using generator or grid electricity;

8. SOK AN PHNOM KULEN ORCHID RESEARCH AND CONSERVATION CENTER:

The ad hoc group of experts:

a) Welcomes the initiative of launching an Orchid Research and Conservation Center within the Phnom Kulen National Park and in particular a unique centre of research on orchids as well as on botanical biodiversity in Cambodia;

b) Appreciates the extension of the initiative with a seed bank for remarkable trees of Cambodia.

9. PHNOM KULEN NATIONAL PARK:

The ad hoc group of experts:

a) Appreciates the presence and active supp[illegible] of the Ministry of Environment in realiz[illegible]me and Tree inventories in the [illegible] park re[illegible] information about its contents and fu[illegible]

សហប្រតិបត្តិការជាមួយសារមន្ទីរប៉ារីស និងសួនរុក្ខឧទ្យាន KEW

វគ្គបណ្តុះបណ្តាល និងការកសាងសមត្ថភាព

បញ្ហាប្រឈម

- ការកំណត់ប្រព័ន្ធគ្រប់គ្រងមិនទាន់ច្បាស់លាស់
- កង្វះខាតធនធានមនុស្ស ថវិកា សម្រាប់គាំទ្រដល់កិច្ចដំណើរការរបស់មជ្ឈមណ្ឌល SAKORC
- ការកំណត់ការប្រើប្រាស់ដីមិនទាន់ច្បាស់លាស់
- កង្វះខាតបុគ្គលិក និងអ្នកជំនាញ

ទិសដៅការងារឆ្នាំ២០២០

- ❖ រៀបចំផែនទី និងផែនការមេ នៃមជ្ឈមណ្ឌល SAKORC
- ❖ រៀបចំរចនាសម្ព័ន្ធនៃការគ្រប់គ្រង
- ❖ ពង្រឹងកិច្ចសហប្រតិបត្តិការ ជាមួយមជ្ឈមណ្ឌលជីវៈចម្រុះកូរ៉េ, Kew, សារមន្ទីរប៉ារីស...
- ❖ សិក្សាស្រាវជ្រាវ ប្រមូល កំណត់ប្រភេទ ដាក់ស្លាកសំគាល់ និងការគ្រប់គ្រងទិន្នន័យ
- ❖ រៀបចំសម្ភារអប់រំបន្ថែម
- ❖ ការបង្កាត់ និងដាំក្នុងថ្នាល
- ❖ ការកៀរគរថវិកា និងធនធាន

សូមអរគុណ !
អាសយដ្ឋានទាក់ទង ៖
Email: sopheachhin@gmail.com
Tel:017 877 377

Annual Workshop to Review NCSD 2019 Progress and 2020 PLANs

21 October 2019, Mok Mareth Hall, Ministry of Environment, Phnom Penh

Progress of on the Development of Sok An Phnom Kulen Orchid Research and Conservation Center

Mr. Chhin Sophea

Deputy Office of Department of Biodiversity

General Secretariat of National Council for Sustainable Development/Ministry of Environment

Content

- Background
- Objectives
- Location
- Current Status
- Challenges and Recommendations
- Next Step (2020)

Background

- **Mandate**
  - Declaration No. 426 ប្រ.ក ប.ស្ដ dated 3 December 2015 on Mandates and Operations of Biodiversity Department of General Secretariat of National Council for Sustainable Development (Clause 7- Mandates of Ex-Situ Conservation)
- **Challenges**
  - Wild Orchid trade to neighbouring countries; and
  - Neither sufficient scientific research nor orchid database
- **Opportunities**
  - Richness of Native Wild Orchid throughout the country
  - Potential for eco-tourist development to improve local incomes and contribute to national economics
  - Promotion of scientific research, capacity building, and public awareness-raising



Objectives

- **Research:** **Identify individual species and its factions**
- **Conservation:** **Rescue threatened & endangered species, conserve native species, and reintroduce into natural habitat**
- **Education:** **Provide information and knowledge of Wild Orchid in Cambodia including;**
- **Recreation:** **Serve as entertainment and relaxation areas for national and international tourisms.**

Location of Center

❖ **Location:** **Srah Khvao Village, Thbeng Commune, Banteay Srey District, Siem Reap Province, at the entrance to Phnom Kulen NP**

❖ **Current plan:**

- **Orchid garden: 25 m x 35 m = 875 m^2**
- **Nursery: 14 m x 14 m = 196 m^2**

❖ **Further plan:** **The same location with plan to extend to around 1,500 ha**

Master Plan

❖ **Phase 1:**

- Wild and hybrid orchid garden
- Nursery

❖ **Phase 2:**

- Cafe
- Souvenir shops
- Seed bank and
- Entertainments programs

❖ **Phase 3:**

- Hiking trails to/around Hob mountain

Current Status

- ❖ Finished land use mapping
- ❖ Finished initial internal design
- ❖ Developed nursery and water supply systems
- ❖ Collecting Orchid: 130 species (>1500 ind)
- ❖ Developed leaflets, posters & relevant information
- ❖ Reviewing, verifying and identifying orchid species
- ❖ Cooperating & partnering with orchid communities
- ❖ Labeling collected orchid (>60%)
- ❖ Setting up orchid database (up-to-date)
- ❖ Preparing information board

Land Use Map of Center







Current Wild Orchid Garden

Nursery and Warehouse

Water Supply System



Research and Collections







Research and Collections (Cont.)

Label and Database Management



Information & Education Materials

INFORMATION & EDUCATIONAL MATERIALS (Cont.)



GARDEN VISIT: MoE and APSARA Authority

GARDEN VISIT: Experts from 11 Countries in Asia and Pacific

GARDEN VISIT: ICC-Angkor Expert Team

COLLABORATION: ICC-Angkor Conference



méthodologiques et de vérifier certains résultats avant la publication du diagnostic, lors du prochain CIC.

c) Encourage cette équipe à proposer dans le cadre de la finalisation du document, une vision territoriale et collaborative, indispensable au développement touristique de Siem Reap /Angkor

7. LES ANTENNES :

Le groupe d'experts :

a) Félicite l'Autorité Nationale APSARA d'avoir entrepris des sondages d'archéologie préventive dans les 12 localités choisies pour l'installation des antennes planifiés.

b) Accepte la proposition technique finale basée sur un système de déploiement rapide (RDS) qui limite les impacts sur le site.

c) Encourage l'autorité nationale APSARA d'explorer des sources d'énergie alternatives comme le solaire, afin d'éviter l'utilisation de groupes électrogènes ou du réseau électrique ;

8. CENTRE SOK AN DE RECHERCHE ET DE CONSERVATION DE L'ORCHIDÉE AU PHNOM KULEN :

Le groupe d'experts :

a) Accueille favorablement l'initiative d'établir un centre de recherche et de conservation des orchidées dans le Parc National des Kulen et en particulier un centre de recherche sur les orchidées ainsi que sur la biodiversité botanique au Cambodge.

b) Apprécie l'extension de ce projet à l'établissement d'une banque de semences pour des espèces arborées remarquables du Cambodge.

9. PARC NATIONAL DES PHNOM KULEN :

Le groupe d'experts :

a) Apprécie la présence et le soutien actif du Ministère de l'Envi... dans la réalisation d'un inventaire des pl... ...res remarquables dans le parc et demande davantage d'informations sur son contenu et son usage futur ;

to verify certain results before the publication of the diagnoses for the next ICC.

c) Encourages the team to propose within the framework of the document, a territorial and collaborative vision, indispensable for tourism development in Siem Reap/Angkor.

7. The ANTENNAS:

The ad hoc group of experts:

a) Congratulates the National Authority APSARA to have undertaken a preventive archaeology survey in the 12 locations chosen for the implementation of the forthcoming antennas;

b) Accepts the final technical proposal based on a Rapid Deployment System (RDS) which limits the impact on the site ;

c) Encourages APSARA National Authority to explore some alternative energy sources such as solar to avoid using generator or grid electricity;

8. SOK AN PHNOM KULEN ORCHID RESEARCH AND CONSERVATION CENTER:

The ad hoc group of experts:

a) Welcomes the initiative of launching an Orchid Research and Conservation Center within the Phnom Kulen National Park and in particular a unique centre of research on orchids as well as on botanical biodiversity in Cambodia;

b) Appreciates the extension of the initiative with a seed bank for remarkable trees of Cambodia.

9. PHNOM KULEN NATIONAL PARK:

The ad hoc group of experts:

a) Appreciates the presence and active support of the Ministry of Environment in realizi... ...hone and Tree inventories in the ...k but re... ...informa... about its ...ntents and f... ...se ;

COLLABORATION: International (Kew and Paris Museums)

Capacity Building

Challenges

- Unclear management structure
- Limited capacity (human and financial resources)
- Conflict land use (inside the proposed center)

NEXT STEP (2020)

- ❖ Finalize master plan
- ❖ Develop management structure and operational guideline
- ❖ Partnership and networking with Kew, Paris Museum, Korea, Singapore…
- ❖ Continue collecting and identifying species
- ❖ Educational materials development
- ❖ Scientific capacity building (taxonomy, genetic resource, tissue culture, …)
- ❖ Resources mobilize
- ❖ Marketing

Thank You!
Contact:
Email: sopheachhin@gmail.com
Tel.: 017 877 377

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
អគ្គលេខាធិការដ្ឋាន

របាយការណ៍នៃកិច្ចប្រជុំ
សមិទ្ធិផលសម្រេចបានប្រចាំនៃកិច្ចប្រជុំឆ្នាំ២០១៩
និងទិសដៅបន្តឆ្នាំ២០២០

រាជធានីភ្នំពេញ ខែតុលា ឆ្នាំ២០១៩

មាតិកា

៣.សមិទ្ធិផលសម្រេចបាន ៤
អនុកម្មវិធីទី១៖ ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង និងលើកកម្ពស់ការ អនុវត្តវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ៤
អនុកម្មវិធីទី២ ជំរុញការអនុវត្តឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ១២
អនុកម្មវិធី៣៖អភិរក្សជីវៈចម្រុះ និងជីវសុវត្ថិភាព ១៨
៤. សកម្មភាពចូលរួម កិច្ចប្រជុំ សិក្ខាសាលា បណ្តុះបណ្តាលនៅក្នុង និងក្រៅប្រទេស ២៤
៥. ការគ្រប់គ្រងហិរញ្ញវត្ថុ ២៤
៦.ការរៀនសូត្រនិងបទពិសោធន៍ដែលទទួលបាន ២៤
៧. បញ្ហាប្រឈម ២៥
៨. ទិសដៅអនុវត្តបន្តឆ្នាំ២០២០ ..... ២៥
៨.១ នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ ២៥
៨.២ នាយកដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ២៦
៨.៣ នាយកដ្ឋានសេដ្ឋកិច្ចបៃតង ២៧
៨.៤ នាយកដ្ឋានប្រែប្រួលអាកាសធាតុ ២៨
៨.៥ នាយកដ្ឋានជីវៈចម្រុះ ២៨
៩. សន្និដ្ឋាន ៣០

១. សេចក្តីផ្តើម

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច.) ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤០៣ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។ ក.ជ.អ.ច. បង្កើតឡើងក្នុងគោលបំណងដើម្បីលើកកម្ពស់ការអភិវឌ្ឍដោយចីរភាពសំដៅរក្សាបាននូវតុល្យភាពរវាងសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ៥៩ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។ អគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. មានតួនាទីសម្របសម្រួលការងារប្រចាំថ្ងៃរបស់ ក.ជ.អ.ច. ដែលមាននាយកដ្ឋានចំណុះចំនួន៥ គឺនាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ នាយកដ្ឋានប្រែប្រួលអាកាសធាតុ នាយកដ្ឋានសេដ្ឋកិច្ចបៃតង នាយកដ្ឋានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និងនាយកដ្ឋានដីរៈចម្រុះ។

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ជាស្ថាប័នអន្តរក្រសួងដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាប្រធានកិត្តិយស និងរដ្ឋមន្ត្រីក្រសួងបរិស្ថានជាប្រធាន។ ក.ជ.អ.ច. មានសមាជិកភាពមកពីក្រសួង ស្ថាប័នសំខាន់ៗ ព្រមទាំងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ទាំងអស់។ ក.ជ.អ.ច. មានក្រុមការងារបច្ចេកទេសចំនួន០៧ គឺការប្រែប្រួលអាកាសធាតុ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ដីរៈចម្រុះ ទីក្រុងនិរន្តរភាព ថាមពលនិរន្តរភាព ផលិតកម្ម និងការប្រើប្រាស់ដោយចីរភាព និងថាមពលនុយក្លេអ៊ែរ។ ក្រុមការងារទាំងអស់កំពុងគាំទ្រដល់ការអនុវត្តអាណត្តិការងាររបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយមានការសម្របសម្រួលពីអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច.។

នៅក្នុងឆ្នាំ២០១៩ អគ្គលេខាធិការដ្ឋានបានសម្រេចនូវសមិទ្ធិផលសំខាន់ៗដែលជាកិច្ចខិតខំប្រឹងប្រែងរបស់នាយកដ្ឋានចំណុះឱ្យអគ្គលេខាធិការដ្ឋាន ដោយមានការគាំទ្រ និងសហការពេញលេញពីក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍នានា។

២ . ស្ថិតិមន្ត្រីក្នុងអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច.

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពមានថ្នាក់ដឹកនាំ និងមន្ត្រីបម្រើការងារសរុបចំនួន៩៤នាក់ (ក្នុងនោះមានស្រីចំនួន២៣នាក់) ប្រធាននាយកដ្ឋាន០៥នាក់ អនុប្រធាននាយកដ្ឋាន១៥ នាក់ ប្រធាន/អនុប្រធាន និងមន្ត្រីថ្នាក់ការិយាល័យ៥៩នាក់ មន្ត្រីជាប់កិច្ចសន្យាចំនួន៦នាក់ និងមន្ត្រីស្ម័គ្រចិត្តចំនួន៩នាក់។

ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. រួមមាន ១០នាក់ ដែលដឹកនាំដោយឯកឧត្តមអគ្គលេខាធិការ ០១រូប និងឯកឧត្តម លោកជំទាវអគ្គលេខាធិការរង ០៩រូប ដូចខាងក្រោម៖

- ឯកឧត្តម ទិន ពន្លក អគ្គលេខាធិការ
- ឯកឧត្តម កែន សេរីរដ្ឋា អគ្គលេខាធិការរង
- ឯកឧត្តម វ៉ាន់ មុនីនាថ អគ្គលេខាធិការរង
- លោកជំទាវ ចាន់ សុម៉ាលី អគ្គលេខាធិការរង
- ឯកឧត្តម ភាវ សុវុទ្ធី អគ្គលេខាធិការរង
- ឯកឧត្តម ឯ រុឌ្ឍី អគ្គលេខាធិការរង
- ឯកឧត្តម ជា ចន្ធន៍ធូ អគ្គលេខាធិការរង

- ឯកឧត្តម ប្រាក់ ថាវអមិដា អគ្គលេខាធិការរង
- ឯកឧត្តម យិន សំវ៉ាយ អគ្គលេខាធិការរង
- លោកជំទាវ ងិន លីណា អគ្គលេខាធិការរង។

ប្រធាននាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. មានចំនួន០៥រូប រួមមាន៖

- លោក ម៉ា ច័ន្ទសទ្ធា ប្រធាននាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ
- លោក សុំ ធី ប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ
- លោក ហាក់ ម៉ៅ ប្រធាននាយកដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- លោក ម៉េង មុនីរក្ស ប្រធាននាយកដ្ឋានជីវៈចម្រុះ
- លោក តាំង ម៉េងអៀង ប្រធាននាយកដ្ឋានសេដ្ឋកិច្ចបៃតង។

តារាង ១៖ ចំនួនមន្ត្រីនៅក្នុងនាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច.

នាយកដ្ឋាន	ប្រធាននាយកដ្ឋាន	អនុប្រធាន នាយកដ្ឋាន	ការិយាល័យ មន្ត្រីសរុប	មន្ត្រីជាប់ កិច្ចសន្យា	មន្ត្រី ស្ម័គ្រចិត្ត
នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ	១	៣	១៣	៤	១
នាយកដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា	១	៤	៧	០	០
នាយកដ្ឋានជីវៈចម្រុះ	១	៤	១៣	២	៣
នាយកដ្ឋានប្រែប្រួលអាកាសធាតុ	១	៣	១៤	០	០
នាយកដ្ឋានសេដ្ឋកិច្ចបៃតង	១	១	១២	០	៥
សរុប	**៥**	**១៥**	**៥៩**	**៦**	**៩**

ប្រភព៖ ស្ថិតិមន្ត្រីនាយកដ្ឋាននៃអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. (គិតត្រឹមខែតុលា ឆ្នាំ២០១៩)

៣.សមិទ្ធិផលសម្រេចបាន

អនុកម្មវិធីទី១៖ ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង និងលើកកម្ពស់ការអនុវត្តវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

គោលបំណង៖ គាំទ្រគោលដៅអភិវឌ្ឍន៍ដោយចីរភាព តាមរយៈការសិក្សាស្រាវជ្រាវ និងកសាងសមត្ថភាព ការជំរុញការរៀបចំ និងអនុវត្តគោលនយោបាយ យន្តការគតិយុត្ត និងឧបករណ៍ជំនួយដល់ការធ្វើសេចក្តីសម្រេចចិត្ត ការលើកកម្ពស់ប្រសិទ្ធភាពក្នុងការប្រើប្រាស់មូលធនធម្មជាតិ និងការកាត់បន្ថយការបំពុលបរិស្ថាន។

ចង្កោមសកម្មភាពទី១៖ សេវាគាំទ្រប្រតិបត្តិការរបស់អគ្គលេខាធិការដ្ឋាន ក.ជ.អ.ច.

- បានសម្របសម្រួលចរាចរណ៍លិខិតចេញ-ចូល និងចាត់បញ្ជូនមន្ត្រីក្នុងអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. ដើម្បីចូលរួមកិច្ចប្រជុំនានារបស់ក្រសួង/ស្ថាប័នពាក់ព័ន្ធទាំងក្នុង និងក្រៅប្រទេស
- បានសម្របសម្រួលជាមួយនាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋានដើម្បីរៀបចំលិខិតឆ្លើយតប ផ្តល់យោបល់ និងអនុសាសន៍នានាដែលពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាពនៅកម្ពុជា
- បានសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ និងស្ថាប័នអន្តរជាតិនានាដើម្បីចុះអនុស្សរណៈនៃការយោគយល់រវាងអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. លើការងារអភិវឌ្ឍន៍ដោយចីរភាព និងការគាំទ្របច្ចេកទេសនានាពីដៃគូ ដើម្បីឱ្យអគ្គលេខាធិការដ្ឋានមានលទ្ធភាពពេញលេញក្នុងការបំពេញមុខងាររបស់ខ្លួន
- បន្តផ្តត់ផ្តង់សម្ភារការិយាល័យដល់នាយកដ្ឋានតាមការស្នើសុំដើម្បីជានាដល់ប្រតិបត្តិការរបស់នាយកដ្ឋានចំណុះដំណើរការដោយរលូន និងដោគជ័យ
- បានរៀបចំបេសកកម្មក្នុង និងក្រៅប្រទេសជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានពិនិត្យ និងកែសម្រួលលិខិតចេញរបស់នាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋានដើម្បីជានាថារាល់ទម្រង់លិខិតចេញ ខ្លឹមសារ និងកម្មវត្ថុអនុលោមតាមការណែនាំរបស់ក្រសួងបរិស្ថាន ពិសេសលិខិតដែលចេញទៅក្រសួង ស្ថាប័ននានា
- បានចូលរួម សម្របសម្រួល និងគាំទ្រពេញលេញក្នុងដំណើរការរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីបរិស្ថានអាស៊ានដែលគ្រោងនឹងរៀបចំនៅថ្ងៃទី៧-៩ ខែតុលា ឆ្នាំ២០១៩ នៅខេត្តសៀមរាប
- ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍នានាដើម្បីកៀរគរធនធានហិរញ្ញវត្ថុ និងបច្ចេកទេសក្នុងការអនុវត្តផែនការសកម្មភាព និងគម្រោងនានារបស់អគ្គលេខាធិការដ្ឋាន។

ចង្កោមសកម្មភាពទី២៖ ការងារគ្រប់គ្រង និងសម្របសម្រួលក្រុមប្រឹក្សាអភិវឌ្ឍន៍ដោយចីរភាព

- សហការជាមួយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងក្រសួងផែនការក្នុងការដាក់បញ្ចូលការអភិវឌ្ឍដោយចីរភាព ការអភិវឌ្ឍបៃតង ការប្រែប្រួលអាកាសធាតុ ជីវៈចម្រុះ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាទៅក្នុង**យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤** ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ និងក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ២០១៦-២០៣០ និងគោលនយោបាយជាតិប្រជាជន ផែនការសកម្មភាព និងយុទ្ធសាស្ត្រនានាដែលពាក់ព័ន្ធការងារអភិវឌ្ឍន៍ដោយចីរភាព
- បានសហការជាមួយក្រសួងបរិស្ថាន និងក្រសួងពាក់ព័ន្ធក្នុងការសម្របសម្រួលរៀបចំបញ្ចប់សេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ជីវៈចម្រុះ សេដ្ឋកិច្ចបៃតង វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាព្រមទាំងសទ្ធានុក្រមពាក្យបច្ចេកស័ព្ទដែលបានប្រើប្រាស់ ក្នុងក្រមបរិស្ថាន និងធនធានធម្មជាតិ
- បានរៀបចំគោលការណ៍ណែនាំស្តីពីនីតិវិធីប្រតិបត្តិ (Operations Manual) សម្រាប់គម្រោង ក.ជ.អ.ច. និងរៀបចំគោលការណ៍ណែនាំស្តីពីនីតិវិធីប្រតិបត្តិសម្រាប់មូលនិធិបរិស្ថាន និងសង្គមក្រសួងបរិស្ថាន

- បានសហការជាមួយលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិរៀបចំសេចក្តីព្រាងសេចក្តីណែនាំសម្រាប់បញ្ជាបការអភិវឌ្ឍដោយចីរភាពទៅក្នុងផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ
- កំពុងសម្របសម្រួលអនុវត្តការរៀបចំសេចក្តីព្រាងគោលនយោបាយស្តីពីការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ីនៅកម្ពុជា (Payment for Ecosystem Services "PES") ដោយអនុវត្តសាកល្បងក្នុងតំបន់គោលដៅចំនួន០២ គឺតំបន់ប្រើប្រាស់ច្រើនយ៉ាងព្រៃកទឹកសាបក្បាលឆាយក្នុងខេត្តព្រះសីហនុ និងឧទ្យានជាតិជ័យវរ្ម័ន-នរោត្តម (ភ្នំគូលែន) ក្នុងខេត្តសៀមរាប។ សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិត្រូវបានរៀបចំឡើងប្រកបដោយជោគជ័យ ដោយផ្តោតសំខាន់លើការចែករំលែកបទពិសោធន៍ ការអនុវត្តល្អរបស់បណ្តាប្រទេសជិតខាង និងប្រទេសនៅថ្នាក់តំបន់ដើម្បីជាទុនសម្រាប់ការអនុវត្តន៍ PES នៅកម្ពុជា

ចង្កោមសកម្មភាពទី៣៖ ការអភិវឌ្ឍផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

សកម្មភាព ៣.១ រៀបចំក្រមសីលធម៌សិក្សាស្រាវជ្រាវ

- កំពុងរៀបចំបញ្ចប់ក្រមសីលធម៌ សិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដែលសម្របសម្រួលដោយនាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ។

សកម្មភាព ៣.២ ប្រមូលចងក្រងទិន្នន័យការប្រើប្រាស់បច្ចេកវិទ្យាបៃតងក្នុងប្រទេស

- បាន និងកំពុងស្រាវជ្រាវទិន្នន័យ និងព័ត៌មានទាក់ទងនឹងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា តាមរយៈគេហទំព័រ និងស្ថាប័នពាក់ព័ន្ធ
- បាន និងកំពុងសម្របសម្រួលសហការជាមួយសាកលវិទ្យាល័យមួយចំនួនពិសេសសាលាជាតិកសិកម្មព្រែកលៀបលើគម្រោង «ផលប៉ះពាល់បរិស្ថានពីផលិតកម្មចតុប្បាត និងបក្សីនៅប្រទេសកម្ពុជា»

សកម្មភាព ៣.៣ រៀបចំសិក្ខាសាលាបណ្តុះបណ្តាលលើកកម្ពស់ចំណេះដឹងវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

រូបទី១៖សិក្ខាសាលាលើកកម្ពស់ការយល់ដឹងពីការប្រើប្រាស់ថាមពលនុយក្លេអ៊ែរ និងបច្ចេកវិទ្យាបៃតង

- បានរៀបចំសិក្ខាសាលាលើកកម្ពស់ការយល់ដឹងស្តីពីការប្រើប្រាស់ថាមពលនុយក្លេអ៊ែរ សម្រាប់បម្រើឱ្យគោលបំណងសន្តិភាព និងបច្ចេកវិទ្យាបៃតង នៅសាកលវិទ្យាល័យបាត់ដំបងដែលមាននិស្សិតចូលរួមសរុប២០០នាក់
- បានរៀបចំវេទិកាកិច្ចពិភាក្សាវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាលើកទី២ជាមួយសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្រសួងស្ថាប័ន គ្រឹះស្ថានសិក្សា និងអង្គភាពពាក់ព័ន្ធ ដោយមានអ្នកចូលរួមសរុបប្រមាណជា៤៥០នាក់ កាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ នៅសាលប្រជុំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ កិច្ចពិភាក្សានេះមានគោលបំណងដើម្បី លើកកម្ពស់ការយល់ដឹងជាសាធារណៈ និងពិភាក្សាផ្លាស់ប្តូរមតិយោបល់ស្តីពីភាពចាំបាច់ និងសារៈសំខាន់នៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍ និងការប្រើប្រាស់បច្ចេកវិទ្យានុយក្លេអ៊ែរសម្រាប់គោលបំណងសន្តិភាព ជាពិសេសដើម្បីជំរុញឱ្យយុវជនកម្ពុជាចាប់អារម្មណ៍លើការសិក្សាមុខជំនាញវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានុយក្លេអ៊ែរ
- បានចូលរួមរៀបចំវេទិកាយុវជនជជែកពិភាក្សាអំពីបរិស្ថានឆ្នាំ២០១៩ ស្តីពីបរិស្ថានវិទ្យាសាស្ត្របច្ចេកវិទ្យា

ទំព័រ ៥

និងបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ ដែលនាយកដ្ឋានបានផ្តល់ប្រធានបទ **«ការប្រើប្រាស់បច្ចេកវិទ្យាជាកត្តាដែលនាំឱ្យប្រទេសកម្ពុជាមានការអភិវឌ្ឍដោយចីរភាព»** និងជាសមាជិកគណៈកម្មការនៅវគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រ និងកំពុងបន្តសហការរៀបចំនៅវគ្គផ្តាច់ព្រ័ត្រ។

- បានធ្វើបទបង្ហាញស្តីពីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ក្នុងកម្មវិធីបណ្តុះបណ្តាលមន្ត្រីរាជការ នៃក្រសួងបរិស្ថាន

សកម្មភាព ៣.៤ ចូលរួមកិច្ចប្រជុំថ្នាក់ជាតិ និងអន្តរជាតិនានាពាក់ព័ន្ធនឹងការលើកកម្ពស់ចំណេះដឹងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

- បានចូលរួមសន្និសីទ Vinastom លើកទី១៣ ស្តីពីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានុយក្លេអ៊ែរ នៅប្រទេសវៀតណាម ដែលមានការចូលរួមពីភាគីពាក់ព័ន្ធទាំងស្ថាប័នរដ្ឋាភិបាល និងឯកជនសរុបទាំងអស់ចំនួន១០២នាក់ មកពីបណ្តាប្រទេសនៅអឺរ៉ុប និងអាស៊ីអាគ្នេយ៍។ សន្និសីទនេះមានគោលបំណងដើម្បីប្រមូលផ្តុំអ្នកស្រាវជ្រាវ ខាងផ្នែកវិទ្យាសាស្ត្រ ក៏ដូចជាអ្នកជំនាញបរទេស ដែលបាននិងកំពុងធ្វើការនៅក្នុងវិស័យផ្សេងៗ ក្នុងក្របខណ្ឌវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានុយក្លេអ៊ែរ នៅតាមក្រុមហ៊ុន និងស្ថាប័នរដ្ឋ ដែលបានមកចែករំលែកនូវបទពិសោធន៍ និងលទ្ធផលនៃការស្រាវជ្រាវរបស់ អ្នកជំនាញទាំងនោះ
- បានចូលរួមសន្និសីទលើកទី៧និងកិច្ចប្រជុំពាក់ព័ន្ធស្តីពីយានយន្តប្រើថាមពលអគ្គិសនី នៅប្រទេសហ្វីលីពីន។ សន្និសីទនេះរៀបចំឡើងក្នុងគោលបំណងដើម្បីចែករំលែកនូវព័ត៌មាន និងបទពិសោធន៍នៃការផលិតនិងការដាក់ឱ្យប្រើប្រាស់នូវទោចក្រយានយន្ត និងត្រីចក្រយានយន្តអគ្គិសនីក្នុងប្រទេសនៅតំបន់អាស៊ី។

សកម្មភាព៣.៥ រៀបចំកិច្ចប្រជុំក្រុមការងារថាមពលនុយក្លេអ៊ែរ កម្ពុជា-រុស្ស៊ី និងកិច្ចប្រជុំក្រុមការងារថ្នាក់ជាតិដើម្បីសម្របសម្រួលកិច្ចសហប្រតិបត្តិការលើការប្រើប្រាស់ថាមពលនុយក្លេអ៊ែរសម្រាប់បម្រើឱ្យគោលបំណងសន្តិភាព

- បានចូលរួមរៀបចំទស្សនកិច្ចសិក្សាជូនដល់ក្រុមការងារថ្នាក់ជាតិដើម្បីស្វែងយល់ពីមជ្ឈមណ្ឌលស្រាវជ្រាវបច្ចេកវិទ្យានុយក្លេអ៊ែរ និងពង្រឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់នៅប្រទេសវៀតណាម ដែលទស្សនកិច្ចនេះរៀបចំឡើងដើម្បីស្វែងយល់អំពីដំណើរការសិក្សាស្រាវជ្រាវ និងការប្រើប្រាស់បច្ចេកវិទ្យានុយក្លេអ៊ែរនៅវិទ្យាស្ថានថាមពលបរមាណូវៀតណាម (VINATOM) និងវិទ្យាស្ថានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យានុយក្លេអ៊ែរ (INST) នៅហាណូយ ព្រមទាំងនៅមជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិទ្យាវិទ្យុសកម្ម (VINAGAMMA) នៅហូជីមិញ

រូបទី២៖ ទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលស្រាវជ្រាវបច្ចេកវិទ្យានុយក្លេអ៊ែរនៅប្រទេសវៀតណាម

- បានសម្របសម្រួលគណៈប្រតិភូកម្ពុជាចំនួន១០នាក់ចូលរួមវេទិកាបរមាណូអន្តរជាតិ លើកទី១១ នៅទីក្រុងសូឈី នៃសហព័ន្ធរុស្ស៊ី
- កំពុងរៀបចំកិច្ចប្រជុំក្រុមការងាររួមកម្ពុជា-រុស្ស៊ី លើវិស័យថាមពលនុយក្លេអ៊ែរក្នុងគោលបំណងសន្តិភាព នៅកម្ពុជាលើកទី៣ ចុងឆ្នាំ២០១៩ ដើម្បីពិនិត្យលើវឌ្ឍនភាពការងារ និងសេចក្តីព្រាងកិច្ចព្រមព្រៀងបង្កើតមជ្ឈមណ្ឌលវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានុយក្លេអ៊ែរ។

សកម្មភាព ៣.៦ បន្តចូលរួមអនុវត្តអនុស្សរណៈកម្ពុជា-រុស្ស៊ី និងកម្ពុជា-ចិនលើវិស័យថាមពលនុយក្លេអ៊ែរ

- បានរៀបចំកិច្ចប្រជុំជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យលើសេចក្តីព្រាងកិច្ចព្រមព្រៀងកម្ពុជា-រុស្ស៊ី និងកែសម្រួលខ្លឹមសារស្របតាមស្មារតីនៃកិច្ចប្រជុំ
- បាន និងកំពុងរៀបចំបូកសរុបមតិយោបល់លើសេចក្តីព្រាងកិច្ចព្រមព្រៀងកម្ពុជា-រុស្ស៊ីស្តីពីការសាងសង់មជ្ឈមណ្ឌលវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានុយក្លេអ៊ែរនៅលើទឹកដីកម្ពុជាដើម្បីដូនថ្នាក់ដឹកនាំពិនិត្យ និងសម្រេច ដើម្បីបន្តពិភាក្សាជាមួយភាគីរុស្ស៊ី
- បានផ្សព្វផ្សាយអាហារូបករណ៍ Rosatom សម្រាប់ឆ្នាំ២០១៩-២០២០ ដល់និស្សិត និងបានរៀបចំសំណើសុំពិនិត្យលទ្ធភាពបង្កើនប្រាក់អាហារូបករណ៍បន្ថែម ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ទ្រទ្រង់ជីវភាពនិស្សិតកម្ពុជាសិក្សាផ្នែកបច្ចេកវិទ្យានុយក្លេអ៊ែរនៅសហព័ន្ធរុស្ស៊ី
- បានរៀបចំសំណើសុំក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សម្របសម្រួលចាត់ចែងថវិកាឧបត្ថម្ភចំនួន២០០ដុល្លារអាមេរិក/ខែដើម្បីទ្រទ្រង់ជីវភាពរស់នៅរបស់និស្សិតកម្ពុជាសិក្សាបច្ចេកវិទ្យានុយក្លេអ៊ែរនៅសហព័ន្ធរុស្ស៊ី
- បានចូលរួមសិក្ខាសាលាបណ្តុះបណ្តាលស្តីពី Russian-IAEA Nuclear Energy Management School for Young Professionals នៅសហព័ន្ធរុស្ស៊ី ដែលសិក្ខាសាលាបណ្តុះបណ្តាលនេះមានគោលបំណងបង្ហាញពីបញ្ហាធនធានមនុស្សក្នុងវិស័យថាមពលនុយក្លេអ៊ែរ ផែនការកម្លាំងពលកម្ម វដ្តជីវិតកម្លាំងពលកម្ម ភាពជាអ្នកដឹកនាំ និងសុវត្ថិភាពថាមពលនុយក្លេអ៊ែរ។

ជាមួយភាគីចិន

- កំពុងរៀបចំអនុស្សរណៈនៃការយោគយល់រវាងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងសាជីវកម្មថាមពលនុយក្លេអ៊ែរជាតិចិនស្តីពីការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យថាមពលនុយក្លេអ៊ែរ សម្រាប់បម្រើឱ្យគោលបំណងសន្តិភាព
- បានចូលរួមវគ្គបណ្តុះបណ្តាលយុវជនក្នុងវិស័យឧស្សាហកម្មថាមពលនុយក្លេអ៊ែរឆ្នាំ២០១៩ សម្រាប់ប្រទេសក្នុងតំបន់មេគង្គ-ឡានឆាងនៅប្រទេសចិន ដែលវគ្គបណ្តុះបណ្តាលនេះគឺអនុលោមតាមគម្រោងផ្តួចផ្តើមស្តីពីខ្សែក្រវ៉ាត់ និងផ្លូវ ដើម្បីលើកកម្ពស់ធនធានមនុស្ស និងពង្រឹងកិច្ចសហប្រតិបត្តិក្នុងវិស័យថាមពលនុយក្លេអ៊ែរ ព្រមទាំងបង្កើនចំណេះដឹងនានាដល់យុវជន ដែលជាតំណាងប្រទេសស្ថិតក្នុងតំបន់មេគង្គ-ឡានឆាងលើវិស័យនេះផងដែរ។

រូបទី៣៖ គណៈប្រតិភូចូលរួមពិព័រណ៌បច្ចេកវិទ្យានុយក្លេអ៊ែរ ឆ្នាំ២០១៩ នៅសហព័ន្ធរុស្ស៊ី

ចង្កោមសម្មភាពទី៤៖ ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង

សកម្មភាព៤.១ សម្របសម្រួលរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រនិរន្តរភាពទីក្រុង

- បានសម្របសម្រួល និងរៀបចំកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រសួងស្ថាប័នពាក់ព័ន្ធស្តីពីកម្មវិធីការងាររបស់វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកលប្រចាំកម្ពុជាឆ្នាំ២០១៩-២០២០ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩ នៅទីស្តីការ

ទំព័រ ៧

ក្រសួងបរិស្ថាន ដោយមានអ្នកចូលរួមចំនួនប្រមាណ ១៧នាក់ (ស្ត្រី ០៤នាក់)។ ជាលទ្ធផល កិច្ចប្រជុំបានឯកភាពលើសកម្មភាពអនុវត្តការងារឆ្នាំ២០១៩-២០២០ ដោយក្នុងនោះមាន៖ ១). រៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពីវិធីសាស្ត្ររៀបចំផែនការយុទ្ធសាស្ត្រទីក្រុងនិរន្តរភាពដល់មន្ត្រីរាជរដ្ឋាភិបាល ២).សិក្ខាពីគម្រូអាជីវកម្មនៃការកែច្នៃសំណល់ (កំប៉ុស្តកម្ម និងការកែច្នៃសំណល់ប្លាស្ទិច)នៅខេត្តបាត់ដំបង ៣).សិក្ខាគម្រូអាជីវកម្មសម្រាប់ការគ្រប់គ្រងសំណល់ចេញពីបង្គន់ (Sludge management) នៅខេត្តសៀមរាប ៤).សិក្ខាបុរេសមិទ្ធិលទ្ធភាពស្តីពីប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ខ្នាតតូចនៅតំបន់ជាយក្រុងភ្នំពេញ ៥). បញ្ជ្រាបទស្សនទានការិយាល័យ និងព្រឹត្តិការណ៍បៃតង (Green Office & Green Event) ព្រមទាំងលើកកម្ពស់ឱ្យមានការចាប់ផ្តើមសហគ្រិនភាពបៃតង និង៦).ការសិក្ខាគម្រូអាជីវកម្មសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធកែច្នៃសំណល់រឹងទៅជាថាមពល (Refuse-Derived Fuel (RDF) សម្រាប់ឡដុតឥដ្ឋនៅរាជធានីភ្នំពេញ

- បានសហការរៀបចំសិក្ខាសាលាស្តីពីការសិក្សាបង្កើតគំរូអាជីវកម្មសម្រាប់ខ្សែចង្វាក់ផលិតកម្មនៃការកែច្នៃសំណល់ដោយនិរន្តរភាព ដោយផ្តោតសំខាន់លើសំណល់សរីរាង្គ និងប្លាស្ទិក ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ នៅខេត្តបាត់ដំបង ដែលមានអ្នកចូលរួមពីក្រសួងស្ថាប័ន ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអ្នកសិក្សាស្រាវជ្រាវចំនួន៥៧នាក់ ស្ត្រី១៨នាក់។ លទ្ធផលសំខាន់ៗពីសិក្ខាសាលាគឺបង្កើតគំរូអាជីវកម្មមួយដែលមានផលចំណេញ តាមរយៈការកែលំអខ្សែចង្វាក់ផលិតកម្ម ហើយសេចក្តីព្រាងនៃលទ្ធផលសិក្សានឹងត្រូវពិភាក្សាជាមួយអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. និងដៃគូពាក់ព័ន្ធ
- បានរៀបចំកិច្ចប្រជុំលើកទី១ ក្រុមការងារបច្ចេកទេសទីក្រុងនិរន្តរភាព ដែលមានអ្នកចូលរួមពីក្រសួងស្ថាប័ន និងរដ្ឋបាលរាជធានីខេត្តពាក់ព័ន្ធ ប្រមាណ៣០នាក់ ស្ត្រីចំនួន០៥នាក់។ ក្រុមការងារបានពិនិត្យ និងសម្រេចលើតួនាទី ភារកិច្ច និងផែនការសកម្មភាពបន្តរបស់ក្រុមការងារបច្ចេកទេស និងបានទទួលការអនុម័តជាផ្លូវការ តាមរយៈប្រកាសលេខ០១២ ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ ២០១៩ ក.ជ.អ.ច.។ នាយកដ្ឋានសេដ្ឋកិច្ចបៃតង ដែលជាលេខាធិការដ្ឋានក្រុមការងារបាន និងកំពុងរៀបចំកិច្ចប្រជុំលើកទី២ ដែលគ្រោងរៀបចំនៅខែតុលា ឆ្នាំ២០១៩
- បានសម្របសម្រួលរៀបចំពិធីប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ឆ្នាំ២០១៨-២០៣០ ដែលមានអ្នកចូលរួមពីក្រសួងស្ថាប័ន អង្គភាពនៃរដ្ឋបាលរាជធានីភ្នំពេញ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអ្នកសិក្សាស្រាវជ្រាវសរុប ១៤៨នាក់ ស្ត្រី២៥នាក់។ ឯកសារនេះបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការ និងអាចរកបានតាមរយៈ គេហទំព័ររបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល
- បាន និងកំពុងសម្របសម្រួលរៀបចំបោះពុម្ពផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព ឆ្នាំ២០១៨-២០៣០ សម្រាប់ក្រុងកែប ព្រះសីហនុ បាត់ដំបង សៀមរាប កំពង់ចាម ត្បូងឃ្មុំ និងក្រុងបាវិត
- កំពុងអនុវត្តគម្រោងគោលការណ៍ណែនាំ និងវិញ្ញាបនបត្រកម្មអគារបៃតងនៅកម្ពុជាដែលមានវឌ្ឍនភាពសំខាន់ៗ៖ ១). បានរៀបចំប្រជុំបើកគម្រោងទៅនាថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩ នៅរាជធានីភ្នំពេញ ដោយមានអ្នកចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ នឹងអ្នកពាក់ព័ន្ធរបស់គម្រោងសរុប២០នាក់ ស្ត្រី ០៥នាក់ (២) កិច្ចប្រជុំលើកដំបូង (Kick off

Meeting) លើផ្នែកបច្ចេកទេស ជាមួយវិទ្យាស្ថានសំណង់ស៊ីវិល និងបច្ចកវិទ្យាសំណង់កូរ៉េ (Korea Institute of Civil Engineering and Building Technology-KICT) ដើម្បីពិនិត្យមើលកិច្ចសហការអនុវត្តគម្រោងអគារបៃតង ៣). រៀបចំជ្រើសរើសទីប្រឹក្សាគម្រោង៤).បានប្រមូលឯកសារពាក់ព័ន្ធ និងរៀបចំសេចក្តីព្រាងការវិភាគពាក់ព័ន្ធនឹងអគារបៃតងនៅកម្ពុជា និង ៥).បានរៀបចំកិច្ចប្រជុំលើកទី១ របស់ក្រុមការងារបច្ចេកទេសគម្រោងស្តីពីគោលការណ៍ណែនាំ និងវិញ្ញាបនបត្រកម្មអគារបៃតងនៅកម្ពុជា ដែលបានរៀបចំទៅនាថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ នៅរាជធានីភ្នំពេញ ដោយមានអ្នកចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ នឹងអ្នកពាក់ព័ន្ធរបស់គម្រោងសរុប២០នាក់ ស្ត្រី០៤រូប ដើម្បីពិនិត្យ និងឯកភាពលើតួនាទី និងភារកិច្ចរបស់ក្រុមការងារបច្ចេកទេសគម្រោង

- បានសហការជាមួយវិទ្យាស្ថានអភិវឌ្ឍន៍បៃតង សកលរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំបច្ចេកទេសស្តីពីការិយាល័យបៃតង (Green Office) និងវេទិកាបៃតង (Green Event)។

សកម្មភាព៤.២ បណ្តុះបណ្តាល និងផ្សព្វផ្សាយការងារពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព

- បានសម្របសម្រួលរៀបចំសិក្ខាសាលាបណ្តុះបណ្តាលស្តីពី"ការបញ្ជ្រាប និងលើកកម្ពស់ការយល់ដឹងពីវិញ្ញាបនបត្របៃតង"នៅមន្ទីរបរិស្ថាន ខេត្តបាត់ដំបង ដោយមានការចូលរួមពីមន្ត្រីជំនាញមកពីសាលាខេត្ត មន្ទីរបរិស្ថាន មន្ទីរពាណិជ្ជកម្ម មន្ទីររ៉ែ និងថាមពល និងមន្ទីរទេសចរណ៍ និងសិប្បកម្មនៃខេត្តទាំង៥ គឺខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង។ គោលបំណង នៃសិក្ខាសាលាបណ្តុះបណ្តាលនេះ ដើម្បី (១)ពង្រឹងសមត្ថភាពបន្ថែមរបស់សិក្ខាកាមលើទស្សនទាន និងបទពិសោធន៍ ការអភិវឌ្ឍសេដ្ឋកិច្ចបៃតងនៅកម្ពុជា និងសកលនវានុវត្តន៍បរិស្ថាន ស្លាកសញ្ញាបរិស្ថាន និង គោលដៅអភិវឌ្ឍន៍ដោយចីរភាពរបស់កម្ពុជាក្នុងវិស័យបរិស្ថាន និង២)ផ្តល់ជាវេទិកាពិភាក្សាអំពីបញ្ហាប្រឈមនានាដែលអាចគំរាមកំហែងដល់ការសម្រេចនូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា។

សកម្មភាព៤.៣ ជំរុញការប្រើប្រាស់ និងការផលិតដោយចីរភាព

- បានចុះអនុស្សរណៈនៃការយោគយល់រវាងមជ្ឈមណ្ឌលនវានុវត្តន៍អេកូសម្រាប់ជំនួបសហគ្រាសធុនតូច និងមធ្យមអាស៊ី-អឺរ៉ុប (ASEM SMEs Eco-Innovation) និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ស្តីពី កិច្ចសហប្រតិបត្តិការលើនវានុវត្តន៍អេកូសម្រាប់ជំនួបអាស៊ីអឺរ៉ុបលើគម្រោងកសាងសមត្ថភាព និងលើកកម្ពស់ការអភិវឌ្ឍឧស្សាហកម្មដែលបញ្ចេញកាបូនទាប
- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការបង្កើតមូលដ្ឋានគ្រឹះសម្រាប់ប្រព័ន្ធស្លាកសញ្ញាអេកូសម្រាប់មន្ត្រី និងការសាងសមត្ថភាពនវានុវត្តន៍អេកូសម្រាប់សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជាចំនួនពីរលើកនៅឆ្នាំ២០១៧ ដោយមានសិក្ខាកាមចូលរួមសរុប១៥០នាក់
- បានចូលរួម និងធ្វើបទបង្ហាញក្នុងសិក្ខាសាលាបណ្តុះបណ្តាលស្តីពីការរៀបចំស្លាកសញ្ញាបរិស្ថានសម្រាប់កម្ពុជា នៅទីក្រុងប៉េកាំង ប្រទេសចិន ចំនួន២លើក និងកិច្ចប្រជុំផ្ទៀងផ្ទាត់លទ្ធផលនៅភ្នំពេញចំនួន ០១លើក ដោយមានសមាជិកចូលរួមសរុបចំនួន ៨០នាក់
- បានធ្វើបទបង្ហាញស្តីពីស្ថានភាព និងស្ថាប័នទទួលបន្ទុកស្លាកសញ្ញាអេកូរបស់ប្រទេសកម្ពុជាក្នុងសន្និសីទថ្នាក់ជាតិរបស់អង្គការ NTFP-EP ដោយមានអ្នកចូលរួមសរុបចំនួន១៣០នាក់
- បានដាក់គម្រោងសំណើស្តីពី Efficiency of Green Eco-Labeling in Cambodia ទៅរដ្ឋាភិបាលជប៉ុនតាមរយៈស្ថានទូតជប៉ុនប្រចាំនៅកម្ពុជា

- បានសម្របសម្រួលជាមួយ GIZ ថ្នាក់តំបន់លើកិច្ចសហការជំរុញការអនុវត្តកម្មវិធីការប្រើប្រាស់ និងការផលិតដោយចីរភាពក្នុងតំបន់ ដែលក្នុងនោះរួមមានការរៀបចំគោលនយោបាយពាក់ព័ន្ធ និងការពង្រឹងសមត្ថភាពមន្ត្រីរាជរដ្ឋាភិបាល។

សកម្មភាព៤.៤ សិក្សាប្រសិទ្ធភាពសេដ្ឋកិច្ច (Economic Efficiency) ក្នុងការអភិវឌ្ឍថាមពល និងការកាត់បន្ថយការបំពុលបរិស្ថាន

៤.៤.១ ការងារគោលនយោបាយពាក់ព័ន្ធនឹងយានយន្ត

- បានបង្កើត និងប្រជុំក្រុមការងារអន្តរក្រសួងដែលមានសមាសភាពមកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានគោលនយោបាយ) ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងពាណិជ្ជកម្ម ក្រសួងបរិស្ថាន ក្រសួងរ៉ែ និងថាមពល និង ក.ជ.អ.ច. ដើម្បីសិក្សាវាយតម្លៃបទប្បញ្ញត្តិ និងគោលនយោបាយសារពើពន្ធសម្រាប់យានយន្តដឹកជញ្ជូនផ្លូវគោកនៅកម្ពុជា និងរៀបចំអនុសាសន៍ ស្របតាមគោលដៅគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា សំដៅ ១) កាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ការបំពុលផលប៉ះពាល់លើសុខភាពដែលកើតចេញពីយានយន្តដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសកម្ពុជា និងកែលម្អសុវត្ថិភាពចរាចរណ៍ ២) កាត់បន្ថយតម្រូវការ និងការពឹងផ្អែកលើថាមពល តាមរយៈការកាត់បន្ថយការនាំចូលប្រេងឥន្ធនៈដោយបង្កើនប្រសិទ្ធភាពថាមពលជាអតិបរិមាពីយានយន្តនិងលើកកម្ពស់បច្ចេកវិទ្យាស្អាត ឧទាហរណ៍ យានយន្ត ប្រើប្រាស់ថាមពលអគ្គិសនី ៣) រក្សាបាននូវលទ្ធភាពទិញយានយន្តសម្រាប់ក្រុមមនុស្សដែលមានចំណូលកម្រិតមធ្យម និងកម្រិតទាប និង ៤) មានឥទ្ធិពលវិជ្ជមានចំពោះការកៀរគរចំណូលជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា
- លទ្ធផលនៃការសិក្សា ក្រុមការងារអន្តរក្រសួងបានរៀបចំនូវអនុសាសន៍សំខាន់ៗ សម្រាប់ធ្វើកំណែទម្រង់ក្របខណ្ឌគោលនយោបាយសារពើពន្ធស្របតាមគោលដៅគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាដោយក្នុងនោះមានអនុសាសន៍សម្រាប់រយៈពេលខ្លី គឺគួរធ្វើវិសោធនកម្មអត្រាពន្ធគយ និងអាករពិសេសសម្រាប់យានយន្តដែលជាប់ពន្ធគយតិច(LDVs) ដោយមាន**៣សេណារីយ៉ូ**ដូចតទៅ៖
  - **សេណារីយ៉ូទី១ (កែសម្រួលអត្រាពន្ធគយ និងអាករពិសេសដោយផ្អែកលើទំហំម៉ាស៊ីន)** ចំពោះសេណារីយ៉ូនេះការសិក្សាបង្ហាញថាចំណូលពន្ធរបស់រដ្ឋអាចនឹងមានការធ្លាក់ចុះធៀបនឹងសេណារីយ៉ូធុរកិច្ចតាមទម្លាប់ធម្មតា។ ការធ្លាក់ចុះនេះបណ្តាលមកពីការធ្លាក់ចុះចំណូលពន្ធដែលបានមកពីរថយន្តទេសចរណ៍មានប្រមាណ ៦៦% នៃចំនួនយានយន្តជាប់ពន្ធគយតិច បើទោះជាអាចមានការកើនចំណូលពន្ធពីការនាំចូលរថយន្តដឹកអ្នកដំណើរ និងរថយន្តធំៗ
  - **សេណារីយ៉ូទី២ (កែសម្រួលអត្រាពន្ធគយ និងអាករពិសេសដោយផ្អែកលើប្រភេទប្រេងឥន្ធនៈ)** ក្នុងសេណារីយ៉ូនេះ ការសិក្សាបង្ហាញថាអាចនឹងមានការកើនឡើងចំណូលពន្ធដែលបានមកពីរថយន្តដឹកអ្នកដំណើរ និងឡានធំៗ

រូបទី៤៖ សិក្ខាសាលាស្តីពីការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រក្នុងការរៀបចំផែនការវិស័យថាមពល

(Trucks) ដោយសារប្រភេទឡានទាំងនេះភាគច្រើនប្រើប្រេងម៉ាស៊ូត ដែលត្រូវបង់ពន្ធខ្ពស់ ខណៈដែលចំណូលពន្ធពីរថយន្តទេសចរណ៍នៅរក្សាក្នុងកម្រិតដដែល

- **សេណារីយ៉ូទី៣ (កែសម្រួលអត្រាពន្ធគយ និងអាករពិសេសដោយផ្អែកលើទំហំម៉ាស៊ីន និងប្រភេទប្រេងឥន្ធនៈ)៖** មានន័យថា បន្តយពន្ធសម្រាប់រថយន្តដែលប្រើប្រេងឥន្ធនៈស្អាត (Clean Fuel) និងជាមួយគ្នាតម្លើងពន្ធលើរថយន្តដែលមានទំហំម៉ាស៊ីនធំ។ ចំពោះសេណារីយ៉ូនេះ ការសិក្សាបង្ហាញថានឹងមានការកើនឡើងចំណូលពន្ធរបស់រដ្ឋពីការនាំចូលយានយន្តដែលជាប់ពន្ធគយតិច ចាប់ពីឆ្នាំ ២០១៦ ទៅដល់ឆ្នាំ២០៥០។ ចំពោះអនុសាសន៍សម្រាប់រយៈពេលមធ្យមគឺវិធានការសក្តានុពលដើម្បីលើកកម្ពស់យានយន្តដែលមានប្រសិទ្ធភាពថាមពលពេញលេញកាន់តែច្រើនឡើង រួមមាន៖(១). បិទស្លាកសញ្ញាសន្សំសំចៃផ្នែកសេដ្ឋកិច្ចលើឥន្ធនៈ (Fuel Economy Labelling) និង(២).កំណត់អាយុកាលឬទឹតបន្តឹងស្តង់ដារ EURO Fuel សម្រាប់ការនាំចូលយានយន្ត។

- ក្រុមការងារអន្តរក្រសួងបានធ្វើរបាយការណ៍ស្តីពីវាយតម្លៃបទប្បញ្ញត្តិ និងគោលនយោបាយសារពើពន្ធសម្រាប់យានយន្តដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសកម្ពុជា ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៤.៤.២ ការងារគោលនយោបាយពាក់ព័ន្ធនឹងថាមពលកកើតឡើងវិញ (ថាមពលពន្លឺព្រះអាទិត្យ)

- បានបង្កើតក្រុមការងារបច្ចេកទេសវាយតម្លៃសក្តានុពលថាមពលពន្លឺព្រះអាទិត្យដើម្បីពិនិត្យផ្តល់យោបល់និងអនុសាសន៍ ក្នុងការរៀបចំគោលនយោបាយពាក់ព័ន្ធនឹង ថាមពលកកើតឡើងវិញ និងចងក្រងអនុវត្តគោលនយោបាយយុទ្ធសាស្ត្រ ផែនការសកម្មភាព ពាក់ព័ន្ធនឹងថាមពលកកើតឡើងវិញ។ ក្រុមការងារនេះបានប្រជុំចំនួនពីរលើករួចមកហើយ និងកំពុងពិនិត្យ និងផ្តល់យោបល់លើការសិក្សាចំនួន៣រួមមាន៖ ១) សេចក្តីព្រាងរបាយការណ៍ស្តីពីការសិក្សាវាយតម្លៃសក្តានុពល ថាមពលពន្លឺព្រះអាទិត្យ ២) ការឆ្លើយតបទៅនឹងបញ្ហាប្រឈមវិស័យថាមពលរបស់កម្ពុជា និងតួនាទីរបស់ថាមពលនិរន្តរភាព និង ៣) ការស្នើឡើងវិធីសាស្ត្រសម្រាប់ការវាយតម្លៃហ៊ានលើការខាតបង់សេដ្ឋកិច្ចបណ្តាលមកពីភាពអាក់រអួលក្នុងការផ្គត់ផ្គង់អគ្គិសនីពីបណ្តាញអគ្គិសនីជាតិ

- បានសម្របសម្រួលជាមួយអង្គការ UNDP បោះពុម្ពរបាយការណ៍ស្តីពីការកាត់បន្ថយហានិភ័យលើការវិនិយោគថាមពលកកើតឡើងវិញនៅកម្ពុជា (Derisking Renewable Energy Investment-DREI) និងកំពុងត្រៀមរៀបចំកម្មវិធីប្រកាសជាក់ឱ្យប្រើប្រាស់ជាផ្លូវការលើរបាយការណ៍នាខែតុលាឆ្នាំ២០១៩

- បានបញ្ចប់របាយការណ៍ស្តីពីការវាយតម្លៃសក្តានុពលអភិវឌ្ឍន៍បៃតងនៅកម្ពុជា (Green Growth Pontential Assessment Cambodia Counry Report)

រូបថតទី៥៖កិច្ចប្រជុំក្រុមការងារបច្ចេកទេសវាយតម្លៃសក្តានុពលថាមពលពន្លឺព្រះអាទិត្យនៅកម្ពុជា

- បានសម្របសម្រួលរៀបចំបញ្ចប់របាយការណ៍ស្តីពីផលប៉ះពាលសេដ្ឋកិច្ច សង្គម និងបរិស្ថាននៃការជំរុញវិស័យឧស្សាហកម្មបៃតងនៅកម្ពុជា (The Economic, Social and Environmental Impacts of Greening Industrial Sector in Cambodia)
- បានសម្របសម្រួលជាមួយ UNDP ក្នុងការតម្លើងបន្ទះសូឡាថាមពលពន្លឺព្រះអាទិត្យលើដំបូលអគារក្រសួងបរិស្ថាន។

សកម្មភាព ៤.៥ កសាងសមត្ថភាព និងចូលរួមកិច្ចប្រជុំក្រុមការងាររបស់ ASEAN

- បានចូលរួមកិច្ចប្រជុំអាស៊ាន និងអាស៊ីអឺរ៉ុបចំនួន ២លើក៖ ១) កិច្ចប្រជុំពាក់កណ្តាលអាណត្តិលើកទី១៨ "18th AFEO Mid-term Meeting" នៃអង្គការសហព័ន្ធវិស្វកម្មអាស៊ាននៅ រាជធានីបង់ដា សេរីបេហ្គាវ៉ាន់ប្រទេសប្រ៊ុយណេដោយបានធ្វើបទបង្ហាញស្តីពីវឌ្ឍនភាព ការរៀបចំទីក្រុងនិរន្តរភាពនៅកម្ពុជា
- បានចូលរួមសិក្ខាសាលាថ្នាក់តំបន់លើកទីពីរបស់កម្មវិធីទីក្រុងឈានមុខការអភិវឌ្ឍដោយចីរភាពអាស៊ាន (2nd Regional Workshop of the ASEAN SDGs Frontrunner Cities Programme-SDGs-FC) និងកិច្ចប្រជុំលើកទី១៧ នៃក្រុមការងារអាស៊ានស្តីពីទីក្រុងនិរន្តរភាពបរិស្ថាន (17th Meeting of ASEAN Working Group on Environmentally Sustainable Cities (AWGESC)) នៅទីក្រុង Vientiane ប្រទេសឡាវ

អនុកម្មវិធីទី២ ជំរុញការអនុវត្តឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

ការប្រែប្រួលអាកាសធាតុបានក្លាយទៅជាប្រធានបទអាទិភាពចម្បងមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ដូចមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល។ សកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុមាននៅក្នុងគ្រប់ទិដ្ឋភាព ដូចជាការពង្រឹងសមត្ថភាពស្ថាប័ននិងសមត្ថភាពបច្ចេកទេសការរៀបចំផែនការ និងគោលនយោបាយ ការងារសិក្សាស្រាវជ្រាវ អប់រំ និងលើកកម្ពស់ការយល់ដឹង ការអនុវត្តកាតព្វកិច្ចក្រោមអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ការអនុវត្តយន្តការអភិវឌ្ឍន៍ស្អាតក្រោមពិធីសារក្យូតូ និងបណ្តាគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ផ្សេងៗទៀតការអនុវត្តគម្រោងបន្សាំនានា ដោយរួមទាំងបណ្តាគម្រោងស្នើឡើងក្រោមកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការងារសម្របសម្រួលនិងសហប្រតិបត្តិការអន្តរជាតិ ការចូលរួមចរចានៅថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ និងការកៀរគរធនធានសម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

រូបទី៦៖ ប្រតិភូកម្ពុជាចូលរួមសន្និសីទបណ្តារដ្ឋភាគីជាសមាជិកអនុសញ្ញាUNFCCCលើកទី២៤ (COP-24) នៅប្រទេសប៉ូឡូញ

នាយកដ្ឋានប្រែប្រួលអាកាសធាតុជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. ដោយមានភារកិច្ចលើកកម្ពស់ការយល់ដឹង កសាងសមត្ថភាព បញ្ជ្រាបការប្រែប្រួលអាកាសធាតុ រៀបចំរបាយការណ៍ជាតិ និងរៀបចំក្របខណ្ឌសម្របសម្រួល កៀរគរហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ។ គោលបំណងនៃអនុកម្មវិធីទី២ (ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ) គឺរួមចំណែកគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាព ក្រោមលក្ខខណ្ឌការប្រែប្រួលអាកាសធាតុ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។

ចង្កោមសកម្មភាពទី៥៖ អប់រំផ្សព្វផ្សាយ ព័ត៌មាន លើកកម្ពស់ការយល់ដឹង និងបញ្ជ្រាបការងារប្រែប្រួលអាកាសធាតុ

សកម្មភាពទី៥.១ កិច្ចប្រជុំក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ

- បានរៀបចំកិច្ចប្រជុំលើកទី៤ ក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ និងដៃគូអភិវឌ្ឍន៍នៅដើម្បីផ្សព្វផ្សាយលទ្ធផលសន្និសីទលើកទី២៤ នៅប្រទេសប៉ូឡូញ ការយល់ដឹងអំពីស្ថានភាពនៃការដាក់បញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុង NSDP បច្ចុប្បន្នភាពគម្រោងមូលនិធិអាកាសធាតុបៃតង និងបច្ចុប្បន្នភាពសកម្មភាពសម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ
- បានរៀបចំកិច្ចប្រជុំលើកទី៥ ក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ ដើម្បីពិភាក្សា ពិគ្រោះយោបល់ និងប្រមូលធាតុចូល លើរបាយការណ៍ពាក់កណ្តាលអាណត្តិ CCCSP និងលើការរៀបចំផែនទីបង្ហាញផ្លូវការអនុវត្ត NDC
- បានរៀបចំកិច្ចប្រជុំលើកទី៦ ក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ និងដៃគូអភិវឌ្ឍន៍ បានពិភាក្សាទៅលើផែនទីបង្ហាញផ្លូវការអនុវត្ត NDC គោលការណ៍ និងនីតិវិធីនៃការស្នើសុំជំនួយពីមូលនិធិអាកាសធាតុបៃតងនិងបច្ចុប្បន្នភាពនៃគម្រោងទន្លេមេគង្គក្រោមរបស់ធនាគារពិភពលោក។

សកម្មភាពទី៥.២ ចូលរួមវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សន្និសីទអន្តរជាតិ

មន្ត្រីនាយកដ្ឋានប្រែប្រួលអាកាសធាតុ បានចូលរួមកិច្ចវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សន្និសីទអន្តរជាតិ នៅក្រៅប្រទេសចំនួន៤៥លើករួមមាន៖

- បានចូលរួមសិក្ខាសាលាចែករំលែកចំណេះដឹងថ្នាក់តំបន់ស្តីពី "យន្តការទីផ្សារកាបូនអន្តរជាតិ និងតម្លាភាពក្រោមកិច្ចព្រមព្រៀងទីក្រុងប៉ារីស" នៅទីក្រុងបាងកក ប្រទេសថៃ
- បានចូលរួមសិក្ខាសាលាថ្នាក់តំបន់ស្តីពីយេនឌ័រ សំដៅទៅលើការវិនិយោគលើការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ នៅប្រទេសថៃ
- បានចូលរួមវេទិកាផែនការជាតិបន្សុំនៅទីក្រុងសានស៊ីបារ ប្រទេសតង់ហ្សានី
- បានចូលរួម Inception Workshop on the PaSTI-JAIF Project ប្រទេសថៃ
- បានចូលរួមសិក្ខាសាលាស្តីពីភាពជាអ្នកដឹកនាំសម្រាប់សមភាព យេនឌ័រ ប្រទេសថៃ
- បានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាលមូលនិធិអាកាសធាតុបៃតងលើកទី២២ នៅសាធារណរដ្ឋកូរ៉ែ
- បានចូលរួមកិច្ចប្រជុំលើកទី១៥នៃគណៈកម្មាធិការបន្សុំ នៅទីក្រុងបោន ប្រទេសអាល្លឺម៉ង់
- បានចូលរួមសិក្ខាសាលាថ្នាក់តំបន់ស្តីពី"ការការពារសង្គមពីហានិភ័យអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ" "Social Protection, Climate Risk and Disaster Management" នៅទីក្រុងបាងកក ប្រទេសថៃ
- បានចូលរួមសិក្ខាសាលា«Measurement Reporting and Verification (MRV) Biennial Update Reports (BUR) and National Communications (NCs)» នៅទីក្រុងបាងកក ប្រទេសថៃ
- បានចូលរួមសិក្ខាសាលាស្តីGEF Expanded Constiuency សម្រាប់បណ្តាប្រទេសអាស៊ីខាងកើត អាស៊ីខាងត្បូង និងប្រទេសចិន នៅប្រទេសម៉ុងហ្គោលី
- បានចូលរួមសិក្ខាសាលាស្តីពី ភាពជាដៃគូស្តីពីតម្លាភាពក្រោមកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ នៅទីក្រុងហ្សាការតា ប្រទេសឥណ្ឌូនេស៊ី
- បានចូលរួមកិច្ចប្រជុំក្រុមការងារបរិស្ថាននៃមហាអនុតំបន់មេគង្គប្រចាំឆ្នាំលើកទី២៤ នៅទីក្រុងគុនមីង ខេត្តយូណាន សាធារណរដ្ឋប្រជាមានិតចិន
- បានចូលរួមកិច្ចប្រជុំថ្នាក់តំបន់ស្តីពីការងាររួមទីក្រុង Koronivia ស្តីពីកសិកម្ម នៅទីក្រុងបាងកក ប្រទេសថៃ

- បានចូលរួមក្នុងវេទិការសប្តាហ៍នៃការបន្សាំនឹងការប្រែប្រួលអាកាសធាតុសកល-កូរ៉េ នៅទីក្រុងសុងដូ សាធារណរដ្ឋកូរ៉េ
- បានចូលរួមកិច្ចប្រជុំថ្នាក់តំបន់ស្តីពី "ស្ថិតិយេនឌ័រក្នុងវិស័យប្រែប្រួលអាកាសធាតុនិងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ" និងកិច្ចប្រជុំជំនាញស្តីពី"ស្ថិតិនៃគ្រោះមហន្តរាយ" នៅទីក្រុងបាងកក ប្រទេសថៃ
- បានចូលរួមកិច្ចប្រជុំលើកទី៤៩របស់ក្រុមប្រឹក្សាអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (IPCC) ដែលអនុម័ត របាយការណ៍វិធីសាស្ត្រ កែសម្រួលឆ្នាំ២០១៩ ចំពោះគោលការណ៍ណែនាំស្តីពីសារពើភ័ណ្ឌផ្ទះកញ្ចក់ នៅប្រទេសជប៉ុន
- បានចូលរួមកិច្ចប្រជុំលើកទី១ របស់គណៈកម្មការដឹកនាំគម្រោងស្តីពី ការពង្រឹង អំណាចស្ត្រីសម្រាប់សង្គមដែលធន់នឹងអាកាសធាតុ នៅទីក្រុងបាងកក ប្រទេសថៃ
- បានចូលរួមសិក្ខាសាលាបច្ចេកទេសលើកទី៣ ស្តីពីការអនុវត្តគំនិតផ្តួចផ្តើមកសាងសមត្ថភាពសម្រាប់តម្លាភាព នៅទីក្រុងរ៉ូម ប្រទេសអ៊ីតាលី
- បានចូលរួមសិក្ខាសាលាស្តីពីការពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុ នៃសមាជិក អាស៊ាន តាមរយៈការចែករំលែកបទពិសោធន៍ និងមេរៀនស្តីពីវឌ្ឍនភាពនៃសកម្មភាព បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ នៅខេត្តឈៀងរៃ ប្រទេសថៃ
- បានចូលរួមសិក្ខាសាលាបណ្តុះបណ្តាលម៉ូដែលការប្រែប្រួលអាកាសធាតុស្តីពីម៉ូដែល S8 SI-CAT សម្រាប់ ការវាយតម្លៃផលប៉ះពាល់ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ ផែនការបន្សាំ និងផែនការទីក្រុង នៅទីក្រុងបាងកក ប្រទេសថៃ
- បានចូលរួមកិច្ចប្រជុំក្រុម LDCs និង G77 and China និងសន្និសីទសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុSB50នៅទីក្រុងបោន អាល្លឺម៉ង់
- បានចូលរួមសន្និសីទស្តីពីជីវៈចម្រុះលើកទី៩ នៅទីក្រុងTrondheim ប្រទេសណ័រវ៉ែ
- បានចូលរួមកម្មវិធីបច្ចេកវិទ្យាប្រែប្រួលអាកាសធាតុកូរ៉េឆ្នាំ២០១៩ នៅទីក្រុងសេអ៊ូល កូរ៉េ
- បានចូលរួមសិក្ខាសាលាលើកទី១៧ស្តីពី "សារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់នៅអាស៊ី ដែលបានប្រព្រឹត្តនៅប្រទេសសឹង្ហបុរី
- បានចូលរួមសិក្ខាសាលាបណ្តុះបណ្តាលសម្រាប់អ្នកចរចារយៃក្នេង នៅទីក្រុង Kathmandu ប្រទេសនេប៉ាល់
- បានចូលរួមកិច្ចប្រជុំលើកទី៥០នៃក្រុមការងារអន្តរដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស
- បានចូលរួមសិក្ខាសាលាថ្នាក់តំបន់ស្តីពី Circular Economy as Transformational Pathway for Combating Global Climate Challenges នៅទីក្រុងបាងកក ប្រទេសថៃ
- បានចូលរួមសិក្ខាសាលាបណ្តុះបណ្តាលស្តីពីការបង្កើតចំណេះដឹងដើម្បីបង្កើនផលប៉ះពាល់វិជ្ជមាន និងបង្រួមផលប៉ះពាល់អវិជ្ជមានក្នុងការអនុវត្តវិធានការឆ្លើយតប នៅប្រទេសម៉ាល់ឌីវ
- បានចូលរួមវេទិកា 2019 East Asia Marine Cooperation Platform Qingtao Forum នៅខេត្តសានដុង សាធារណរដ្ឋប្រជាមានិតចិន
- បានកិច្ចប្រជុំពិភាក្សាថ្នាក់តំបន់ស្តីពីការរួមចំណែកថ្នាក់ជាតិឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និងវេទិកាប្រចាំសប្តាហ៍អាកាសធាតុតំបន់អាស៊ីប៉ាស៊ីហ្វិក នៅទីក្រុងបាងកក ប្រទេសថៃ
- បានចូលរួមកិច្ចប្រជុំថ្នាក់តំបន់អាស៊ីប៉ាស៊ីហ្វិកស្តីពីស្ថិតិយេនឌ័រ និងបរិស្ថាន នៅទីក្រុងបាងកក ប្រទេសថៃ
- បានចូលរួមសិក្ខាសាលា បណ្តុះបណ្តាលថ្នាក់តំបន់ស្តីពី ការរៀបចំផែនការជាតិបន្សាំទៅនឹងការ

ប្រែប្រួលអាកាសធាតុ ការអនុវត្ត និងក្របខណ្ឌនៃការតាមដាន និងវាយតម្លៃ នៅប្រទេសថៃ

- បានទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពី យុទ្ធសាស្ត្រនៃការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ នៅប្រទេសសិង្ហបុរី។

សកម្មភាពទី៥.៣ កិច្ចប្រជុំក្រុមការងារ ASEAN ស្តីពីការប្រែប្រួលអាកាសធាតុ

មន្ត្រីនាយកដ្ឋានប្រែប្រួលអាកាសធាតុចំនួន៩នាក់ បានចូលរួមកិច្ចប្រជុំ និងសិក្ខាសាលារបស់ក្រុមការងារ ASEAN ស្តីពីការប្រែប្រួលអាកាសធាតុ ដែលបានរៀបចំចំនួន៥លើក

- បានចូលរួមកិច្ចប្រជុំក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុអាស៊ាន ជាមួយសហភាពអឺរ៉ុប និងដៃគូអភិវឌ្ឍន៍ "Working Meeting of EU, AWGCC and Development Partners" នៅទីក្រុងហ្សាការតា ប្រទេសឥណ្ឌូនេស៊ី
- បានចូលរួមសិក្ខាសាលាស្តីពីការពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុនៃសមាជិក អាស៊ានតាមរយៈការចែករំលែកបទពិសោធន៍ និងមេរៀនស្តីពីវឌ្ឍនភាពនៃសកម្មភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ នៅខេត្តឈៀងរ៉ៃ ប្រទេសថៃ
- បានចូលរួមកិច្ចប្រជុំឧត្តមមន្ត្រីអាស៊ាន នៅទីក្រុងបាងកក ប្រទេសថៃ
- បានចូលរួមប្រជុំពិនិត្យលើផែនការសកម្មភាពក្រុមការងារអាស៊ានស្តីពីការប្រែប្រួលអាកាសធាតុ សន្និសីទលើកទី២ស្តីពីភាពជាដៃគូនៃការប្រែប្រួលអាកាសធាតុ និងកិច្ចប្រជុំលើកទី១០ក្រុមការងារអាស៊ានស្តីពីការប្រែប្រួលអាកាសធាតុ នៅប្រទេសសិង្ហបុរី
- ក្រុមការងារបាន និងកំពុងរៀបចំសេចក្តីព្រាងនៃគោលជំហររបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់សន្និសីទប្រចាំឆ្នាំនៃក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុលើកទី២៥ (COP25) នៅទីក្រុង Santiago ប្រទេសឈីលី
- បានសម្របសម្រួលរៀបចំឯកសារសម្រាប់បង់វិភាគទានជាសមាជិកអនុសញ្ញាក្របខណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ពិធីសារក្យូតូ និងកិច្ចព្រមព្រៀង (អាកាសធាតុ)ទីក្រុងប៉ារីស
- បានបញ្ចប់ការសិក្សាស្តីពីដំណោះស្រាយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុទៅលើកំណើនសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា និងបានរៀបចំប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ក្រោមអធិបតីភាព **ឯកឧត្តម សាយ សំអាល់** ប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងជារដ្ឋមន្ត្រីក្រសួងបរិស្ថាន ដោយមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍន៍ សរុបជិត ២០០នាក់។ របាយការណ៍នេះបានដាក់លើគេហទំព័ររបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដែលសាធារណជនអាចស្វែងរកបាន។

សកម្មភាពទី៥.៤ កិច្ចប្រជុំ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលផ្សព្វផ្សាយ

រូបទី៧៖ ការបណ្តុះបណ្តាលនិស្សិត និងយុវជនអំពីការប្រែប្រួលអាកាសធាតុ និងដំណើរទស្សនកិច្ចសិក្សា

- បានបណ្តុះបណ្តាលស្តីពីការប្រែប្រួលអាកាសធាតុ សម្រាប់យុវជនខេត្តបាត់ដំបង ដែលអញ្ជើញមកពីមន្ទីរវិស័យពាក់ព័ន្ធ រដ្ឋបាលខេត្ត ក្រុង និងសាលាគរុកោសល្យ និងវិក្រឹតការ ខេត្តបាត់ដំបង សរុបចំនួន១៦០នាក់ ក្នុងនោះស្ត្រី៩២នាក់

ទំព័រ ១៥

- បានបណ្តុះបណ្តាលស្តីពីការប្រែប្រួលអាកាសធាតុ សម្រាប់យុវជនខេត្តឧត្តមានជ័យ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត រដ្ឋបាលខេត្ត ក្រុង ខេត្ត ចំនួន១៥០នាក់ ក្នុងនោះស្ត្រី៤៨នាក់
- បានបណ្តុះបណ្តាលស្តីពីការប្រែប្រួលអាកាសធាតុ សម្រាប់យុវជនខេត្តរតនគិរី ដោយមានការចូលរួមពីអគ្គលេខាធិការដ្ឋាន នាយកដ្ឋាន មន្ទីរអប់រំ យុវជន និងកីឡាខេត្ត រដ្ឋបាលខេត្ត/ក្រុង និងវិទ្យាល័យ កាយវិទ្យ កាកបាទក្រហម សរុបចំនួន១៥៤នាក់ ក្នុងនោះស្ត្រី ៧៤ នាក់
- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការធ្វើផែនការជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុដល់ក្រសួងពាក់ព័ន្ធនៅរាជធានីភ្នំពេញដើម្បីលើកកម្ពស់សមត្ថភាពក្នុងការសរសេរគម្រោងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងស្វែងរកប្រភពហិរញ្ញប្បទានអាកាសធាតុក្រោយយន្តការបន្សាំដែលមានអ្នកចូលរួមចំនួន៤០នាក់
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីសម្មភាព និងរបបគំហើញរបស់ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (IPCC) និងសិក្ខាសាលាចែករំលែកចំណេះដឹង និងបទពិសោធន៍នៅខេត្តសៀមរាប
- បានចូលរួមរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការបញ្ជូនសំណើស្រាវជ្រាវ និងការរៀបចំអនុវត្តគម្រោងស្រាវជ្រាវការប្រែប្រួលអាកាសធាតុវគ្គបណ្តុះបណ្តាលស្តីពីការបញ្ជូនសំណើស្រាវជ្រាវ និងការរៀបចំអនុវត្តគម្រោងស្រាវជ្រាវការប្រែប្រួលអាកាសធាតុ ដែលមានអ្នកចូលរួម៦៥នាក់
- បានរៀបចំសិក្ខាសាលាស្តីពីយន្តការឥណទានកាបូនរួមគ្នានៅកម្ពុជា ការចូលរួមអនុវត្តNDC និងការអនុវត្ត SDGs ដែលមានអ្នកចូលរួម៥០នាក់
- បានរៀបចំសិក្ខាសាលាភាពជាដៃគូនៃការអនុវត្ត NDC មានអ្នកចូលរួមប្រមាណ៦០នាក់

រូបទី៨៖ ការវាយតម្លៃភាពងាយរងគ្រោះ និងដាក់ផែនការបន្សាំការប្រែប្រួលអាកាសធាតុទៅក្នុងផែនការវិនិយោគឃុំ នៅឃុំបាសាក់ ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង

- បានសហការរៀបចំសិក្ខាសាលាថ្នាក់តំបន់របស់ក្រុមជំនាញការ និងអ្នកពិគ្រោះយោបល់នៃអនុសញ្ញា UNFCCC នៅខេត្តសៀមរាប
- បានកែលម្អរគេហទំព័ររបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ (www. ncsd.moe.gov.kh)
- បានរៀបចំផ្ទាំងរូបភាព និងអត្ថបទសម្រាប់ដាក់តាំងនៅតាមទីធ្លានៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។

ការងារផ្សេងៗ

ការអនុវត្តគម្រោងនានាក្រោមការដឹកនាំ និងសម្របសម្រួលរបស់នាយកដ្ឋានប្រែប្រួលអាកាសធាតុ

ក. កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា

បានគាំទ្រគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយសហការជាមួយមន្ទីរបរិស្ថាននិងឃុំ ដែលមានគម្រោងចំនួន១២ត្រូវគាំទ្រដោយពីគម្រោង CCCA ក្នុងឆ្នាំ ២០១៩ រួមមាន៖

- ខេត្តសៀមរាប គម្រោងបានគាំទ្រដល់គម្រោង ជីកស្រះដែលមានបណ្តោយ ៤០ម ទទឹង៣០ម ជម្រៅ ៣,៥មផ្លូវ៦០ម និងគម្រោងសូឡាបូមទឹក១កន្លែង

- ខេត្តកំពង់ស្ពឺបានផ្តល់គម្រោងស្រះចំនួន២កន្លែង ដែលមានបណ្តោយ៤០មទទឹង៣០ម ជម្រៅ ៣,៥ ម៉ែត្រ
- ខេត្តឧត្តរមានជ័យ បានគាំទ្រដល់គម្រោងជីកស្រះ ១កន្លែង ដែលមានបណ្តោយ ៤០ម ទទឹង៣០ម ជម្រៅ៣,៥មផ្លូវ៦០ម៉ែត្រ
- គម្រោងបានសាងសង់លូរំដោះទឹកចំនួន៦កន្លែង នៅខេត្តស្វាយរៀង
- ខេត្តកោះកុងគម្រោងបានគាំទ្រដល់គម្រោងលូ រំដោះទឹកខ្នាតធំ១កន្លែង។
- បានរៀបចំ និងការផ្តល់ជាតុចូលនៃសូចនាករពាក់ព័ន្ធការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអនុវត្ត យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ក្របខណ្ឌគោលដៅអភិវឌ្ឍន៍ដោយចីរភាពកម្ពុជា និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ យ៉ាងហោចណាស់សូចនាករចំនួន០៦ ត្រូវបានរាជរដ្ឋាភិបាលអនុម័ត
- បានគាំទ្រដល់វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញគោលនយោបាយអាកាសធាតុ និងហិរញ្ញវត្ថុសាធារណៈ និងបណ្តុះបណ្តាលក្រសួងនានាដើម្បីបញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយ និងយុទ្ធសាស្ត្រតាមវិស័យ ជាពិសេសវិស័យហេដ្ឋារចនាសម្ព័ន្ធ
- បានសម្របសម្រួល និងគាំទ្រដល់ដំណើរការនៃការសិក្សានយោបាយលើគោលនយោបាយសារពើពន្ធសម្រាប់យានយន្តមានប្រសិទ្ធភាពប្រេង។ ជាលទ្ធផល អនុសាសន៍ត្រូវបានដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិនិត្យ និងសម្រេច ជាពិសេសការកែប្រែគោលនយោបាយសារពើពន្ធថ្មីដើម្បីធានាដល់ចីរភាពបរិស្ថាន សេដ្ឋកិច្ច សង្គម
- សហការជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC) ក្នុងការតាមដានហិរញ្ញប្បទានការប្រែប្រួលអាសធាតុក្នុងកម្រងទិន្នន័យ ODA។ ជាលទ្ធផលអនុសាសន៍របស់នាយកដ្ឋានត្រូវបានទទួលយក និងកែប្រែទម្រង់នៃការកត់ត្រាជាពិសេសបានពង្រឹងសមត្ថភាពមន្ត្រីCRDB/CDC និងដៃគូអភិវឌ្ឍន៍ លើការកត់ត្រាទិន្នន័យហិរញ្ញប្បទានអាកាសធាតុក្នុងកម្មវិធីរបស់ដៃគូអភិវឌ្ឍន៍
- បានចុះកិច្ចព្រមព្រៀងហិរញ្ញវត្ថុសម្រាប់កម្មវិធី CCCA ជំហានទី៣ (២០១៩-២០២៤) ជាមួយ UNDP, ស៊ុយអែត និងសហភាពអឺរ៉ុប
- បានបន្តកិច្ចសហការជាមួយក្រសួងពាក់ព័ន្ធដែលនឹងចូលរួមអនុវត្តគម្រោង ក្រោមជំនួយពីកម្មវិធី CCCA ដំណាក់កាលទី៣ ដែលរួមមានក្រសួងបរិស្ថាន ក្រសួងរ៉ែ និងថាមពល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាដើម។

ខ. គម្រោងរៀចំរបាយការណ៍ជាតិលើកទី៣ ក្រោមអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ

- បានបញ្ចប់ជំពូកទី១ ស្តីពីស្ថានភាពទូទៅរបស់កម្ពុជា
- កំពុងរៀបចំជំពូកទី២ស្តីពីសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ សម្រាប់ឆ្នាំ២០០៥ និង ឆ្នាំ២០១០
- កំពុងរៀបចំជំពូកទី៣ ស្តីពីការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។

គ. រៀបចំរបាយការណ៍បច្ចុប្បន្នភាពពីរឆ្នាំម្តងលើកទី១ របស់កម្ពុជាក្រោមអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ

- បានបញ្ចប់ជំពូកទី១ស្តីពីស្ថានភាពទូទៅរបស់កម្ពុជា
- កំពុងរៀបចំជំពូកទី២ស្តីពីសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ ពីឆ្នាំ១៩៩៤ ដល់២០១៦
- កំពុងរៀបចំជំពូកទី៣ស្តីពីការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ពីឆ្នាំ ១៩៩៤ ដល់ ២០១៦។

អនុកម្មវិធីពាក់ព័ន្ធអតិវក្សជីវៈចម្រុះ និងជីវសុវត្ថិភាព

នាយកដ្ឋានជីវៈចម្រុះមានតួនាទីដឹកនាំ និងសម្របសម្រួលការងារអភិរក្ស ការគ្រប់គ្រង និងការប្រើប្រាស់ប្រកបដោយនិរន្តរភាពនៃធនធានជីវៈចម្រុះ សៀវភៅប្រព័ន្ធអេកូឡូស៊ីនិងការងារជីវសុវត្ថិភាព។ ឆ្នាំ២០១៩ នាយកដ្ឋានជីវៈចម្រុះបានសម្រេចសមិទ្ធផលសំខាន់ៗ ដូចខាងក្រោម៖

ចង្កោមសកម្មភាពទី១៖ សៀវភៅគាំទ្រ កិច្ចសហប្រតិបត្តិការអន្តរជាតិ-អាស៊ាននិងការសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងជីវៈចម្រុះ និងជីវសុវត្ថិភាព

សកម្មភាពទី៤.១ ចូលរួមសិក្ខាសាលាវគ្គបណ្តុះបណ្តាល និងកិច្ចប្រជុំក្នុងនិងក្រៅប្រទេស

- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី Global Inception Meeting and Capacity Building Workshop នៅចក្រភពអង់គ្លេស
- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីAdvanced International Training Program on Intellectual Property and Genetic Resource-in Support of Innovation នៅប្រទេសសំប៊ី
- បានចូលរួមសិក្ខាសាលាថ្នាក់តំបន់ស្តីពី «ប្រព័ន្ធការពារក្នុងតំបន់ការពារធម្មជាតិនៃតំបន់អាស៊ាន» ប្រទេសម៉ាឡេស៊ី
- បានចូលរួមសិក្ខាសាលាស្តីពី "The Identification of Sites and Areas Critical to the Persistence of Biodiversity in the ASEAN Region and on the Development of Visualization Tools to Aid Reporting Processes to Multilateral Environmental Agreements (MEAs)" នៅប្រទេសថៃ
- បានចូលរួមសិក្ខាសាលាស្តីពី"Accelerating Aichi Target11 Implementation in the East and Southeast Asia Regions" និងកិច្ចប្រជុំពិភាក្សាអាស៊ានថ្នាក់តំបន់ស្តីពី "The Post-2020 Global Biodiversity Framework" នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន
- បានចូលរួមសិក្ខាសាលាស្តីពី"Harmonization of Biosafety Regulation System" នៅទីក្រុង Dhaka នៅប្រទេសបង់ក្លាដេស
- បានចូលរួមសន្និសីទអន្តរជាតិស្តីពីជីវៈចម្រុះ នៅទីក្រុងបាងកក ប្រទេសថៃ
- បានចូលរួម The Biodiversity-Based Product (BBP) Project Closing Event នៅប្រទេសឡាវ
- ចូលរួមកិច្ចប្រជុំថ្នាក់តំបន់ស្តីពីការរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រគ្រប់គ្រងបរិស្ថានដោយផ្តល់អាទិភាពលើធនធានបរិស្ថានក្នុងអាងទន្លេ នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៩ នៅប្រទេសវៀតណាម
- បានចូលរួមសិក្ខាសាលាស្តីពី "The Regional Experiences-Sharing on Intellectual Property Rights, Biodiversity and Community Access and Benefit Sharing from the Use of Biological Resources and Associated Traditional Knowledge" នៅទីក្រុងហាណូយ ប្រទេសវៀតណាម
- បានចូលរួមកិច្ចប្រជុំឧត្តមមន្ត្រីបរិស្ថានអាស៊ានលើកទី៣០ និងកិច្ចប្រជុំពាក់ព័ន្ធ នៅប្រទេសថៃ
- បានចូលរួមសន្និសីទ Trondheim លើកទី៩ ស្តីពីជីវៈចម្រុះ រៀបចំដោយក្រសួងអាកាសធាតុ និងបរិស្ថាននៃរដ្ឋាភិបាលប្រទេសន័រវ៉ែ នៅទីក្រុង Trondheim ប្រទេសន័រវ៉ែ
- បានចូលរួមសន្និបាតលើកទី៦ ស្តីពី"បណ្តាញរុក្ខឧទ្យានអាស៊ាន (Botanic Garden Network)" ដែលមានការចូលរួមពីបណ្តាប្រធានរុក្ខឧទ្យាន អ្នកជំនាញ អង្គការដៃគូមកពីបណ្តាប្រទេសអាស៊ាន អាស៊ីខាងកើត និងអាស៊ីខាងត្បូង ដែលមានចំនួន ៧០រូប។ សន្និបាតលើកទី៦នេះ បានរៀបចំឡើងដោយបណ្តាញរុក្ខឧទ្យានអន្តរជាតិ (BGCI) និង

Queen Sirikit Botanic Garden នៅទីក្រុងឈៀងម៉ៃ ប្រទេសថៃ

- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "Integrated Biodiversity and Ecosystem Conservation" ប្រទេសម៉ាឡេស៊ី

សកម្មភាពទី៤.២ ចូលរួមសិក្ខាសាលា និងកិច្ចប្រជុំក្នុងក្របខណ្ឌ ASEAN ទាក់ទងនឹងជីវៈចម្រុះ UN-CBD

- បានចូលរួមកិច្ចប្រជុំស្តីពី "The ASEAN Working Group on Nature Conservation and Biodiversity (AWGNCB)" នៅទីក្រុងវៀងចន្ទ ប្រទេសឡាវ
- បានចូលរួមកិច្ចប្រជុំស្តីពី WG8J 11 and SBSTTA 23 នៅទីក្រុងម៉ុងរ៉េអាល់ ប្រទេសកាណាដា
- បានចូលរួមកិច្ចប្រជុំស្តីពី"Thematic Consultation on Area-Based Conservation Measure for the Post-2020 Global Biodiversity Framework" នៅទីក្រុង Dushanbe ប្រទេសតាហ្ស៊ីគីស្តាន
- បានចូលរួមកិច្ចប្រជុំស្តីពី "Monitoring the Utilization of Genetic Resource Under the Nagoya protocol" ប្រទេសតាហ្ស៊ីគីស្តាន
- ត្រៀមចូលរួមកិច្ចប្រជុំស្តីពី "Thematic Workshop on Ecosystem Restoration for the Post-2020 Global Biodiversity Framework" និងសិក្ខាសាលាត្រៀមចាប់ពីថ្ងៃទី នៅទីក្រុង Rio de Janeiro ប្រទេសប្រេស៊ីល។

សកម្មភាពទី៤.៣ ការប្រារព្ធទិវាជីវៈចម្រុះអន្តរជាតិប្រចាំឆ្នាំ២០១៩

បានរៀបចំទិវាជីវៈចម្រុះអន្តរជាតិ សម្រាប់ឆ្នាំ២០១៩ នៅខេត្តមណ្ឌលគិរីក្រោមប្រធានបទ "ជីវៈចម្រុះរបស់យើង អាហាររបស់យើង សុខភាពរបស់យើង" នៅសួនឧទ្យានសែនមនោរម្យ ខេត្តមណ្ឌលគិរី ដែលមានអ្នកចូលរួមប្រមាណ ១០០០នាក់។

*រូបទី៩៖ ទិវាជីវៈចម្រុះអន្តរជាតិឆ្នាំ២០១៩ ក្រោមប្រធានបទ **"ជីវៈចម្រុះរបស់យើង អាហាររបស់យើង សុខភាពរបស់យើង"** នៅខេត្តមណ្ឌលគិរី*

សកម្មភាពទី៤.៤ បោះពុម្ព និងផ្សព្វផ្សាយឯកសារអនុសញ្ញា ពិធីសារ ក្របខ័ណ្ឌការងារ យុទ្ធសាស្ត្រ និងឯកសារផ្សព្វផ្សាយ ពាក់ព័ន្ធនឹងជីវៈចម្រុះ

- បោះពុម្ពឯកសាររបាយការណ៍ជាតិលើកទី៦ ចំនួន ២៥០ក្បាល
- បោះពុម្ពឯកសារផ្ទាំងផ្ទត់អប់រំស្តីពីយេនឌ័រ និងការអភិរក្សជីវៈចម្រុះ ចំនួន ៥០ផ្ទាំង
- បោះពុម្ព និងផ្សព្វផ្សាយខិតប័ណ្ណព័ត៌មានស្តីពីកេសរកូលជប្រភេទ ចំនួន១០០សន្លឹក
- បោះពុម្ពសៀវភៅណែនាំរុក្ខជាតិមានតម្លៃផ្នែកសេដ្ឋកិច្ចក្នុងឧទ្យានជាតិភ្នំគូលែនចំនួន១០០ក្បាល
- បោះពុម្ពសៀវភៅបច្ចេកទេស និងថែរក្សាទុកក្តៀងនៃប្រទាលថ្លើមឆ្កែ ឬខ្ចាយខ្មៅចំនួន ៣០០ ក្បាល
- បោះពុម្ពផ្សាយនូវសៀវភៅមគ្គុទេសក៍កេសរកូលនៅកម្ពុជា (ភាគ១)
- បានបង្កើតឯកសារសង្ខេបគោលនយោបាយនៃខ្សែចង្វាក់ផលិតផលផលិតចេញពីធនធានជីវៈចម្រុះ

- បានផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងអំពីការរៀបចំឯកសារច្បាប់ និងបទដ្ឋានគតិយុត្តនៃការអនុវត្តពិធីសារណាហ្គូយ៉ានៅកម្ពុជា។

សកម្មភាពទី៤.៥ ចុះសិក្សាស្រាវជ្រាវ វាយតម្លៃ និងចងក្រងទិន្នន័យនៅ ទីវាលសហគមន៍ និងតំបន់ការពារ ធម្មជាតិទាក់ទងនឹងធនធានជីវៈចម្រុះ ធនធានពន្ធុ ចំណេះដឹងប្រពៃណី ប្រព័ន្ធអេកូឡូស៊ី ការអភិរក្សក្រៅតំបន់ និងការងារជីវសុវត្ថិភាព

- សម្របសម្រួលស្នើសុំបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិរក្សកេសរកូល សុខ អាន ភ្នំគូលែន និងបានទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាល តាមរយៈលិខិតលេខ៨៧សជណ.ដប ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៩
- បានប្រមូលទិន្នន័យ និងព័ត៌មានជីវៈចម្រុះពីខេត្តចំនួន០៦ខេត្ត រួមមាន កោះកុង ពោធិ៍សាត់ មណ្ឌលគិរី រតនៈគិរី ស្ទឹងត្រែង និងក្រចេះ សម្រាប់រៀបចំប្រព័ន្ធគ្រប់គ្រង ទិន្នន័យជីវៈចម្រុះថ្នាក់ជាតិ
- បានប្រជុំពិគ្រោះយោបល់ជាមួយដៃគូពាក់ព័ន្ធ ដើម្បីវាយតម្លៃស្ថានភាពនៃការអភិរក្សជីវៈចម្រុះ បញ្ហាប្រឈម និងសមត្ថភាព សម្រាប់បង្កើតភាពងាយស្រួលក្នុងការចែករំលែកព័ត៌មាន និងរៀបចំជាឯកសារគតិយុត្តផ្សេងៗក្នុងគោលបំណងជំរុញការអនុវត្តផែនការសកម្មភាព និងយុទ្ធសាស្ត្រជាតិស្តីពីជីវៈចម្រុះ (NBSAP) នៅប្រទេសកម្ពុជា
- ស្វែងយល់លម្អិតពីប្រព័ន្ធទិន្នន័យរបស់មជ្ឈមណ្ឌលព័ត៌មានជីវៈចម្រុះសកល(GBIF)ដើម្បីបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យជីវៈចម្រុះជាតិ
- បានដឹកនាំនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិទ្យាសាស្ត្រអភិរក្សជីវៈចម្រុះ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញចុះកម្មសិក្សានៅឧទ្យានជាតិ ព្រះមុនីវង្ស "បូកគោ" ដើម្បីស្វែងយល់និងអនុវត្តជាក់ស្តែងនូវវិធីសាស្ត្រស្រាវជ្រាវបច្ចេកទេសក្នុងការកំណត់អត្តសញ្ញាណ របៀបកត់ត្រាទិន្នន័យនៅទីវាល និងវិធីសាស្ត្រប្រមូល និងរក្សាសំណាកសត្វស្លាប ល្មូន ថល ជលិក ប្រចៀវ សត្វល្អិត និងរុក្ខជាតិ។

សកម្មភាពទី៤.៦ ប្រមូល និងថែរក្សាសំណាកសម្រាប់ការសិក្សាស្រាវជ្រាវ និងអភិរក្សក្រៅដែនធម្មជាតិ

- បាននាំយកកេសរកូលចំនួន៣ប្រភេទ ដែលដាក់

រូបទី១០៖ ការបណ្តុះបណ្តាលបច្ចេកទេសនៃការបង្កាត់ និងផ្សាំកូនកេសរកូលព្រៃ ជល់មន្ត្រីឧទ្យានុរក្ស និងសហគមន៍មូលដ្ឋាន នៅមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិរក្សកេសរកូល សុខ អាន ភ្នំគូលែន ខេត្តសៀមរាប

ព្រះនាមព្រះវររាជបិតា និងព្រះមហាក្សត្រ ព្រមទាំងឈ្មោះ សម្តេចតេជោនាយករដ្ឋមន្ត្រី រួមមាន៖ ១) Mayara Prince Norodom Sihanouk ២) Dendrobium Norodom Sihamoni និង ៣) Pararachnis Hun Sen ពីប្រទេសសិង្ហបុរីដើម្បីថែរក្សា និងអប់រំផ្សព្វ ផ្សាយ

- បានរៀបចំអនុស្សារណៈចំនួន៤ ជាមួយ៖ ១). ភ្នាក់ងារសេវាកម្មព្រៃឈើនៃសាធារណរដ្ឋកូរ៉េ ស្តីពីការសិក្សាស្រាវជ្រាវនិងការអភិរក្សក្រៅតំបន់ ២). The Royal Botanic Garden, KEW នៃប្រទេសអង់គ្លេស ស្តីពីសហប្រតិបត្តិការលើការសិក្សាស្រាវជ្រាវរុក្ខជាតិ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលស្រាវជ្រាវ និងអភិរក្សកេសរកូលសុខ អាន ភ្នំគូលែន ៣). សារមន្ទីរប្រវត្តិសាស្ត្រទីក្រុងប៉ារីស ប្រទេសបារាំងស្តីពីសហប្រតិបត្តិការលើការសិក្សាស្រាវ ជ្រាវរុក្ខជាតិ ការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលស្រាវជ្រាវ និងអភិរក្សកេសរកូលសុខ អានភ្នំ

គូលែន និងការចងក្រងឯកសារយុទ្ធជាតិនៅប្រទេសកម្ពុជា ៤).អង្គការផ្តោតទៅលើសត្វព្រៃ ស្តីពីសហប្រតិបត្តិការលើវិស័យអប់រំនិងផ្សព្វផ្សាយជីវៈចម្រុះ

- រៀបចំថ្នាលបណ្តុះកូនកេសរកូលទំហំ១៦០ម៉ែត្រការ៉ែ
- បានកៀរគរថវិកាពីដៃគូ និងថវិការដ្ឋដើម្បីគាំទ្រដល់កិច្ចដំណើរការមជ្ឈមណ្ឌល
- បានពិនិត្យ វាយតម្លៃ និងផលិតផែនទីមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិរក្សកេសរកូល សុខ អាន ភ្នំគូលែន
- បានសហការជាមួយក្រុមជំនាញបរទេសដើម្បីសិក្សាពីលទ្ធភាពក្នុងរៀបចំផែនការមែនៃការបង្កើតមជ្ឈមណ្ឌលបានចំនួន ៥ លើក

រូបទី១១៖ ការចុះប្រមូលសំណាកកេសរកូលព្រៃ បំពង់ក្រឡោម និងបណ្តាង្គជាតិ នៅតំបន់អេកូទេសចរណ៍ធម្មជាតិជីផាត និងដែនជម្រកសត្វព្រៃតាតៃ ខេត្តកោះកុង

- មន្ត្រីចំនួន១រូប បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការសិក្សាពីជីវៈចម្រុះ នៅប្រទេសកូរ៉េខាងត្បូង
- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រ នៃការប្រមូលបង្កាត់ និងថែទាំ
- បានបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រនៃការប្រមូលសំណាកកេសរកូលព្រៃ និងបង្កាត់ពូជដល់ឧទ្យានរក្ស ចំនួន ៤០រូប
- បានចូលរួមកិច្ចប្រជុំកសាងបណ្តាលសួនរុក្ខឧទ្យានថ្នាក់តំបន់ចំនួន ០២លើក
- សម្របសម្រួល និងរៀបចំសេចក្តីព្រាងសៀវភៅស្តីពីប្រភេទរាតត្បាតនៅកម្ពុជានិងប្រមូលយករូបភាព



រូបទី១២៖ ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពី« ការកសាងសមត្ថភាពលើការគ្រប់គ្រង និងអភិរក្សជនជានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីនៅកម្ពុជា»

- បានចុះបេសកកម្មចំនួន ២លើក បន្តការងាររៀបចំសួនកេសរកូលព្រៃសុខ អាន ភ្នំគូលែន ដូចជាការរៀបចំលម្អ និងរៀបចំសាងសង់ធ្នើដើម្បីបណ្តុះ កូនកេសរកូលបន្ថែម និងពិនិត្យមើលនូវស្លាកឈ្មោះកេសរកូលចាស់ៗ និងរៀបចំស្លាកឈ្មោះថ្មីបន្ថែមបាន ចំនួន១០០០ ស្លាកឈ្មោះ និងពិនិត្យមើលវឌ្ឍនភាពនៃការរៀបចំ ការថែទាំ និងការតបំពង់ទឹកពីលើភ្នំ និងការពង្រីកមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិរក្សកេសរកូល សុខ អាន ភ្នំគូលែន ចុះរៀបចំផែនទីមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវ និងអភិរក្សកេសរកូល សុខ អាន ភ្នំគូលែន នៅខេត្តសៀមរាប
- បានរៀបចំសំណើសុំអនុញ្ញាតជាគោលការណ៍គាំទ្រដល់ដំណើរការរៀបចំផែនទីមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិរក្សកេសរកូល សុខ អាន ភ្នំគូលែន
- បានចុះប្រមូលសំណាករុក្ខជាតិប្រភេទកេសរកូលព្រៃ សម្រាប់ឆ្នាំ២០១៩ ចំនួន៥លើក នៅខេត្តមណ្ឌលគិរី កោះកុង និងព្រះវិហារ មានដូចជាបំពង់ក្រឡោម និងបណ្តាង្គជាតិ នៅតំបន់អេកូទេសចរណ៍ធម្មជាតិ "ជីផាត" និងដែនជម្រកសត្វព្រៃតាតៃក្នុងភូមិសាស្ត្រខេត្តកោះកុង។ ជាលទ្ធផលយើងប្រមូលបានកេសរកូលព្រៃចំនួន៣៨ប្រភេទ បណ្តាង្គជាតិ៥ប្រភេទ បំពង់ក្រឡោម១ប្រភេទ និងរុក្ខជាតិលំអផ្សេងៗទៀតជាច្រើន។ រាល់សំណាក

ទំព័រ ២១

រុក្ខជាតិដែលប្រមូលបានទាំងអស់បានត្រូវដឹកជញ្ជូនទៅមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិរក្សកេសរកូល សុខ អាន ភ្នំគូលែននៅក្នុងខេត្តសៀមរាប ដើម្បីរៀបចំដាំទៅតាមលក្ខណៈបច្ចេកទេស។

ចង្កោមសកម្មភាពទី២៖ ការរៀបចំយុទ្ធសាស្ត្រ ក្របខណ្ឌការងារនិងគោលនយោបាយស្តីពីជីវៈចម្រុះ ជីវសុវត្ថិភាព ប្រព័ន្ធអេកូឡូស៊ី និងអនុវត្តអនុសញ្ញាពិធីសារ និងកិច្ចព្រមព្រៀងនានា

- បានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសជីវៈចម្រុះ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាល ទាក់ទងនឹងការគ្រប់គ្រង និងអភិរក្សធនធាន ជីវៈចម្រុះ ធនធានពន្ធុ ការងារជីវសុវត្ថិភាព ការអភិរក្សក្រៅតំបន់ យន្តការសម្របសម្រួល CHM និងសេវាកម្មប្រព័ន្ធអេកូឡូស៊ី
- បានរៀបចំសិក្ខាសាលាស្តីពី "ការរៀបចំបង្កើតក្របខណ្ឌការងារសម្រាប់អនុវត្តពិធីសាណាហ្គូយ៉ាស្តីពីការប្រើប្រាស់និងការបែងចែកផលប្រយោជន៍ពីធនធានពន្ធុ (ABS)" ដោយមានសិក្ខាកាមចូលរួមចំនួន១០០រូប នៅរាជធានីភ្នំពេញ
- បានរៀបចំកិច្ចប្រជុំអន្តរអគ្គលេខាធិការដ្ឋាន និងអគ្គនាយកដ្ឋានចំណុះក្រសួងបរិស្ថានស្តីពីការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី ដើម្បីពិនិត្យសម្រេចលើជម្រើសក្នុងការអនុវត្ត PES ដោយមានអ្នកចូលរួម៤៩នាក់ (ស្រី៧នាក់)
- បានបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ ដល់យុវជន ឧទ្យានុរក្ស និងមន្ត្រីវ័យក្មេងក្រសួងបរិស្ថាន ចំនួន០២លើក (៧០នាក់ក្នុងមួយលើក)
- បានរៀបចំសិក្ខាសាលាស្តីពី "ការត្រួតពិនិត្យ តាមដានការអនុវត្តផែនការសកម្មភាព និងយុទ្ធសាស្ត្រជាតិស្តីពីជីវៈចម្រុះ (NBSAP) នៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ដោយមានអ្នកចូលរួមចំនួន ៥០នាក់(ស្រី១៤នាក់)
- បានរៀបចំកម្មវិធីដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ "របាយការណ៍ជាតិលើកទី៦ ក្រោមអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ ដោយមានអ្នកចូលរួមពីថ្នាក់ដឹកនាំក្រសួងស្ថាប័នពាក់ព័ន្ធ តំណាងស្ថានទូតអង្គការដៃគូអភិវឌ្ឍន៍ គ្រឹះស្ថានអប់រំ និងវិទ្យាស្ថានសិក្សាស្រាវជ្រាវព្រមទាំងវិស័យឯកជន សរុបចំនួន ៨០រូប
- បានរៀបចំកិច្ចប្រជុំស្តីពីជីវៈចម្រុះក្នុងតំបន់ការពារធម្មជាតិទាំង ៥ នៅខេត្តមណ្ឌលគីរី" នៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៩ ដោយមានអ្នកចូលរួមសរុបប្រមាណ ៤០នាក់
- បានរៀបចំសិក្ខាសាលាស្តីពីសកម្មភាពអភិរក្សជីវៈចម្រុះរបស់ដៃគូកំពុងអនុវត្តនៅតំបន់ការពារធម្មជាតិនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៩ ដោយមានអ្នកចូលរួមប្រមាណ៨០នាក់ (ស្រី១៨នាក់)
- បានរៀបចំសិក្ខាសាលាស្តីពី វិធានការទប់ស្កាត់ការជួញដូរសត្វ និងរុក្ខជាតិព្រៃនៅកម្ពុជា ដោយមានអ្នកចូលរួមសរុបប្រមាណ ៤០ នាក់ (ស្រី ៤នាក់)

ខ. រៀបចំ និងបង្កើតយន្តការ និងវិធានការជំរុញការគ្រប់គ្រងជីវៈចម្រុះ ធនធានពន្ធុ និងជីវសុវត្ថិភាព

- បានធ្វើបទបង្ហាញស្តីពីការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិរក្សកេសរកូល សុខ អាន ភ្នំគូលែនក្នុងកិច្ចប្រជុំលើកទី៣២ របស់ICC Angkor ជាលទ្ធផល ICC Angkor បានអបអរសាទរចំពោះវឌ្ឍនភាពនៃការរៀបចំមជ្ឈមណ្ឌលកេសរកូល និងផ្តល់អនុសាសន៍ឱ្យពង្រឹងធនធានមនុស្ស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ព្រមទាំងចាប់ផ្តើមរៀបចំកម្មវិធីសម្រាប់ភ្ញៀវទេសចរណ៍ចូលទស្សនា
- បានចូលរួមជាវាគ្មិនក្នុងកម្មវិធីវិទ្យុ ទូរទស្សន៍ ចំនួន ០៣លើក ពាក់ព័ន្ធប្រធានបទការគ្រប់គ្រងជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី និងកេសរកូល
- បានប្រជុំឆ្លងខ្លឹមសារនៃសេចក្តីព្រាងនៃសេចក្តីសម្រេចនិងសមាសភាពអនុក្រុមការងារបច្ចេកទេសជីវសុវត្ថិភាព
- បានប្រមូលលិខិតបទដ្ឋានគតិយុត្តិ និងឯកសារពាក់ព័ន្ធនឹងជីវសុវត្ថិភាពដើម្បីបញ្ចូល និងផ្សព្វផ្សាយនៅក្នុងគេហទំព័ររបស់ BCHM

- ផ្សព្វផ្សាយពីខ្លឹមសារ គុណសម្បត្តិ គុណវិបត្តិនៃការប្រើប្រាស់សារពាង្គកាយកែច្នៃរស់ដល់សាធារណជន តាមរយៈទិវាជីវៈចម្រុះអន្តរជាតិ គេហទំព័រ BCHM វគ្គបណ្តុះបណ្តាល
- ទំនាក់ទំនងជាមួយនឹងអ្នកឯកទេសផ្នែកជីវសុវត្ថិភាពដើម្បីពង្រឹងសមត្ថភាពមន្ត្រីទទួលបន្ទុកលើជំនាញជីវសុវត្ថិភាព និងការដាក់ឱ្យដំណើរការឡើងវិញនូវមន្ទីរពិសោធន៍បច្ចេកទំនើប
- បានរៀបចំយុទ្ធសាស្ត្រ និងផែនការកសាងសមត្ថភាពមន្ត្រី និងស្ថាប័នពាក់ព័ន្ធការងារជីវសុវត្ថិភាពរយៈពេលខ្លី និងមធ្យម
- បានចូលរួមកិច្ចប្រជុំពិភាក្សា និងផ្តល់ធាតុចូលសម្រាប់ដាក់បញ្ចូលមុខទំនិញសារពាង្គកាយកែច្នៃទៅក្នុងតារាង បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតនៅកម្ពុជានៃអនុក្រឹត្យលេខ២០៩
- ស្វែងយល់លម្អិតពីប្រព័ន្ធទិន្នន័យរបស់មជ្ឈមណ្ឌលព័ត៌មានជីវៈចម្រុះសកល(GBIF) ដើម្បីបង្កើតប្រព័ន្ធគ្រប់គ្រងនិន្នន័យជីវៈចម្រុះជាតិ
- ប្រមូល និងផ្តល់ធាតុចូលសម្រាប់ការរៀបចំទីតាំងតាំងបង្ហាញ (Corridor Display)
- បានផ្សព្វផ្សាយ និងអនុវត្តគំរូកម្រងព័ត៌មាននៃការស្នើសុំលិខិតអនុញ្ញាតនាំចេញសំណាក
- ធនធានពន្ធក្នុងគេហទំព័រយន្តការសម្របសម្រួលនិងផ្សព្វផ្សាយព័ត៌មាន (CHM) និងអ្នកស្នើសុំ
- បានសម្របសម្រួល និងផ្តល់លិខិតអនុញ្ញាតឱ្យនាំចេញសំណាកទឹកត្រពាំង សត្វល្អិត និងផ្សិតចំនួន ០៣លិខិត (ប្រទេសជប៉ុន បារាំង និងប្រទេសអង់គ្លេស)

គ. យន្តការ CHM បានដំណើរការ និងធ្វើបច្ចុប្បន្នភាព

- គ្រប់គ្រង ថែទាំ និងធ្វើបច្ចុប្បន្នភាពព័ត៌មាន និងទិន្នន័យពាក់ព័ន្ធជីវៈចម្រុះជាប្រចាំ
- ផ្សព្វផ្សាយពីការប្រើប្រាស់ និងស្វែងរកព័ត៌មានទិន្នន័យក្នុងគេហទំព័រCHM តាមរយៈកិច្ចប្រជុំ និងសិក្ខាសាលាបានចំនួន០២លើក។

ទំព័រ ២៣

៤. សកម្មភាពចូលរួម កិច្ចប្រជុំ សិក្ខាសាលា បណ្តុះបណ្តាលនៅក្នុង និងក្រៅប្រទេស

តារាង ២៖ សកម្មភាពចូលរួម កិច្ចប្រជុំ សិក្ខាសាលា បណ្តុះបណ្តាលនៅក្នុងប្រទេស

ល.រ	ឈ្មោះអង្គភាព	ចូលរួម ប្រជុំ សិក្ខាសាលា បណ្តុះបណ្តាល ក្នុងប្រទេស								
		ប្រជុំ			សិក្ខាសាលា			បណ្តុះបណ្តាល		
		លើក	អ្នកចូលរួម		លើក	អ្នកចូលរួម		លើក	អ្នកចូលរួម	
			សរុប	ស្រី		សរុប	ស្រី		សរុប	ស្រី
១	នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ	៨០	១៧	៨	៦៨	១៥	៧	៦	៣	៣
២	នាយកដ្ឋានសេដ្ឋកិច្ចបៃតង	២៥	៣០	២០	២៨	៣៥	២៧	១៧	១៩	១៥
៣	នាយកដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា	៣៦	៤៥	៦	៤៩	៦៧	១៣	៧	៩	៣
៤	នាយកដ្ឋានប្រែប្រួលអាកាសធាតុ	២៩	៥៦	២៩	៥២	៧២	២៩	៣	៣	២
៥	នាយកដ្ឋានជីវចម្រុះ	៥០	៦៦	១៤	២៧	៦៧	១៩	៨	១២	៤
	សរុប	**១៣២**	**២៧៧**	**៦៩**	**១៩៤**	**៣០៩**	**៨៨**	**៣៨**	**៤៩**	**២៧**

ប្រភព៖នាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. គិតត្រឹមខែកញ្ញា ឆ្នាំ២០១៩

តារាងទី៣ សកម្មភាពចូលរួម កិច្ចប្រជុំ សិក្ខាសាលា បណ្តុះបណ្តាលនៅក្រៅប្រទេស

ល.រ	ឈ្មោះអង្គភាព	ចូលរួម ប្រជុំ សិក្ខាសាលា បណ្តុះបណ្តាល ក្រៅប្រទេស								
		ប្រជុំ			សិក្ខាសាលា			បណ្តុះបណ្តាល		
		លើក	អ្នកចូលរួម		លើក	អ្នកចូលរួម		លើក	អ្នកចូលរួម	
			សរុប	ស្រី		សរុប	ស្រី		សរុប	ស្រី
១	នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ	១៨	១០	៣	១៣	១២	១	៥	៤	១
២	នាយកដ្ឋានសេដ្ឋកិច្ចបៃតង	៧	៥	១	៤	២	១	៧	១៤	០៥
៣	នាយកដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា	៥	៦	១	៤	៤	២	៦	៦	៤
៤	នាយកដ្ឋានប្រែប្រួលអាកាសធាតុ	១៤	៣០	១៤	១៧	៣៣	១២	១៣	៩	៧
៥	នាយកដ្ឋានជីវៈចម្រុះ	៥	៥	០	៩	១១	៣	៣	៣	០
	សរុប	**៣១**	**៦៤**	**១៩**	**៣៤**	**៦៣**	**១៩**	**៣២**	**៣២**	**១៧**

ប្រភព៖នាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. គិតត្រឹមខែកញ្ញា ឆ្នាំ២០១៩

៥. ការគ្រប់គ្រងហិរញ្ញវត្ថុ

ចំណាយដែលបានស្នើសុំជំពូក៦០ លើការទិញអស់១៣០ ៧០២ ៩០០៛ ស្មើនឹង៦៧,១០% នៃឥណទានអនុម័ត ១៩៤ ៨០០ ០០០រៀល។ ចំណាយដែលបានស្នើសុំជំពូក៦១ លើសេវាខាងក្រៅអស់ ២ ៣៦៣ ៣២០ ៣៥៥៛ ស្មើនឹង៨៣,៣៦%នៃឥណទានអនុម័ត ២ ៨៣៥ ២០០ ០០០ រៀល។ សរុបជារួមចំណាយដែលបានស្នើសុំសរុបរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍ដោយចីរភាពគឺ២ ៤៩៤ ០២៣ ២៥៥៛ ស្មើនឹង៨១,០៨% នៃឥណទានអនុម័ត ៣ ០៧៦ ០០០ ០០០ រៀល។

៦.ការរៀនសូត្រនិងបទពិសោធន៍ដែលទទួលបាន

- ការគាំទ្រ និងការណែនាំតម្រង់ទិសកម្រិតគោលនយោបាយរបស់ថ្នាក់ដឹកនាំមានភាពច្បាស់លាស់ប្រាកដនិយម និងឆ្លើយតបទៅនឹងអាទិភាពរបស់ជាតិ
- រក្សាបានជារួមនូវភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំនៅគ្រប់លំដាប់ថ្នាក់

- កំណត់បញ្ហាច្បាស់លាស់ និងលើកសំណើសិក្សាស្រាវជ្រាវដែលស្របទៅនឹងអាទិភាពរបស់ជាតិ
- ប្រើវិធីសាស្ត្រសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រ ដែលធានាបាននូវសត្យានុម័ត និងភាពជាក់លាក់នៃអនុសាសន៍គោលនយោបាយដែលស្នើឡើង
- ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញភាគច្រើនមានវិន័យការទទួលខុសត្រូវខ្ពស់ក្នុងការអនុវត្តការកិច្ច សាមគ្គីភាពផ្ទៃក្នុង និងមានសមត្ថភាពជំនាញច្បាស់លាស់
- រក្សាបាន និងលើកកម្ពស់ជាលំដាប់ ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការអន្តរក្រសួង ដោយឈរលើមូលដ្ឋានគោរពគ្នាទៅវិញទៅមក និងផលប្រយោន៍ជាតិជារួម
- រក្សាបាន និងលើកកម្ពស់ជាលំដាប់នូវ ភាពជាដៃគូទំនុកទុកចិត្ត និងសមត្ថភាពកៀរគរធនធានក្នុងចំណោមដៃគូអន្តរជាតិនានា
- មាននីតិវិធីច្បាស់លាស់និងសមត្ថភាពសមរម្យ ក្នុងការគ្រប់គ្រងគម្រោង ការគ្រប់គ្រងហិរញ្ញវត្ថុ និងការតាមដានត្រួតពិនិត្យ។

៧. បញ្ហាប្រឈម

- ចំនួនមន្ត្រីមធ្យោបាយ និងថវិកានៅមានកម្រិតសម្រាប់អនុវត្តការងារដែលបន្តកើនឡើងជាលំដាប់
- សមត្ថភាពជំនាញរបស់មន្ត្រីនៅមានកម្រិតជាពិសេសផ្នែកស្រាវជ្រាវ វិភាគទិន្នន័យ រៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការ និងសំណើគម្រោង
- កិច្ចសហប្រតិបត្តិការ និងការគាំទ្រធនធានពីដៃគូអភិវឌ្ឍន៍ នៅមានកម្រិត និងមិនអាចព្យាករបានច្បាស់លាស់
- ការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិរក្សកេសរកូលទទួលបានការចាប់អារម្មណ៍ និងគាំទ្រពីសារណជនទាំងថ្នាក់ជាតិ និងអន្តរជាតិ ដែលជាផ្នែកមួយចូលរួមលើកកម្ពស់ជីវភាពប្រជាជន ក៏ដូចជាការអភិវឌ្ឍន៍ប្រកបដោយចីរភាព ប៉ុន្តែនៅជួបប្រទះបញ្ហាថវិកា និងជំនាញ
- ការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី (PES) ជាយន្តការហិរញ្ញប្បទានថ្មី សម្រាប់គាំទ្រការអភិរក្សធនធានជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដែលតម្រូវឱ្យមានការចូលរួមពីវិស័យឯកជន និងចែករំលែកផលប្រយោជន៍សហគមន៍។

៨. ទិសដៅអនុវត្តបន្តឆ្នាំ២០២០

៨.១ នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ

- សម្របសម្រួលការរៀបចំសំណើសុំពរជ្ជាភិបាលអនុម័តសេចក្តីសម្រេចស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពអាណត្តិទី៦
- សហការជាមួយនាយកដ្ឋានជំនាញនៃអគ្គលេខាធិការដ្ឋាន ដើម្បីរៀបចំកិច្ចប្រជុំសមាជិកក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព លើកទី៣
- បន្តសម្របសម្រួលជាមួយអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងបរិស្ថាន និងគណៈកម្មាធិការគ្រប់គ្រងមូលនិធិបរិស្ថាន និងសង្គម ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកា ២០២១-២០២៣
- បន្តគ្រប់គ្រង និងចែករំលែកព័ត៌មាន លើគេហទំព័ររបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ncsd.moe.gov.kh) ដែលបានប្រកាសដាក់ឱ្យប្រើប្រាស់ថ្ងៃទី២៨ ខែមិថុនាឆ្នាំ២០១៩ កន្លងទៅ
- បន្តផ្សព្វផ្សាយ និងជំរុញការអនុវត្តយុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ២០១៦-២០២៣
- បន្តសម្របសម្រួលរៀបចំសេចក្តីណែនាំស្តីពីការដាក់បញ្ចូលការអភិវឌ្ឍដោយចីរភាពទៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បន្តសម្របសម្រួលការរៀបចំបញ្ចប់គន្ថីទី៣ និងផ្តល់ធាតុចូលដល់គន្ថីពាក់ព័ន្ធនៃសេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ
- សម្របសម្រួលកិច្ចប្រជុំរដ្ឋមន្ត្រីបរិស្ថាន អាស៊ាន ដែលគ្រោងប្រារព្ធខែតុលា ឆ្នាំ២០១៩ ដែលកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះ

- ផ្សព្វផ្សាយគោលនយោបាយ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីប្រកាស សារាចរណែនាំនិង ព័ត៌មានផ្សេងៗដល់អង្គភាពចំណុះ
- គ្រប់គ្រងស្ថិតិ ព័ត៌មាន វត្តមានមន្ត្រីរាជការ និង បុគ្គលិកពាក់ព័ន្ធ ដោយអនុវត្តន៍ឱ្យបានល្អស្រប តាមច្បាប់ស្តីពីសហលក្ខន្តិក:មន្ត្រីរាជការស៊ីវិល
- ពង្រឹងសមត្ថភាពមន្ត្រីរាជការ តាមរយៈការចូលរួម វគ្គបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស
- ដឹកនាំនិងសម្របសម្រួលការងាររដ្ឋបាល ផែនការ និងហិរញ្ញវត្ថុរបស់អគ្គលេខាធិការដ្ឋាន
- រៀបចំរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំ ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់អគ្គលេខាធិ ការដ្ឋាន ក.ជ.អ.ច.
- ការងារផ្សេងៗដែលថ្នាក់ដឹកនាំប្រគល់ជូន។

៨.២ នាយកដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

ក. ការងារកសាង និងពង្រឹងធនធានមនុស្ស និងសមត្ថភាព

- រៀបចំសិក្ខាសាលាលើកកម្ពស់ចំណេះដឹងវិទ្យា សាស្ត្របច្ចេកវិទ្យា នវានុវត្តន៍ និងបោះពុម្ពឯកសារ ផ្សព្វផ្សាយពាក់ព័ន្ធ
- ចូលរួមសន្និសីទ សិក្ខាសាលា វគ្គបណ្តុះបណ្តាល កិច្ចប្រជុំ និងវេទិកាពាក់ព័ន្ធនានា
- ចុះប្រមូលព័ត៌មាន ស្តីពីការប្រើប្រាស់បច្ចេកវិទ្យា បៃតងនៅតាមខេត្ត/ក្រុង
- រៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព ៥ឆ្នាំ២០១៩-២០២៤ ស្តីពីការស្រាវ ជ្រាវវិទ្យា សាស្ត្រ និងបច្ចេកវិទ្យា និងនវានុវត្តន៍
- ពង្រាងផែនទីបង្ហាញផ្លូវស្តីពីវិទ្យាសាស្ត្រ និងបច្ចេក វិទ្យា
- រៀបចំសេចក្តីព្រាងបញ្ចប់ក្រមសីលធម៌សិក្សា ស្រាវជ្រាវវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- បន្ទៀបចំកម្មវិធីសិក្សាស្រាវជ្រាវថ្នាក់ជាតិសម្រាប់ ការអភិវឌ្ឍដោយចីរភាព។

ខ. ការងាររៀបចំ និងកៀរគរថវិកា

- នាយកដ្ឋានកំពុងសហការជាមួយក្រសួងបរិស្ថាន រៀបចំសំណើគម្រោងសុំមូលនិធិពីដៃគូអភិវឌ្ឍន៍ ដើម្បីអនុវត្តគម្រោង **«ការជំរុញមធ្យោបាយដឹក ជញ្ជូនបៃតង តាមរយៈការប្រើប្រាស់យានយន្តអគ្គិ សនីនៅកម្ពុជា»** ជាមួយវិទ្យាស្ថានអភិវឌ្ឍន៍បៃតង សកល GGGI
- នាយកដ្ឋានកំពុងសហការជាមួយអង្គការអភិវឌ្ឍន៍ ឧស្សាហកម្មសហប្រជាជាតិ UNIDO ក្នុងការ រៀបចំសំណើគម្រោង**«ការរៃយតម្លៃតម្រូវការបច្ចេក វិទ្យាសម្រាប់តំបន់សេដ្ឋកិច្ចពិសេសក្នុងខេត្តព្រះ សីហនុ»** ដើម្បីរៀបចំសំណើគម្រោងស្នើសុំការគាំ ទ្រពីមូលនិធិអាកាសធាតុសកល (GCF)
- នាយកដ្ឋានកំពុងសហការជាមួយមជ្ឈមណ្ឌលនិង បណ្តាញបច្ចេកវិទ្យាអាកាសធាតុក្នុងការរៀបចំ សំណើគម្រោងកសាងភាពធន់នឹងអាកាសធាតុ សម្រាប់គ្រោះទឹកជំនន់និងគ្រោះរាំងស្ងួតនៅក្នុង ខេត្តកំពង់ធំ និងខេត្តព្រៃវែង តាមរយៈប្រព័ន្ធជូន ដំណឹងជាមុន ការពង្រឹងសមត្ថភាព ការបន្សាំផ្នែក កសិកម្មនិងការកែលម្អជីវភាពរស់នៅ ដើម្បីរៀបចំ សំណើគម្រោងស្នើសុំការគាំទ្រពីមូលនិធិអាកាស ធាតុសកល (GCF)
- នាយកដ្ឋានកំពុងសហការជាមួយអង្គការអភិវឌ្ឍន៍ ឧស្សាហកម្មសហប្រជាជាតិ UNIDO ក្នុងការពិនិត្យនិង ផ្តល់យោបល់លើឯកសារគម្រោងស្តីពីបច្ចេកវិទ្យា ស្អាតសកល ពន្លឿននវានុវត្តន៍បច្ចេកវិទ្យាស្អាត សកលនិងសហគ្រិនភាពក្នុងការបណ្តុះធុរកិច្ចថ្មី និងសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា។

គ. ការងារកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នពាក់ព័ន្ធ ប្រទេសម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍

- បន្តអនុវត្តអនុស្សរណៈនៃការយោគយល់លើកិច្ច សហប្រតិបត្តិការក្នុងការប្រើប្រាស់ថាមពលនុយក្លេ អ៊ែរសម្រាប់ បម្រើឱ្យគោលបំណងសន្តិភាពជាមួយ ភាគីរុស្ស៊ី និងភាគីចិន

- រៀបចំសម្របសម្រួលកិច្ចប្រជុំក្រុមការងាររួមកម្ពុជា-រុស្ស៊ីលើកទី៤
- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ក្រុមការងារថ្នាក់ជាតិលើសេចក្តីព្រាងកិច្ចព្រមព្រៀងបង្កើតមជ្ឈមណ្ឌលវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានុយក្លេអ៊ែរនៅក្នុងប្រទេសកម្ពុជា
- សហការជាមួយគ្រឹះស្ថានអប់រំ ដូចជាសាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាកលវិទ្យាល័យភូមិន្ទកសិកម្ម សាលាជាតិកសិកម្មព្រែកលៀប សាកលវិទ្យាល័យមានជ័យ សាកលវិទ្យាល័យត្បូងឃ្មុំ និងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា
- រៀបចំ MoU រវាង ក.ជ.អ.ច. និង CNNC ស្តីពីការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យថាមពលនុយក្លេអ៊ែរ។

៨.៣ នាយកដ្ឋានសេដ្ឋកិច្ចបៃតង

- បន្តសហការជាមួយប្រតិភូលេខាធិការដ្ឋាន SINGG នៃក្រសួងបរិស្ថានសាធារណរដ្ឋកូរ៉េ ដើម្បីឈានទៅដល់ការអនុម័ត និងអនុវត្តគម្រោងនៅដើមឆ្នាំ២០២០ខាងមុខ
- អនុវត្តផែនការសកម្មភាពគម្រោងរៀបចំគោលការណ៍ណែនាំ និងវិញ្ញាបនបត្រកម្មអគារបៃតងនៅកម្ពុជា
- បន្តសហការសម្របសម្រួលជាមួយវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកលប្រចាំកម្ពុជា ពាក់ព័ន្ធនឹងការងារការអភិវឌ្ឍទីក្រុងនិរន្តរភាពមាន៖ ១) ការងារបណ្តុះបណ្តាលគ្រូបង្គោលស្តីពីការរៀបចំទីក្រុងទីប្រជុំជននិរន្តរភាពដល់មន្ត្រីរាជការនៃក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលរាជធានីខេត្តពាក់ព័ន្ធ និង ២) ការរៀបចំបោះពុម្ពផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់ក្រុងគោលដៅទាំងប្រាំពីរ ២០១៨-២០៣០ រួមមានក្រុងកែប ព្រះសីហនុ បាត់ដំបង សៀមរាប កំពង់ចាម សួង និងក្រុងបាវិត
- រៀបចំសម្របសម្រួលបង្កើតក្រុមការងារបច្ចេកទេសស្តីពីការប្រើប្រាស់និងផលិតកម្មដោយនិរន្តរភាព
- លើកកម្ពស់ការយល់ដឹងស្តីពីការប្រើប្រាស់និងការផលិតដោយចីរភាព ទីក្រុងនិរន្តរភាពការអនុវត្តការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និងថាមពលនិរន្តភាព និងបង្កើនសមត្ថភាពដល់អ្នកពាក់ព័ន្ធ ក្នុងក្រសួងបរិស្ថាន និងក្រសួង ស្ថាប័នពាក់ព័ន្ធ ថ្នាក់ជាតិ និងក្រោមជាតិ
- រៀបចំប្រជុំក្រុមការងារបច្ចេកទេសចំនួន ០៦លើក ក្នុងនោះមាន៖ ១) ក្រុមការងារបច្ចេកទេសទីក្រុងនិរន្តរភាពចំនួន០២លើក ២)ក្រុមការងារបច្ចេកទេសវាយតម្លៃសក្តានុពលថាមពលពន្លឺព្រះអាទិត្យ (ថាមពលកកើតឡើងវិញ)ចំនួន០២លើក និង ៣)ក្រុមការងារបច្ចេកទេសការប្រើប្រាស់និងផលិតកម្មដោយនិរន្តរភាពចំនួន ០២លើក
- សហការជាមួយវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកលរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំបច្ចេកទេសស្តីពីការិយាល័យបៃតង(Green Office) និងវេទិកាបៃតង(Green Event) និងធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីនិរន្តរភាពទឹកក្រោមដីសម្រាប់អភិវឌ្ឍសេដ្ឋកិច្ចបៃតង
- សិក្ខាសាលាបណ្តុះបណ្តាលស្តីពីការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រលើវិស័យថាមពល និងទឹក និងឧបករណ៍ជំនួយដល់ការធ្វើសេចក្តីសម្រេចចិត្ត
- ចុះប្រមូលទិន្នន័យវាយតម្លៃវិយោបថនៃការប្រើប្រាស់ធនធាន (ទឹក ថាមពល និងសំណល់រឹង) របស់ប្រជាជនដែលរស់នៅក្នុងតំបន់ទីប្រជុំជនក្រុង
- ចូលរួមសន្និសីទនៃអង្គការសហព័ន្ធវិស្វកម្មអាស៊ាន-ASEAN Federation of Engineering Organization Mid-term and Annual
- ចូលរួមប្រជុំក្រុមការងារថ្នាក់ជាតិរួមកម្ពុជា-រុស្ស៊ីលើកទី៤ដើម្បីសម្របសម្រួលកិច្ចសហប្រតិបត្តិការ និងការប្រើប្រាស់ថាមពលនុយក្លេអ៊ែសំរាប់បម្រើឱ្យគោលបំណងសន្តិភាព និងចូលរួម Atom Expo (នៅប្រទេសរុស្ស៊ី)

ទំព័រ២៧

- កិច្ចប្រជុំក្រុមការងារ ASEAN ស្តីពីការប្រើប្រាស់និងការផលិតដោយចីរភាព និងទីក្រុងនិរន្តរភាព។

៨.៨ នាយកដ្ឋានប្រែប្រួលអាកាសធាតុ

ក. អប់រំ ផ្សព្វផ្សាយព័ត៌មាន លើកកម្ពស់ការយល់ដឹង និងបញ្ញាបការងារ

- រៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុចំនួន២ លើក
- រៀបចំសិក្ខាសាលាស្តីពីវឌ្ឍនភាពនៃការអនុវត្ត NDC ចំនួន១លើក និងសិក្ខាសាលាបញ្ញាបការប្រែប្រួលអាកាសធាតុ សម្រាប់យុវជន ចំនួន២លើក
- បញ្ចប់សារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់សម្រាប់របាយការណ៍ជាតិក្រោមអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ
- បញ្ចប់របាយការណ៍បច្ចុប្បន្នភាពពីរឆ្នាំម្តងក្រោមអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ
- បញ្ញាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការឃុំយ៉ាងតិចចំនួន៤ឃុំ
- ពង្រឹងសមត្ថភាពរបស់ក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ
- លើកកម្ពស់ចំណេះដឹង និងការកសាងសត្តភាពស្តីពីប្រែប្រួលអាកាសធាតុ
- ពង្រឹងសមត្ថភាពកម្ពុជាក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួននៅក្រោមអនុសញ្ញា UNFCCC

- ដើម្បីរៀបចំគោលនយោបាយកៀរគរវិកាសម្រាប់ការគ្រប់គ្រងធនធានធម្មជាតិ
- ផ្តល់ធាតុចូលសម្រាប់ការរៀបចំក្រមបរិស្ថាន និងធនធានធម្មជាតិ
- សិក្សាលទ្ធភាពដើម្បីធ្វើការកែសម្រួលលិខិតបទដ្ឋានគតិយុត្តជីវសុវត្ថិភាព
- រៀបចំពិគ្រោះយោបល់ថ្នាក់ជាតិ ដើម្បីចាប់ផ្តើមអនុវត្ត(PES) នៅក្នុងតំបន់គោលដៅ ដោយអនុវត្តគោលការណ៍ស្ម័គ្រចិត្តជាជំហានដំបូង

ខ. សិក្សាស្រាវជ្រាវ វាយតម្លៃរៀបចំយុទ្ធសាស្ត្រក្របខណ្ឌការងារ និងលើកកំពស់ការកសាងសមត្ថភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន

- លើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ បណ្តាប្រទេសក្នុងតំបន់ និងសកលក្នុងការដោះស្រាយប្រែប្រួលអាកាសធាតុ
- ការពារផលប្រយោជន៍ជាតិ នៅលើឆាកអន្តរជាតិក្នុងកិច្ចចរចាស្តីពីអាកាសធាតុទាំងថ្នាក់តំបន់ និងអន្តរជាតិ
- លើកកំពស់ភាពធន់ ការបន្សាំ និងការចូលរួមកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និងការកៀរគរធនធានហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ។

៨.៩ នាយកដ្ឋានជីវៈចម្រុះ

- រៀបចំប្រជុំលើកទី៣នៃក្រុមការងារបច្ចេកទេសជីវៈចម្រុះ និងអនុក្រុមការងារបច្ចេកទេសជីវសុវត្ថិភាព និង ABS
- ផ្សព្វផ្សាយពីយុទ្ធសាស្ត្រនិងផែនការសកម្មភាពជាតិស្តីពីជីវៈចម្រុះ និងការគ្រប់គ្រងធនធានជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ីនៅតំបន់ខាងកើតទន្លេមេគង្គ
- ធ្វើបច្ចុប្បន្នភាពរបាយការណ៍ស្ថានភាពជីវៈចម្រុះជាតិ
- រៀបចំក្របខណ្ឌគោលនយោបាយសេវាកម្មប្រព័ន្ធអេកូឡូស៊ី
- រៀបចំក្របខណ្ឌការងារនិងលិខិតបទដ្ឋានគតិយុត្តសម្រាប់អនុវត្តពិធីសារណាហ្គូយ៉ាស្តីពីABS
- សិក្សានិងវិភាគទិន្នន័យអំពីហិរញ្ញប្បទានជីវៈចម្រុះ
- រៀបចំយន្តការប្រមូល គ្រប់គ្រង និងបែងចែកផលប្រយោជន៍ពីការអនុវត្ត PES
- គ្រប់គ្រង ថែទាំ និងធ្វើបច្ចុប្បន្នភាព ព័ត៌មាន និងទិន្នន័យពាក់ព័ន្ធជីវៈចម្រុះជាប្រចាំ
- ផ្តើមដំណើរការប្រព័ន្ធគ្រប់គ្រងទិន្នន័យជីវៈចម្រុះជាតិ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយ
- ជំរុញ និងបញ្ញាការប្រើប្រាស់គេហទំព័រ CHM ដល់សាធារណជន ក្រសួងស្ថាប័ន និងអ្នកពាក់ព័ន្ធ

ទំព័រ២៨

- រៀបចំគេហទំព័រឱ្យមានពីរភាសា គឺភាសាអង់គ្លេស និងភាសាខ្មែរ
- ផលិតសម្ភារផ្សព្វផ្សាយ និងរៀបចំអត្ថបទសំខាន់ៗ ពាក់ព័ន្ធធនធានធម្មជាតិ និងជីវៈចម្រុះដើម្បីផ្សព្វផ្សាយ
- វាយតម្លៃតម្រូវការ និងជាក់ឱ្យដំណើរការមន្ទីរពិសោធន៍ជីវបច្ចេកវិទ្យាទំនើប ដោយសហការជាមួយនឹងមន្ទីរពិសោធន៍ក្រសួងបរិស្ថាន និង/ឬ មន្ទីរពិសោធន៍ពាក់ព័ន្ធ
- រៀបចំ និងជាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំពីការស្នើសុំលិខិតអនុញ្ញាក្រោមពិធីសារណាហ្គោយ៉ា
- រៀបចំ និងជាក់ឱ្យអនុវត្តផែនទីបង្ហាញផ្លូវនៃការអនុវត្តពិធីសារណាហ្គោយ៉ា
- កែលម្អ និងអភិវឌ្ឍន៍មជ្ឈមណ្ឌលស្រាវជ្រាវ និងអភិរក្សកេសរកូល សុខ អាន ភ្នំគូលែន រួមមានការពង្រីក ការរៀបចំប្រព័ន្ធទឹក ការរៀបចំថ្នាលបណ្តុះកូនកេសរកូល
- កំណត់ព្រំប្រទល់ និងដោះស្រាយបញ្ហាមិនប្រក្រតីក្នុងទីតាំងមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិរក្សកេសរកូល សុខ អាន ភ្នំគូលែន ដោយសហការជាមួយអ្នកពាក់ព័ន្ធ
- ប្រមូលសំណាកកេសរកូល និងសំណាកសត្វក្នុងខេត្តបាត់ដំបងប៉ៃលិន មណ្ឌលគីរី និងកំពត
- បោះពុម្ព និងផ្សព្វផ្សាយសៀវភៅស្តីពីប្រភេទរាតត្បាតនៅកម្ពុជា
- ស្តីពីការចែករំលែកផលប្រយោជន៍ពីធនធានពន្ធុដោយស្មើភាព និងសមធម៌
- ធ្វើវិសោធនកម្មនិងសំណើបង្កើតច្បាប់លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងជីវសុវត្ថិភាពតាមការចាំបាច់
- រៀបចំរបាយការណ៍ជាតិលើកទី៤ស្តីពីការអនុវត្តពិធីសារជីវសុវត្ថិភាពនិងបញ្ជូនទៅអគ្គលេខាធិការដ្ឋាននៃអនុសញ្ញាស្តីពីជីវៈចម្រុះ
- បន្តផ្សព្វផ្សាយឯកសារពិធីសារជីវសុវត្ថិភាព
- កសាងសមត្ថភាពដើម្បីអនុវត្តការងារជីវសុវត្ថិភាព
- ជាក់ឱ្យលិខិតបទដ្ឋានបែបបទក្នុងការដាក់ពាក្យសុំពិនិត្យសារពាង្គកាយកែច្នៃរស់
- ចុះ MoU ជាមួយប្រទេសកូស្តារីកា សាធារណរដ្ឋកូរ៉េ The Royal Botanic Garden, KEW នៃប្រទេសអង់គ្លេស សារមន្ទីរប្រវត្តិសាស្ត្រទីក្រុងប៉ារីស ប្រទេសបារាំង និងអង្គការផ្តោតលើសត្វព្រៃកម្ពុជា
- ធ្វើការសិក្សា និងវាយតម្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ីនៅប្រទេសកម្ពុជាដើម្បីបង្កើតវេទិកាវិទ្យាសាស្ត្រ-នយោបាយ
- ធ្វើការសិក្សាស្រាវជ្រាវស្ថានភាពជីវៈចម្រុះក្នុងតំបន់ការពារធម្មជាតិក្នុងខេត្ត មណ្ឌលគិរី
- ប្រមូល និងរៀបចំចងក្រងប្រព័ន្ធទិន្នន័យជីវៈចម្រុះដូចជា សត្វ និងរុក្ខជាតិ នៅកម្ពុជាដើម្បីធ្វើបច្ចុប្បន្នភាពគេហទំព័រជីវៈចម្រុះដោយសហការជាមួយភាគីពាក់ព័ន្ធ
- បង្កើតយន្តការកៀរគរថវិកាសម្រាប់ពង្រឹង អភិរក្ស និងប្រតិបត្តិមជ្ឈមណ្ឌល៕

៩. សន្និដ្ឋាន

ក្នុងរយៈពេល៩ខែនៃឆ្នាំ២០១៩នេះ អគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. បានអនុវត្តការងារប្រកបដោយជោគជ័យ ទាំងនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ។ ជោគជ័យទាំងអស់នេះកើតឡើងដោយសារការដឹកនាំប្រកបដោយយុទ្ធសាស្ត្រ ជាក់លាក់ រឹងមាំ និងចក្ខុវិស័យរបស់ថ្នាក់ដឹកនាំ ក.ជ.អ.ច. ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាប្រធានកិត្តិយស និងឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន ជាប្រធានដែលតែងតែយកចិត្តទុកដាក់ខ្ពស់ និងផ្តល់អាទិភាពចំពោះការងាររបស់អគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. ជាពិសេសគំនិតផ្តួចផ្តើមថ្មីៗ រួមមាន ការអភិវឌ្ឍវិស័យថាមពលកកើតឡើងវិញ ការអភិរក្សដីរៈចម្រុះ ការកសាងសង្គម និងសេដ្ឋកិច្ច ដែលមានភាពធន់នឹងអាកាសធាតុ ការលើកម្ពស់សេដ្ឋកិច្ចបៃតង ការសិក្សាស្រាវជ្រាវបែបវិទ្យា បច្ចេកវិទ្យានានុវត្តន៍ និងរដ្ឋបាលទំនើប ជាដើម។

ជាមួយគ្នានេះដែរ ជោគជ័យ និងសមិទ្ធផលទាំងនេះ គឺជាការចូលរួមចំណែករបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការចំណុះអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត សមត្ថភាព ប្រាជ្ញា ស្មារតី ធនធាន និងពេលវេលា ដើម្បីអនុវត្តសកម្មភាពអាទិភាពដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា និងក្របខណ្ឌគតិយុត្តនានាដែលមានជាធរមាន។ ឆ្លងតាមបទពិសោធន៍ការងាររយៈពេលជាង៤ឆ្នាំនេះ អគ្គលេខាធិការធិការដ្ឋាន ក.ជ.អ.ច. បានរៀនសូត្រការងារជាច្រើនរួមមានៈ ការងាររៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រ ការសិក្សាស្រាវជ្រាវ អភិបាលកិច្ចការពង្រឹងសមត្ថភាព ទំនាក់ទំនងអន្តរជាតិ ការកៀរគរធនធានមនុស្ស និងហិរញ្ញវត្ថុ។

ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. យល់ច្បាស់នូវតួនាទីគន្លឹះរបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក្នុងការរួមចំណែកគូសវាសនូវគោលនយោបាយជាតិ និងតាមវិស័យ ដោយផ្អែកលើមូលដ្ឋានសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រ សំដៅគាំទ្រនូវការអភិវឌ្ឍប្រកបដោយចីរភាព ហើយប្តេជ្ញា ខិតខំប្រឹងប្រែងបន្តទៀត ក្នុងការកសាងសមត្ថភាពបច្ចេកទេសនិងសមត្ថភាពស្ថាប័ន ការសម្របសម្រួលកិច្ចសហការជាមួយបណ្តាក្រសួងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល គ្រឹះស្ថានសិក្សាស្រាវជ្រាវ និងវិស័យឯកជន និងក្នុងការកៀរគរធនធាន ពីគ្រប់ប្រភព សំដៅរួមចំណែកអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់អាណត្តិទី៦នៃរដ្ឋសភា ២០១៩-២០២៣ ពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ក្រោមការដឹកនាំដោយឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ឆ្ពោះទៅសម្រេចឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០៕

រួមគ្នាឆ្ពោះទៅអភិវឌ្ឍន៍ដោយចីរភាព

Together towards Sustainable Development